# ការត្រួតពិនិត្យមីន



កម្ពុជា ២០០៧

## ប្រទេសកម្ពុជា

| | |
|---|---|
| ជារដ្ឋសមាជិកចាប់តាំងពី | ថ្ងៃទី ០១ មករា ឆ្នាំ ២០០០ |
| ច្បាប់អនុវត្តន៍សន្ធិសញ្ញា | អនុម័តនៅថ្ងៃទី ២៨ ឧសភា ឆ្នាំ ១៩៩៩ |
| របាយការណ៍មាត្រាទី ៧ ចុងក្រោយត្រូវបានប្រគល់នៅថ្ងៃ | ១១ ឧសភា ឆ្នាំ ២០០៦ |
| មាត្រាទី៤( ការបំផ្លាញគំនរគ្រាប់មីន) | ពេលកំណត់: ០១ មករា ឆ្នាំ ២០០៤<br>បានធ្វើរួចរាល់: ខែ កុម្ភៈ ឆ្នាំ ១៩៩៩ |
| មាត្រា ៣ ( គ្រាប់មីនដែលបានរក្សាទុក) | គ្មាន |
| ប្រភេទគ្រាប់មីនដែលមាន | APMs, AVMs, AXO, CBUs, និង UXO ផ្សេងៗទៀត |
| ផ្ទៃដីដែលមានគ្រាប់មីនតាមការប៉ាន់ស្មាន | ៤ ៤៤៦ គីឡូម៉ែត្រការ៉េ ការប៉ាន់ស្មានចាស់តាមការវាស់ស្ទង់ផលប៉ះពាល់របស់គ្រាប់មីន "LIS" |
| មាត្រាទី៥ ( ការបោសសំអាតផ្ទៃដីដែលមានមីន) | ពេលកំណត់: ០១ មករា ឆ្នាំ ២០១០ |
| លទ្ធភាពដែលអាចសំរេចបានតាមពេលកំណត់ | ខ្សោយ |
| ការរីកចំរើននៃការដោះមីនក្នុងឆ្នាំ ២០០៦ | ផ្ទៃដីដែលបានបោសសំអាតមីន 51.9 $km^2$ (2005: 40.6 $km^2$)<br>ផ្ទៃដីដែលបានលុបចោល/កាត់បន្ថយ: 303$km^2$ (2005: 85.4 $km^2$) |
| សមត្ថភាព **MRE** | គ្រប់គ្រាន់ |
| គ្រោះថ្នាក់គ្រាប់មីន/ សំណល់គ្រឿងផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាម **"ERW"** ក្នុងឆ្នាំ ២០០៦ | សរុប: 450 ករណី (2005: 875 ករណី)<br>ដោយសារមីន : 191 ករណី (2005: 365 ករណី)<br>សព្វាវុធផ្ទុះ: 20 ករណី (2005: 39 ករណី)<br>ERW ផ្សេងទៀត: 239 ករណី (2005: 471 ករណី) |
| ការវិភាគគ្រោះថ្នាក់ | ស្លាប់: 61 នាក់ (ជនស៊ីវិល 44 នាក់, ក្មេង 12 នាក់, ទាហាន 5 នាក់) (2005: 168 នាក់)<br>របួស: 389 នាក់ (ជនស៊ីវិល 238 នាក់, ក្មេង 128 នាក់, អ្នកដោះមីន 16 នាក់,ទាហាន 7 |

| | |
|---|---|
| | នាក់) (2005: 707 នាក់) |
| **អ្នករងគ្រោះដោយសារមីន/ERW ដែលនៅរស់តាមការប៉ាន់ស្មាន** | 43,316 នាក់ (2005: 42,927 នាក់) |
| **ការទទួលបានសេវាថែទាំក្នុងឆ្នាំ ២០០៦** | មិនមានការប្រែប្រួល ឬ កើនឡើងបន្តិចបន្តួច ប៉ុន្តែមិនគ្រប់គ្រាន់ |
| **ការរីនចំរើនចំពោះគោលបំណងផ្តល់ជំនួយដល់ជនរងគ្រោះដែលនៅរស់** | យឺតយ៉ាវ (VA24) |
| **ការផ្តល់ថវិកាកំចាត់មីនក្នុងឆ្នាំ ២០០៦** | ថវិកាអន្តរជាតិ: US$29 583 031 លានដុល្លារអាមេរិក /23.5 លានអឺរ៉ូ (2005: $23.9 លានដុល្លារអាមេរិក)<br>(ប្រទេសកម្ពុជាទទួលបាន ៤២%នៃថវិកាតាមការអំពាវនាវសុំជាដំណាក់ៗរបស់អង្គការសហប្រជាជាតិ)<br>ថវិកាជាតិ: 1,150,000ដុល្លារអាមេរិក |
| **ការរីកចំរើនសំខាន់ៗចាប់តាំងពីខែ ឧសភា ឆ្នាំ ២០០៦** | ប្រទេសកម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទតំបន់មួយស្តីអំពីការកំចាត់មីនក្នុងខែមីនា ឆ្នាំ ២០០៧ ។ អង្គការកំចាត់មីនក្រៅរដ្ឋាភិបាលបានបោសសំអាតមីនបានផ្ទៃដីកើនឡើង ១៥ ភាគរយក្នុងឆ្នាំ ២០០៦ និងបានរំដោះផ្ទៃដីច្រើនជាង៣ដងនៃផ្ទៃដីសំអាតមីនទាំងនោះ ។ អាជ្ញាធរមីនកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់អង្គការកំចាត់មីនក្រៅរដ្ឋាភិបាល ប៉ុន្តែកងយោធពលខេមរភូមិន្ទមិនបានទទួលស្គាល់។ ក្នុងខែមករា ឆ្នាំ ២០០៧ អ្នកដោះមីន CMAC ៧ នាក់ត្រូវបានស្លាប់ ។ យុទ្ធសាស្ត្រជាតិថ្មីមួយសំរាប់ MRE ត្រូវបានអនុម័តយល់ព្រម ហើយសមត្ថភាពត្រូវបានបង្កើន ប៉ុន្តែ MREបានទៅដល់ប្រជាពល-រដ្ឋតិចជាង ដោយសារតែការកំណត់យកតែក្រុមដែលអាចមានគ្រោះថ្នាក់ខ្ពស់បំផុត ។ ការរាយការណ៍ និងការបំផ្លាញមីន និង សំណល់គ្រឿងផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាមបានកើនឡើង ។ ការថយចុះនៃគ្រោះថ្នាក់ក្នុងឆ្នាំ ២០០៦បានបន្តថយចុះក្នុងឆ្នាំ ២០០៧ ។ ការវាយតម្លៃលើផ្នែកស្តារឡើងវិញខាងរាងកាយបានបង្ហាញអោយឃើញពីកង្វះខាតនៃផ្នែកនេះ ។ ផ្នែកនេះពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលបានកាត់បន្ថយជំនួយឧបត្ថម្ភក្នុងឆ្នាំ ២០០៦ ។ |

## គោលនយោបាយប្រឆាំងគ្រាប់មីន

ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើគោលនយោបាយប្រឆាំងគ្រាប់មីននៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ និងបានអនុម័តយល់ព្រមនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៩ ហើយសន្ធិសញ្ញានោះចូលជាធរមាននៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២000 ។ ច្បាប់អនុវត្តក្នុងស្រុក" ច្បាប់ស្តីការហាមឃាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស បានចូលជាធរមាននៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩[1] ។

គិតមកដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០០៧ ប្រទេសកម្ពុជា មិនទាន់បានប្រគល់របាយការណ៍ប្រចាំឆ្នាំស្តីអំពីតម្លាភាពមាត្រាទី៧ សំរាប់ឆ្នាំប្រតិទិន ២០០៦ នៅឡើយ ។ របាយការណ៍ថ្មីបំផុតរបស់ប្រទេសនេះត្រូវបានប្រគល់នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលរបាយការណ៍នោះសំរាប់ឆ្នាំប្រតិទិន២០០៥ ។ប្រទេសកម្ពុជាបានប្រគល់របាយការណ៍កន្លងមកចំនួន ៦ [2] ។

អគ្គលេខាធិការនៃអាជ្ញាធរកំចាត់មីននិងជួយជនរងគ្រោះកម្ពុជា (CMAA) លោក **សម សុត្ថា** បានដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមក្នុងកិច្ចប្រជុំរបស់ប្រទេសជាសមាជិកលើកទី៧ នៅក្នុងខែកញ្ញា ឆ្នាំ ២០០៦ ក្នុងទីក្រុង Geneva ។ ប្រទេសកម្ពុជាត្រូវបានគេអោយទទួលតួនាទីជា co-rapporteur នៃគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកជំនួយសំរាប់ជនរងគ្រោះ និងសមាហរណកម្មខាងផ្នែកសេដ្ឋកិច្ចសង្គម ដោយលោក **សម សុត្ថា** ទទួលតួនាទីនោះរហូតដល់កិច្ចប្រជុំរបស់រដ្ឋជាសមាជិកលើកទី ៨ ។ ប្រទេសកម្ពុជាបានធ្វើអន្តរាគមន៍ក្នុងសម័យប្រជុំនានាស្តីអំពីការបោសសំអាតមីននិងជំនួយសំរាប់ជនរងគ្រោះ ។ ប្រទេសកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំអន្តរសម័យប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៅក្នុងខែ ឧសភា ឆ្នាំ ២០០៦ និងខែ មេសា ឆ្នាំ ២០០៧ ។ នៅក្នុងកិច្ចប្រជុំនាខែមេសាប្រទេសកម្ពុជាបានធ្វើសេចក្តីថ្លែង ការណ៍ ស្តីអំពីការបោសសំអាតមីន និងជំនួយសំរាប់ជនរងគ្រោះ ។

ប្រទេសកម្ពុជាមិនបានចូលរួមក្នុងការពិភាក្សាទូលំទូលាយនានាស្តីអំពីបញ្ហាការបកស្រាយ និងការអនុវត្តពាក់ព័ន្ធទៅនឹងមាត្រាទី១ ទី២ និងទី៣ ជាពិសេសអំពីបញ្ហាពាក់ព័ន្ធទៅនឹងប្រតិបត្តិការយោធារួមគ្នា ជាមួយរដ្ឋដែលមិនមែនជាសមាជិកសន្ធិសញ្ញាបញ្ហាគ្រាប់មីនប្រឆាំងយាន្តយន្តដែលមានខ្សែឆ្នួនរួស ឬឧបករណ៍ប្រឆាំងនឹងការកាន់និងបញ្ហាចំនួនគ្រាប់មីនដែលគេអនុញ្ញាតអោយរក្សាទុកសំរាប់ការបណ្តុះបណ្តាលដែលប្រទេសជាសមាជិកផ្សេងៗទៀតបានចូលរួម ។

ប្រទេសកម្ពុជាជាភាគីមួយនៃកតិកាសញ្ញាស្តីអំពីអាវុធមិនមែននុយក្លេអ៊ែរ (CCW) និងពិធីសារកែសំរួលលើកទី ២នៃកតិកាសញ្ញានេះស្តីអំពីគ្រាប់មីនកប់ដី ។ ប្រទេសកម្ពុជាពុំបានចូលរួមក្នុងសន្និសីទប្រចាំឆ្នាំលើកទី ៨ របស់ប្រទេសជាសមាជិកស្តីអំពីពិធីសានោះនៅក្នុងទីក្រុង Geneva នាខែ វិច្ឆិកា ឆ្នាំ ២០០៦ ឡើយ ។ ប្រទេសនេះបានប្រគល់របាយការ-

[1] The law bans the production, use, possession, transfer, trade, sale, import and export of antipersonnel mines. It provides for criminal penalties, including fines and imprisonment for offenses committed by civilians or members of the police and the armed forces. It also provides for the destruction of mine stockpiles.

[2] The 2006 report was dated April 2006 but shown on the UN website as submitted on 11 May 2006; since then, the UN has ceased recording date submitted. Previous reports were submitted on: 22 April 2005, 30 April 2004, 15 April 2003, 19 April 2002, 30 June 2001 and 26 June 2000.

ណ៍តម្លាភាពក្នុងក្របខ័ណ្ឌមាត្រាទី ១៣នៃពិធីសា ក្នុងខែ មីនា ឆ្នាំ ២០០៧ ដែលគ្របដណ្តប់សកម្មភាពពីថ្ងៃទី ១ កក្កដា ឆ្នាំ ២០០៥ ដល់ថ្ងៃទី៣០ មិថុនា ឆ្នាំ ២០០៦។ ប្រទេសកម្ពុជាពុំទាន់ជាសមាជិកនៃ ពិធីសា CCW ទី ៥ ស្តីអំពីសំណល់គ្រាប់ផ្ទុះដោយសារសង្គ្រាមនៅឡើយ ។

ពីថ្ងៃទី ១២ ដល់ ១៤ ខែ មីនា ឆ្នាំ ២០០៧ ប្រទេសកម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទតំបន់មួយស្តីអំពីការកំចាត់មីននិងវិបាកសំរាប់សន្តិភាពនិងការអភិវឌ្ឍ[3] ។ នៅក្នុងកិច្ចប្រជុំនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានអំពាវនាវដល់រដ្ឋាភិបាលទាំងអស់នៅក្នុងតំបន់ អោយចូលរួមក្នុងសន្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីន ។ ឯកឧត្តមក៏បានមានប្រសាសន៍ថា" ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ជនរងគ្រោះដែលនៅរស់រានមានជីវិតរបស់យើង ដែលបានរំលឹកយើងយ៉ាងត្រឹមត្រូវថា ប្រទេសកម្ពុជាគួរតែគាំទ្រដំណើរការអូស្លូ "Oslo Process" (ដែលមានគោលបំណងបង្កើតជាសន្ធិសញ្ញាប្រឆាំងនឹងសព្វាវុធផ្គុំក្នុងឆ្នាំ ២០០៨) និងចូលរួមក្នុងកតិកាសញ្ញាស្តីអំពីសិទ្ធិជនពិការរបស់សហប្រជាជាតិ ខ្ញុំសូមគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាគាំទ្រដល់ជនរងគ្រោះដែលនៅរស់រានមានជីវិតពីសព្វាវុធសង្គ្រាមនិងគ្រាប់មិនទាន់ផ្ទុះនិងសព្វាវុធផ្គុំនិងដល់ការបោសសំអាតគ្រឿងសព្វាវុធទាំងអស់ដែលនៅរាយប៉ាយក្នុងប្រទេសរបស់យើង"[4] ។

*សកម្មភាពអង្គការក្រៅរដ្ឋាភិបាល*

យុទ្ធនាការប្រឆាំងនឹងគ្រាប់មីនរបស់ប្រទេសកម្ពុជា (CCBL)បានបន្តសកម្មភាពយ៉ាងសកម្ម ជាពិសេសទាក់ទងនឹងបញ្ហាជំនួយសំរាប់ជនរងគ្រោះ ។ បន្ថែមលើកិច្ចការទាក់ទិននឹងគ្រាប់មីនរបស់ខ្លួន ប្រទេសកម្ពុជាបានអនុវត្តសកម្មភាពជាច្រើនពាក់ព័ន្ធទៅនឹងសន្ធិសញ្ញាស្តីអំពីសិទ្ធិជនពិការ និងសព្វាវុធផ្គុំរបស់សហប្រជាជាតិ ។ យុទ្ធនាការប្រឆាំងនឹងគ្រាប់មីនរបស់ប្រទេសកម្ពុជា បានបញ្ចេញរបាយការណ៍ស្តីអំពីការត្រួតពិនិត្យគ្រាប់មីនកប់ដីឆ្នាំ ២០០៦ នៅក្នុងការិយាល័យសេវាជនភាសខ្លួនព្រះយេស៊ូគ្រីស្តក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦ ។ របាយការណ៍នោះបានបកស្រាយនិងលើកកំពស់កតិកាសញ្ញាស្តីអំពីសិទ្ធិជនពិការរបស់សហប្រជាជាតិ និងទទួលបាន ជោគជ័យក្នុងការប្តេជ្ញាចិត្តជាសាធារ-ណៈថា ប្រទេសកម្ពុជានឹងអនុម័តយល់ព្រមលើកតិការសញ្ញានេះ ។ អនុវត្តតាមសន្និសីទស្តីអំពីការបោសសំអាតគ្រាប់មីនយុទ្ធនាការប្រឆាំងនឹងគ្រាប់មីនអន្តរជាតិ "ICBL"សម្ព័ន្ធសព្វាវុធផ្គុំ និង យុទ្ធនាការប្រឆាំងនឹងគ្រាប់មីនរបស់ប្រទេសកម្ពុជា "CCBL"បានប្រារព្ធវេទិកាតំបន់មួយស្តីអំពីសព្វាវុធផ្គុំក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៧ ។

**ការផលិត ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និងការបំផ្លាញចោល**

រដ្ឋាភិបាលបានអោយដឹងថាខ្លួនគ្មានសម្ភារៈផលិតគ្រាប់មីនប្រឆាំងមនុស្សឡើយ[5] ។ ប្រទេសកម្ពុជាមិនត្រូវបានគេស្គាល់ថា ជាប្រទេសនាំចេញនូវគ្រាប់មីនប្រឆាំងមនុស្សឡើយក្នុងពេលកន្លងមក ។ គ្មានការចោទប្រកាន់ច្បាស់លាស់ណាមួយអំពីការប្រើប្រាស់ ការផលិត ឬការផ្ទេរនូវគ្រាប់មីនប្រឆាំងមនុស្សដោយកងកំលាំងរដ្ឋាភិបាល ឬកងកំលាំងប្រឆាំង

[3] Fifteen countries participated, as well as the ASEAN Secretariat, UN agencies, the ICRC, GICHD, ICBL and mine action organizations. For details, see Sam Sotha and Donica Pottie, Closing Summary, Mine Action and its Consequences on Peace and Development, Phnom Penh, 14 March 2007.

[4] Deputy Prime Minister Sok An, Address to the Regional Conference on Mine Action, Phnom Penh, 14 March 2007.

[5] Article 7 Reports, Form E. In the 1970s Cambodia manufactured one type of antipersonnel landmine, the KN-10 Claymore-type mine, and various forces manufactured home-made mines in the past.

ណាមួយឡើយចាប់តាំងពីឆ្នាំ១៩៩៩ មក។ អង្គការត្រួតពិនិត្យគ្រាប់មីនកប់ដីមិនបានរកឃើញភស្តុតាងណាមួយ អំពីការជួញដូរគ្រាប់មីនប្រឆាំងមនុស្សជាលក្ខណៈឯកជនឡើយក្នុងឆ្នាំ២០០៦ឬ២០០៧។ មានការថយចុះនៃការជួញដូរលោហៈអេតចាយដែលបានមកពីគ្រាប់មីនឬគ្រាប់មិនទាន់ផ្ទុះដែលគេបោះបង់ចោល អាស្រ័យដោយមានការត្រួតពិនិត្យដោយនរគរបាល និងរដ្ឋាភិបាល ។

កងយោធពលខេមរភូមិន្ទ(RCAF)បានបំផ្លាញគំនរគ្រាប់មីនប្រឆាំងមនុស្សដែលខ្លួនបានប្រកាសចំនួន៧១ ៩៩១ គ្រាប់ ក្នុងរវាងឆ្នាំ ១៩៩៤ និងឆ្នាំ ១៩៩៨ ហើយក្នុងខែកុម្ភៈ ឆ្នាំ ១៩៩៩ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទបានបញ្ជាក់ជាផ្លូវការថា កងយោធពលខេមរភូមិន្ទពុំមានស្តុកគ្រាប់មីនប្រឆាំងមនុស្សទៀតឡើយ[6] ។ នៅក្នុងឆ្នាំ ២០០០ ប្រទេសកម្ពុជាបានរាយការណ៍អំពីស្តុកគ្រាប់មីនប្រឆាំងមនុស្សចំនួន២០៣៤ គ្រាប់ដែលគ្រប់គ្រងដោយនគរបាលជាតិ[7] ។ ក្រោយមកប្រទេសកម្ពុជាបានប្រកាសថាគ្មានស្តុកគ្រាប់មីនប្រឆាំងមនុស្សទៀតទៀតឡើយចាប់តាំងពីឆ្នាំ២០០១មក[8] ។

ប៉ុន្តែ កងឯកភាពនគរបាលនិងយោធាបន្តរកឃើញគ្រាប់មីនប្រឆាំងមនុស្ស និងសព្វាវុធផ្សេងៗទៀត នៅតាមតំបន់នានា និងពីប្រភពផ្សេងៗជុំវិញផ្ទៃប្រទេស ។ គ្រាប់មីនជាច្រើនគឺជាគ្រាប់មីនដែលគេលាក់ដែលបានបន្សល់ទុកដោយសារសង្គ្រាមជាច្រើនទសវត្សកន្លងមក ។ ការដោះមីនក្រៅផ្លូវការ (តាមភូមិ) និងការជួញដូរលោហៈអេតចាយក៏បានរាប់បញ្ចូលជាស្តុកគ្រាប់មីនដែលគេរកឃើញថ្មីៗ ។ គេត្រូវរាយការណ៍គ្រាប់មីនទាំងនោះទៅអាជ្ញាធរមីនកម្ពុជា (CMAA)និងប្រគល់វាទៅអោយមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC)ដើម្បីបំផ្លាញចោល ។ គ្រាប់មីនខ្លះអាចត្រូវបានគេប្រើប្រាស់សំរាប់ការបណ្តុះបណ្តាល[9] ។

នៅក្នុងរបាយការណ៍មាត្រាទី៧ខែមេសាឆ្នាំ ២០០៦របស់ខ្លួន ប្រទេសកម្ពុជាបានប្រកាសថា ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៥ គេបានរកឃើញ និងបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៧១១៣៦ គ្រាប់រួមមាន ១៦៨៧៨ គ្រាប់ ត្រូវបានបំផ្លាញចោលដោយទីភ្នាក់ងារបីក្នុងឆ្នាំ ២០០៥ : ៩៥៤៤គ្រាប់ដោយCMAC ៥៧២០ គ្រាប់ដោយអង្គការ HALO Trust និង ១៦១៤ គ្រាប់ដោយអង្គការ MAG ។ នោះគឺជាចំនួនដែលច្រើនជាងគេបើធៀបទៅនឹងឆ្នាំមុនៗ ។ ប្រទេសកម្ពុជាបានកត់សំគាល់ថា គ្រាប់មីនទាំងនោះត្រូវបានប្រមូលដោយជនស៊ីវិល និងអាជ្ញាធរយោធាពីប្រភព តំបន់ និងពីកន្លែងលួចលាក់ ផ្សេងៗ[10] ។

*គ្រាប់មីនដែលគេរក្សាទុកសំរាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាល*

ក្នុងរបាយការណ៍មាត្រាទី៧របស់ខ្លួនទាំងមូលប្រទេសកម្ពុជាបានបញ្ជាក់ថា ខ្លួនគ្មានគ្រាប់មីនប្រឆាំងមនុស្សដែល

[6] See *Landmine Monitor Report 1999*, p. 391, for annual destruction totals.
[7] Article 7 Report, Form B, 26 June 2000.
[8] Article 7 Report, Form F, 30 April 2004.
[9] Article 7 Report, Forms D and F, 22 April 2005. For many years the discovery and disposal of these additional mines were not consistently or completely reported in Cambodia's Article 7 reports. It appears difficult for mine-affected countries like Cambodia to answer questions on stockpiles and destruction accurately, in view of mines transferred from minefields for destruction becoming temporary stockpiles, village caches and mines held in warehouses being found. See *Landmine Monitor Report 2004*, p. 248.
[10] Article 7 Report, Form G, April 2006. Mines destroyed in previous years included: 8,739 in 2000; 7,357 in 2001; 13,509 in 2002; 9,207 in 2003 (all by CMAC from 2000-2003); and 15,446 in 2004 (10,033 by CMAC, 3,632 by HALO and 1,781 by MAG). However, MAG informed Landmine Monitor that it had in effect destroyed 6,688 antipersonnel mines. Email from Tim Carstairs, Director of Communications, MAG, UK, 6 August 2007. For information on past inconsistencies in Article 7 reporting on discovered mines, see *Landmine Monitor Report 2004*, p. 248.

គេរក្សាទុកសំរាប់ការបណ្តុះបណ្តាល ឬអភិវឌ្ឍន៍ឡើយ ដូចដែលបានអនុញ្ញាតក្នុងក្របខ័ណ្ឌមាត្រាទី៣ ។ ប៉ុន្តែ ប្រទេសនេះក៏បានរាយការណ៍អំពីការដឹកជញ្ជូនគ្រាប់មីន សំរាប់ការបណ្តុះបណ្តាល ឬអភិវឌ្ឍន៍ ទៅអោយមជ្ឈមណ្ឌលបណ្តុះ-បណ្តាលរបស់ CMAC ជារៀងរាល់ឆ្នាំ ។ វាស្តែងអោយឃើញថាគ្រាប់មីនទាំងនេះត្រូវបានគេយកចេញពីដីដោយអ្នកដោះមីន ឬជាមីនដែលបានមកពីកន្លែងលួចលាក់ដែលគេទើបនឹងរកឃើញថ្មី ។

ប្រទេសកម្ពុជាមិនបានបញ្ជាក់ច្បាស់លាស់ថាគ្រប់គ្រាប់មីនទាំងអស់ ដែលគេផ្ទេរទាំងនោះត្រូវបានប្រើប្រាស់ជារៀងរាល់ឆ្នាំ ឬរក្សាទុកពីមួយឆ្នាំទៅមួយឆ្នាំសំរាប់ការបណ្តុះបណ្តាលយ៉ាងណានោះទេ ។ ជាងនេះទៅទៀត ប្រទេសកម្ពុជាពុំទាន់បានរាយការណ៍អោយបានពិស្តារអំពីគោលបំណងដែលគេចង់ធ្វើ និងការប្រើប្រាស់ជាក់ស្តែងនូវគ្រាប់មីនដែលគេរក្សាទុកសំរាប់ការបណ្តុះបណ្តាល ជាជំហានមួយដែលព្រមព្រៀងដោយរដ្ឋជាសមាជិកទាំងឡាយនៅក្នុងសន្និសីទពិនិត្យឡើងវិញលើកទី១ក្នុងឆ្នាំ២០០៤។ ប្រទេសកម្ពុជាមិនបានប្រើប្រាស់ទំរង់វែងថ្មី"ឃ""Form D"សំរាប់រាយការណ៍អំពីគ្រាប់មីនដែលត្រូវរក្សាទុក ដូចដែលបានព្រមព្រៀងដោយរដ្ឋជាសមាជិកទាំងឡាយនៅក្នុងកិច្ចប្រជុំលើកទី ៦ ក្នុងឆ្នាំ ២០០៥ ឡើយ ។

ប្រទេសកម្ពុជាបានរាយការណ៍ថាក្នុងឆ្នាំ២០០៥ មជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ CMAC ពុំបានទទួលគ្រាប់មីនប្រឆាំងមនុស្ស ដើម្បីគាំទ្រសកម្មភាពបណ្តុះបណ្តាលរបស់ខ្លួនឡើយ ។ របាយការណ៍នោះបានកត់សំគាល់ថាអង្គការ HALOបានទទួលគ្រាប់មីនចំនួន ៧៧ គ្រាប់ពីអ្នកភូមិសំរាប់ការបណ្តុះបណ្តាល[11] ។ ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៤គ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៣០៧៩ គ្រាប់ត្រូវបានគេរាយការណ៍ថាបានផ្ទេរទៅអោយមជ្ឈមណ្ឌលបណ្តុះបណ្តាលនោះដើម្បីប្រើប្រាស់សំរាប់ការហ្វឹកហ្វឺនដោះមីន រួមទាំងគ្រាប់មីន ៥៥៦ គ្រាប់ដែលបានមកពីកងឯកភាពដោះមីននានារបស់ CMAC ក្នុងឆ្នាំ ២០០៤[12] ។

## បញ្ហាគ្រាប់មីនកប់ដី និង សំណល់គ្រាប់ផ្ទុះបន្សល់ទុកដោយសារសង្គ្រាម(ERW)

ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំងឡាយដែលមានគ្រាប់មីនកប់ដី និងសំណល់គ្រាប់ផ្ទុះបន្សល់ទុកដោយសារសង្គ្រាមច្រើនជាងគេបំផុត រួមទាំងគ្រាប់បែកមិនមែននុយក្លេអ៊ែរ និងគ្រាប់បែកផ្គុំ គ្រាប់កាំភ្លើងត្បាល់ និងគ្រាប់ផ្ទុះដែលគេបោះបង់ចោល (AXO) ដែលបណ្តាលមកពីសង្គ្រាមជិតបីទសវត្សកន្លងមក[13] ។

១៥ ឆ្នាំបន្ទាប់ពីមានការដោះមីនជាលក្ខណៈមនុស្សធម៌នៅក្នុងប្រទេសកម្ពុជាមក គំនិតផ្តួចផ្តើមអោយមានការរំដោះផ្ទៃដី ថ្មីៗកំពុងធ្វើអោយមានការថយចុះយ៉ាងខ្លាំងនូវទំហំផ្ទៃដីដែលគេគិតថាមានគ្រាប់មីន ។ ការស្ទាបស្ទង់ផលប៉ះពាល់នៃគ្រាប់មីននៅឆ្នាំ ២០០២ (LIS)បានប៉ាន់ស្មានថាមានផ្ទៃដីប្រមាណ ៤៤៦៦ គីឡូម៉ែត្រការេត្រូវបានគេដឹងឬសង្ស័យថា មានគ្រាប់មីន[14] ។ នៅក្នុងឆ្នាំ ២០០៤ ផ្ទៃដីប្រមាណ ៤៦០ គីឡូម៉ែត្រការេ (ដែលអាចនឹងត្រូវបានកាត់បន្ថយ

[11] Article 7 Report, Form D, April 2006. HALO told Landmine Monitor in February 2006 that it is often called by police or military to dispose of mines or other ordnance handed over in remote areas. It said that some of the mines could be used for training and experimentation with disposal techniques. Interview with Richard Boulter, Programme Manager, HALO Trust, Siem Reap, 28 February 2006.

[12] Article 7 Reports, Form D, 22 April 2005 and April 2006.

[13] See *Landmine Monitor Report 2006*, p. 245.

[14] The LIS, also known as the Cambodia National Level 1 Survey, started in 2000 and was completed in May 2002. See, www.sac-na.org;

ថែមទៀតដោយការស្ទាបស្ទង់និងការគូសផែនទីថ្មីៗ) ត្រូវបានគេស្នើឡើង[15] ។ នៅក្នុងឆ្នាំ ២០០៥ អង្គការ HALO បានរកឃើញផ្ទៃដីធំៗជាច្រើនដែលបញ្ជាក់ដោយ(LIS) ថាប្រហែលជាអាចបង្កបង្កើនផលបាន។ ការនេះជំរុញអោយរដ្ឋាភិបាលអនុម័តយុទ្ធសាស្ត្រកាត់បន្ថយផ្ទៃដី ដែលនាំអោយមានការដកចេញនូវផ្ទៃដីជាង៣៨៩ គីឡូម៉ែត្រការេ ដែលពីមុនគេសង្ស័យថាមានគ្រាប់មីន នាដំណាច់ឆ្នាំ ២០០៦ [16] ។

នៅក្នុងឆ្នាំ ២០០៦ ក៏មានការថយចុះនូវគ្រោះថ្នាក់យ៉ាងគំហុក ដែលក្នុងនោះគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះមានជាងពាក់កណ្តាល ហើយ ភាគច្រើន( ៨៨ភាគរយ) កើតឡើងតែក្នុងខេត្តបួនតាមបណ្តោយព្រំដែនថៃតែប៉ុណ្ណោះ។ អត្រាធ្លាក់ចុះយ៉ាងខ្លាំងនេះបានបន្តនៅក្នុងឆ្នាំ២០០៧ ( សូមមើលផ្នែកបន្ទាប់ស្តីអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និង សំណល់គ្រាប់ផ្ទុះបន្សល់ទុកដោយសារសង្គ្រាម “ERW” ) ។

ប៉ុន្តែផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមដោយសារគ្រាប់មីន និងគ្រាប់ ERW នៅក្នុងប្រទេសកម្ពុជានៅតែមានកំរិតគួរអោយចាប់អារម្មណ៍ ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានមានប្រសាសន៍នៅក្នុងដើមឆ្នាំ ២០០៦ ថា ”បើទុកជាគ្រាប់មីនកប់ដី និងគ្រាប់ UXO មិនសម្លាប់ ឬធ្វើអោយប្រជាជនរងគ្រោះដោយផ្ទាល់ក្តី គ្រាប់ទាំងនោះគឺជាឧបសគ្គដ៏ធំចំពោះការអភិវឌ្ឍប្រទេស ពីព្រោះគេមិនអាចប្រើប្រាស់ដីដែលមានមីនទាំងនោះសំរាប់ធ្វើកសិកម្ម ឬតាំងទីលំនៅជាថ្មីបានឡើយ ប្រជាជនមិនអាចធ្វើដំណើរ ឬទទួលបានហេដ្ឋារចនាសម្ព័ន្ធសង្គមជាមូលដ្ឋានឡើយ ។ ការរំដោះខ្លួនអោយផុតពីគ្រាប់មីនគឺជាតំរូវការជាបឋមសំរាប់លើកស្ទួយជីវភាពប្រជាជនរងគ្រោះអោយរួចចាកផុតពីភាពក្រីក្រ” ។[17]

## កម្មវិធីសកម្មភាពកំចាត់មីន

អាជ្ញាធរមីនកម្ពុជា (CMAA)ដែលត្រូវបានបង្កើតឡើងក្នុងខែកញ្ញា ឆ្នាំ ២០០០ កំណត់បទដ្ឋាន និងសំរបសំរួលសកម្មភាពកំចាត់មីន[18] ។ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** គឺជាប្រធានអាជ្ញាធរមីនកម្ពុជា ហើយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ជាអនុប្រធាន ។ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** ដែលត្រូវបានតែងតាំងជាអនុប្រធានទី ២ នៃអាជ្ញាធរមីនកម្ពុជា ក្នុងខែ មិថុនា ឆ្នាំ ២០០៥ មានភារៈដឹកនាំកិច្ចពិភាក្សាជាមួយអ្នកផ្តល់ជំនួយក្នុងនាមជាប្រធានប្រតិបត្តិនៃក្រុមការងារបច្ចេកទេសរវាងរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយសំរាប់ការបោសសំអាតមីន [19] ។ អាជ្ញាធរមីនកម្ពុជាត្រូវគ្រប់គ្រងប្រចាំថ្ងៃដោយលោកអគ្គលេខាធិការ **សម សុត្ថា** [20] ។ កិច្ចប្រជុំមួយរបស់អាជ្ញាធរមីនកម្ពុជានាថ្ងៃទី ៥

---

*Landmine Monitor Report 2003,* p. 137.

15 Robert Griffin and Robert Keeley, “Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action,” Volume I, Phnom Penh, 4 December 2004.

16 HALO, “The need to document reclaimed land on the National Mined Area Database,” Phnom Penh, 2005. “Mine Action Achievements Report 2006 and Work Plan 2007,” CMAA, Phnom Penh, March 2007,p.29.

17 Deputy Prime Minister Sok An, address during a signing ceremony between UN Development Programme (UNDP) and Australia, Phnom Penh, 25 January 2006.

18 CMAC is the leading national demining operator but does not exercise the wider responsibilities associated with the term ‘center.’ Set up in 1992, CMAC was assigned the role of coordinator in the mid-1990s. It surrendered this function in a restructuring of mine action in 2000 that separated the roles of regulator and implementing agency and led to the creation of the CMAA.

19 See *Landmine Monitor Report 2006,* p. 250.

20 A royal decree dated 4 September 2000 and a subdecree dated 8 August 2001 define the roles and responsibilities of CMAA; the 2001 subdecree also confirmed CMAC’s status as service provider. For details, see Geneva International Centre for Humanitarian Demining, “A Study of the Development of Mine Action Legislation,” Geneva, 2004, pp. 64-66.

មករា ឆ្នាំ ២០០៦ បានគូសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អាជ្ញាធរមីនកម្ពុជា[21] ។

ពង្រាងស្តង់ដាសកម្មភាពកំចាត់មីនថ្នាក់ជាតិ៥ ក្នុងចំណោមពង្រាងស្តង់ដាសកម្មភាពកំចាត់មីនថ្នាក់ជាតិ ១៧ បានចូលជាធរមានក្នុងខែសីហា ឆ្នាំ ២០០៦ ទាក់ទិននឹងការផ្តល់ការទទួលស្គាល់ និងលិខិតអនុញ្ញាត ការត្រួតពិនិត្យអង្គការដោះមីន ការរក្សាទុក ការដឹកជញ្ជូននិងការគ្រប់គ្រងអាវុធជាតិផ្ទុះ និងការរាយករណ៍អំពីគ្រោះនៃការដោះមីន ។ ស្តង់ដា ៦ ទៀត រួមទាំងការបោសសំអាតគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ត្រូវបានអនុម័តនាដំណាច់ឆ្នាំ ២០០៦ ហើយត្រូវបានគេពិនិត្យឡើងវិញនៅក្នុងសិក្ខាសាលាមួយនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧[22] ។

អាជ្ញាធរមីនកម្ពុជាបានចាប់ផ្តើមទទួលស្គាល់អង្គការប្រតិបត្តិការដោះមីនទាំងអស់ដោយពេញលេញជាលើកដំបូងនៅក្នុងឆ្នាំ ២០០៦ ក្នុងគោលបំណងព្យួរការងារអង្គការប្រតិបត្តិការដោះមីនណាដែលមិនបំពេញលក្ខ័ណ្ឌស្តង់ដា[23] ។ នៅ ខែ តុលា អង្គការប្រតិបត្តិការដោះមីនធំៗទាំងបីគឺ CMAC, HALO និង MAG ត្រូវបានទទួលស្គាល់ ។ ក្រុមហ៊ុនពាណិជ្ជកម្ម ២ គឺ Phoenix Clearance និង BACTEC South East Asia ត្រូវបានទទួលស្គាល់ជាបណ្តោះអាសន្ន ។ ក្រុមហ៊ុនពាណិជ្ជកម្ម របស់ប្រទេសកម្ពុជាមួយឈ្មោះ MUA បានដាក់ពាក្យស្នើសុំ ប៉ុន្តែមិនទទួលបានការទទួលស្គាល់ ហើយត្រូវបានព្យួរការងារ[24] ។ ប៉ុន្តែកងយោធពលខេមរភូមិន្ទពុំបានដាក់ពាក្យសុំសំរាប់ការទទួលស្គាល់ឡើយ ហើយរដ្ឋាភិបាលបានចាត់ទុកជាករណីលើកលែងសំរាប់លក្ខ័ខ័ណ្ឌនេះដែលធ្វើអោយអ្នកពាក់ព័ន្ធទាំងឡាយមានកង្វល់អំពីទំហំនៃសមត្ថកិច្ចរបស់អាជ្ញាធរមីនកម្ពុជានិងការគាំទ្រដល់អាជ្ញាធរនេះពីរដ្ឋាភិបាល។ លោកអគ្គលោខាធិការអាជ្ញាធរមីនកម្ពុជា **សម សុត្ថា** បានមានប្រសាសន៍ថា "សម្តេចនាយករដ្ឋមន្ត្រីបានផ្តល់សេចក្តីទុកចិត្តទៅលើកងយោធពលខេមរភូមិន្ទហើយខ្ញុំអនុញ្ញាតអោយពួកគេដោះមីន"[25] ។

ដើម្បីលើកកំពស់តួនាទីរបស់ខ្លួនជាអ្នកចាត់ចែង អាជ្ញាធរមីនកម្ពុជាក៏បានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍផ្នែកធានាគុណភាពដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (UNDP) ដែលបានចុះកិច្ចសន្យាជាមួយអង្គការ BACTEC ក្នុងការផ្តល់ជំនួយបច្ចេកទេស ។ នៅក្នុងឆ្នាំ ២០០៦ អាជ្ញាធរមីនកម្ពុជា បានអោយក្រុមធានាគុណភាពដែលមានមនុស្ស ២ នាក់ ១ (QA) ចំនួន២ ក្រុម ធ្វើការវាយតម្លៃអង្គការដែលដាក់ពាក្យសុំការទទួលស្គាល់ ត្រួតពិនិត្យប្រតិ - បត្តិការ និងតាមដានអំពីគ្រោះថ្នាក់។ សំរាប់ឆ្នាំ២០០៧ អាជ្ញាធរនេះគ្រោងនឹងបន្ថែម២ក្រុមទៀត[26] ។ ផែនការការងារឆ្នាំ ២០០៧របស់ អាជ្ញាធរមីនកម្ពុជាក៏បានអំពាវនាវអោយមានការត្រួតពិនិត្យអោយបានហ្មត់ចត់ទៅលើគ្រោះថ្នាក់ធំៗទាំងអស់[27] ។ នៅក្នុងខែ កក្កដា ឆ្នាំ ២០០៧ ក្រុមធានាគុណភាពចំនួន ២ ក្រុម ត្រូវបានគេដាក់ពង្រាយជាអចិន្ត្រៃយ៏ក្នុងខេត្តបាត់តំបង និងសៀមរាប ដើម្បីបាននៅជិតប្រតិបត្តិការដោះមីននានា[28] ។

---

[21] See *Landmine Monitor Report 2006*, p. 250.
[22] Interview with Steve Munroe, Program Manager, UNDP, Siem Reap, 13 June 2007.
[23] Opening statement of Deputy Prime Minister Sok An, Third Conference on Mine Action Achievements, Phnom Penh, 24 May 2006.
[24] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 31.
[25] Interview with Sam Sotha, Secretary General, CMAA, Phnom Penh, 15 June 2007.
[26] Interview with Sam Sotha, CMAA, Phnom Penh, 15 June 2007.
[27] CMAA, "2007 Road Map," Phnom Penh, 27 November 2006, p. 6.
[28] Email from Steve Munroe, UNDP, 20 July 2007.

ប៉ុន្តែ សមត្ថភាពរបស់អាជ្ញាធរមីនកម្ពុជាក្នុងការបំពេញអណត្តិការងាររបស់ខ្លួនមានលក្ខណៈមិនច្បាស់លាស់ នៅពេលដែលក្រុមធានាគុណភាពមួយដែលត្រូវបានគេបញ្ជូនអោយធ្វើការស៊ើបអង្កេតលើការស្លាប់ របស់អ្នកដោះមីនរបស់ CMAC ៧នាក់ នាថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧ ត្រូវបានរារាំងដោយអង្គការ CMAC និងអាជ្ញាធរថ្នាក់លើផ្សេងៗមិនអោយធ្វើការស៊ើបអង្កេតអោយបានពេញលេញ។ ឧប្បត្តិហេតុនេះបានធ្វើអោយមានកង្វល់កាន់តែខ្លាំងឡើងក្នុងចំណោមអ្នកផ្តល់ជំនួយនិងអង្គការកំចាត់មីននានា ដែលខ្វះការគាំទ្រផ្នែកនយោបាយ ដែលបានធ្វើអោយថយចុះនូវឥទ្ធិពលរបស់អាជ្ញាធរមីនកម្ពុជានិងគាំទ្រស្តង់ដាផ្សេងទៀតសំរាប់អង្គការប្រតិបត្តិការដោះមីនក្នុងស្រុក និងបរទេសនានា [29] ។

អាជ្ញាធរមីនកម្ពុជាបានកត់សំគាល់ការពង្រឹងការគ្រប់គ្រងនិងការប្រមូលទិន្នន័យថាជា "សកម្មភាពជាគន្លឹះមួយ " ។ នៅក្នុង ខែ ឧសភា ឆ្នាំ ២០០៧ បន្ទាប់ពីបានពិភាក្សាជាមួយអង្គការប្រតិបត្តិការដោះមីននានា អាជ្ញាធរមីនកម្ពុជាបានអនុម័តយល់ព្រមលើសំណើជាច្រើនរបស់អង្គការស្ម័គ្រចិត្តអន្តរជាតិអូស្ត្រាលី (AVI)ដែលផ្អែកលើការវាយតម្លៃលើតំរូវការរបស់ផ្នែកទិន្នន័យរបស់អាជ្ញាធរមីនកម្ពុជា ដែលបានបញ្ចប់ទៅនៅក្នុងខែ ឧសភា ឆ្នាំ ២០០៦[30] ។ អង្គការ AVI បានរកឃើញថា អាជ្ញាធរមីនកម្ពុជាពុំបានកំណត់ស្តង់ដានៃរបាយការណ៍និងឯកសារ ដែលធ្វើអោយរបាយការណ៍ និង ឯកសាររបស់អង្គការប្រតិបត្តិការដោះមីននានាមានលក្ខណៈខុសៗគ្នា និងរកឃើញថា អាជ្ញាធរមីនកម្ពុជាមានការលំបាក ក្នុងការទទួលបានទិន្នន័យក្នុងទំរង់ដែលអាចប្រើប្រាស់បាន និងទៀងទាត់ ។ អ្នកផ្តល់ទិន្នន័យនីមួយៗមាននីតិវិធីគ្រប់គ្រងទិន្នន័យល្អៗ ប៉ុន្តែធ្វើការងារដាច់ដោយឡែកៗពីគ្នា ។ ជាងនេះទៅទៀត កងយោធពលខេមរភូមិន្ទ កងនរគរបាល និង អង្គការដោះមីនជាលក្ខណៈពាណិជ្ជកម្មដែលទើបបង្កើតថ្មី ពុំបាន "រាយការណ៍អំពីការបោសសំអាតឬព័ត៌មានអំពីការបោះបង់ចោលនូវគ្រាប់ផ្ទុះទៅជូនអាជ្ញាធរមីនកម្ពុជាអោយបានទៀងទាត់ឡើយ" [31] ។

អាជ្ញាធរមីនកម្ពុជា គ្រោងនឹងបង្កើតប្រព័ន្ធទិន្នន័យមជ្ឈឹមមួយដោយអនុម័តយកប្រព័ន្ធគ្រប់គ្រងព័ត៌មានសំរាប់ការកំចាត់មីន(IMSMA) ។ កិច្ចប្រជុំនានាជាមួយមជ្ឈមណ្ឌលអន្តរជាតិក្រុងហ្ស៊ីណែវសំរាប់ការដោះមីនជាលក្ខណៈមនុស្សធម៌ក្នុងក្រុងភ្នំពេញ នាខែ សីហា ឆ្នាំ២០០៧ ត្រូវបានគេគ្រោងធ្វើសំរាប់ដាក់បញ្ចូលកំណែទី៤ "version 4" [32] ។ នៅ ក្នុងខែ ឧសភា អាជ្ញាធរមីនកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាមួយស្តីអំពីការបណ្តុះបណ្តាលបុគ្គលិកខាងផ្នែកទិន្នន័យរបស់អាជ្ញាធរមីនកម្ពុជា ជាមួយអង្គការជំនួយប្រជាជនន័រវេស "Norwegian People's Aid" [33] ។

### *ផែនការយុទ្ធសាស្ត្រកំចាត់មីន*

ទស្សនៈវិស័យរយៈពេលមធ្យមរបស់ប្រទេសកម្ពុជាគឺសំដៅកាត់បន្ថយប៉ះពាល់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះអោយដល់កំរិតសូន្យនៅត្រឹមឆ្នាំ ២០១២ " ដោយបោសសំអាតផ្ទៃដីទាំងអស់ដែលមានផលប៉ះពាល់ដោយសារ

29 Interviews with mine action stakeholders, Phnom Penh, 14-15 June 2007.
30 Interview with Sam Sotha, CMAA, Phnom Penh, 15 June 2007.
31 AVI, "Recommendations for a Collective Information Management Strategy for the Cambodian ERW Action Sector," draft, Phnom Penh, May 2007, pp. 1-7.
32 Interview with Sam Sotha, CMAA, Phnom Penh, 15 June 2007.
33 Interview with Luke Atkinson, Norwegian People's Aid (NPA), Phnom Penh, 14 June 2007; Memorandum of Understanding between the Royal Government of Cambodia and Norwegian People's Aid in Cambodia, 16 May 2007.

គ្រាប់មីនខ្ពស់បំផុត ។ ទស្សនៈវិស័យរយៈពេលវែងគឺ "ប្រទេសកម្ពុជាមួយ គ្មានផលប៉ះពាល់អវិជ្ជមានដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះលើផ្នែកសេដ្ឋកិច្ចសង្គមនិងផ្នែកមនុស្សធម៌ ដោយកសាងសមត្ថភាពជាតិមួយដើម្បីដោះស្រាយបញ្ហានៅលើផ្ទៃដីដាច់ស្រយាលដែលមិនបានធ្វើការបោសសំអាតចាប់ពីឆ្នាំ ២០១២"[34] ។

នៅក្នុងឆ្នាំ២០០៥ អាជ្ញាធរមីនកម្ពុជាបានបង្កើតផែនការកំចាត់មីន ៥ឆ្នាំ សំរាប់២០០៥-២០០៩ ដែលដាក់ចេញនូវគោលដៅចំបង៧ បួន និងសកម្មភាពមួយចំនួន រួមមានផែនការៈ-

- បង្កើនការសម្របសម្រួលថ្នាក់ជាតិ ដោយធ្វើសមាហរណកម្មការកំចាត់មីនជាមួយការអភិវឌ្ឍជាតិ និងបង្កើតមធ្យោបាយគ្រប់គ្រងព័ត៌មាន
- កែលំអការធ្វើផែនការនិងការត្រួតពិនិត្យផ្នែកសេដ្ឋកិច្ចសង្គម ដោយធ្វើសមាហរណកម្មការបោសសំអាតមីនទៅក្នុងកិច្ចការរបស់គណៈកម្មាធិការកំចាត់មីនថ្នាក់ខេត្ត(PMACs) និងកងឯកភាពធ្វើផែនការកំចាត់មីន(MAPUs) ។
- បន្តអភិវឌ្ឍការកំចាត់មីន ដោយត្រួតពិនិត្យឡើងវិញនូវការដាក់ពង្រាយធនធានបោសសំអាតមីន កំណត់គោលដៅបោសសំអាតមីនចំការមីនដែលមានអាទិភាពខ្ពស់អោយបានត្រឹមឆ្នាំ ២០១២ កាត់បន្ថយចំនួននិងទំហំផ្ទៃដីដែលសង្ស័យថាមានគ្រាប់មីន និងអនុវត្តតាមស្តង់ដាបោសសំអាតមីនកម្ពុជា
- ពង្រីក និងកែលំអការសម្របសម្រួលការអប់រំអំពីគ្រោះថ្នាក់គ្រាប់មីន និងជំនួយជនរងគ្រោះ[35] ។

ផែនការ២០០៥-២០០៦ សំដៅផ្តល់ក្របខ័ណ្ឌជាតិមួយសម្រាប់ការធ្វើផែនការនិងកំណត់អាទិភាពប្រចាំឆ្នាំ ដែលកំណត់ដោយកងឯកភាពធ្វើផែនការកំចាត់មីន ដោយមានកិច្ចពិគ្រោះជាមួយអាជ្ញាធរថ្នាក់ស្រុក/ខេត្ត និងអង្គការដោះមីននានា សំរាប់ខេត្ត៥ដែលរងផលប៉ះពាល់ខ្លាំងជាងគេ[36] ។ ក្នុងគោលបំណងពង្រឹងការសម្របសម្រួល ចាប់ពីចុងឆ្នាំ ២០០៦ កងឯកភាពធ្វើផែនការកំចាត់មីនចាប់ផ្តើមទទួលរបាយការណ៍ប្រចាំខែពីអង្គភាពដោះមីននានា[37] ។ អង្គការបានកត់សំគាល់ការធ្វើអោយមាននិរន្តរភាពរបស់កងឯកភាពធ្វើផែនការកំចាត់មីនថាជាកង្វល់ដ៏ធំមួយ នៅពេលដែលជំនួយគាំទ្រដែលផ្តល់ដោយក្រុមអ្នកស្ម័គ្រចិត្តអូស្ត្រាលី (AVI) សំរាប់ពីរឆ្នាំមុននឹងត្រូវបញ្ចប់នៅពាក់កណ្តាលឆ្នាំ ២០០៨ខាងមុខ[38] ។

នៅក្នុងខែ ឧសភា ឆ្នាំ ២០០៦ រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់មួយ ដែលត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញនូវដីដែលគេសង្ស័យក្នុង LIS ប៉ុន្តែត្រូវបានសហគមន៍ចូលកាន់កាប់ឡើងវិញរួចហើយ ។ អគ្គលេខាធិការនៃអាជ្ញាធរមីនកម្ពុជា លោក **សម សុត្ថា** បានមានប្រសាសន៍ថា ដីបែបនោះមិនត្រូវបានគិតថាបានបោសសំអាតរួចនោះទេ

---

[34] CMAA, "National Mine Action Strategy," Third Edition, Phnom Penh, March 2005, p. 7.
[35] CMAA, "Five Year Mine Action Plan 2005-2009," Phnom Penh, April 2005, p. 6.
[36] For more information on MAPUs, see *Landmine Monitor Report 2006*, pp. 251-252. The five provinces are Battambang, Bantheay Meanchey, Krong Pailin, Oddar Meanchey and Prey Vihear.
[37] Interview with Andy Kervel, AVI, Siem Reap, 16 July 2007.
[38] "Mine clearance in Cambodia–2007, A HALO Trust background brief," HALO Trust, undated but May 2007,p.9.

ប៉ុន្តែគេគិតថា  ជាដីដែលត្រូវបានកាត់បន្ថយគ្រោះថ្នាក់ទៅដល់កំរិតមួយដែលគេមិនគួរពិចារណាធ្វើការដោះមីនបន្តទៀតឡើយ  វៀរលែងតែមានករណីពិសេស( ដូចជាសំរាប់ហេដ្ឋារចនាសម្ព័ន្ធ) ”[39] ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ  អាន** បានជំរុញអង្គការប្រតិបត្តិការដោះមីននានាអោយ ” ជួយអាជ្ញាធរមីនកម្ពុជាក្នុងការសំគាល់ផ្ទៃដីទាំងអស់ដែលពីមុនត្រូវបានគេសង្ស័យថាមានមីន      ប៉ុន្តែត្រូវបានគេប្រគល់អោយប្រជាជនធ្វើការបង្កបង្កើនផលបានប្រកបដោយសុវត្ថិភាពរួចហើយ ”  និងផ្តោតការយកចិត្តទុកដាក់លើការបោសសំអាតមីនលើផ្ទៃដីដែលមានគ្រាប់មីនច្រើនបំផុត[40] ។

នៅក្នុងឆ្នាំ ២០០៦ អង្គការ UNDP បានចាប់ផ្តើមអនុវត្តគំរោងរយៈពេល ៥ ឆ្នាំ មួយឈ្មោះ Clearing for Results ដែលមានបំណងបង្កើនប្រសិទ្ធភាពនិងតម្លាភាពក្នុងការបោសសំអាតមីន។ អង្គការ UNDP បានផ្តល់ថវិកាអោយអង្គការ CMAC សំរាប់កិច្ចការបោសសំអាតមីនដែលផ្សារភ្ជាប់ទៅនឹងគោលដៅផ្នែកសេដ្ឋកិច្ចសង្គមដែលបានកំណត់យ៉ាងច្បាស់លាស់ ។ នៅក្នុងដំណាក់កាលបន្ទាប់ អង្គការ UNDP មានគោលដៅអោយមានការប្រកួតប្រជែងដេញថ្លៃសំរាប់ការបោសសំអាតមីនដោយអង្គការណាដែលបានការទទួលស្គាល់អោយធ្វើការនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ ២០០៦ អង្គការ UNDP បានផ្តល់ថវិកាជាង ៤លាន សំរាប់គំរោងនេះ ដែលក្នុងនោះទឹកប្រាក់ ៣.៥លានសំរាប់ការបោសសំអាតនិងតុល្យភាពសំរាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងអាជ្ញាធរមីនកម្ពុជា។ នៅក្នុងឆ្នាំ២០០៦ អង្គការ UNDP បានផ្តល់ថវិកាចំនួនប្រហែល ៤.៥ លាន រួមមាន ៤លានសំរាប់ការបោសសំអាតមីន[41] ។

ការសិក្សាថ្នាក់ជាតិមួយដែលគេបញ្ចេញអោយដឹងនៅក្នុងឆ្នាំ ២០០៦ បានកត់សំគាល់ថា បញ្ហាគ្រាប់មីនរបស់ប្រទេសកម្ពុជាអាចត្រូវបានដោះស្រាយបានមួយចំនួនធំនៅត្រឹមឆ្នាំ ២០១០ និងជំរុញរដ្ឋាភិបាលអោយបង្កើតយុទ្ធសាស្ត្រមួយដើម្បីដោះស្រាយបញ្ហាយូរអង្វែងនៃគ្រាប់ផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាមរបស់ប្រទេសកម្ពុជា  និងដើម្បីតំរង់ទិសដៅធនធានកំចាត់មីនទៅដោះស្រាយបញ្ហាគ្រាប់ផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាមវិញ[42] ។ វាបានអំពាវនាវឱ្យរដ្ឋាភិបាលបង្កើតមជ្ឈមណ្ឌលជាតិគ្រាប់ផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាមមួយ។   គិតមកដល់ត្រឹមពាក់កណ្តាលឆ្នាំ ២០០៧ គ្មានការសម្រេចចិត្តណាមួយត្រូវបានធ្វើទៅតាមសំណូមពររបស់ការសិក្សានោះឡើយ[43] ។

### *ការធ្វើសមាហរណកម្មការបោសសំអាតមីនជាមួយការស្តារនិងអភិវឌ្ឍ*

នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ អាជ្ញាធរមីនកម្ពុជា បានចេញសេចក្តីណែនាំជាច្រើនសំរាប់ការអនុវត្តអនុក្រឹត្យឆ្នាំ ២០០៤ ស្តីអំពីការគ្រប់គ្រងសេដ្ឋកិច្ចសង្គមនៃការបោសសំអាតមីន ។ អនុក្រឹត្យនោះបានកំណត់នូវតួនាទីរបស់អាជ្ញាធរមីនកម្ពុជា របស់កងឯកភាពធ្វើផែនការកំចាត់មីន និងរបស់អាជ្ញាធរថ្នាក់ស្រុកនិងខេត្ត[44] ។

ការប្រើប្រាស់ដីក្រោយការបោសសំអាតនិងការចុះបញ្ជីដី  ដែលបានបោសសំអាតរួចបានក្លាយទៅជាចំនុចដែលត្រូវ

[39] Statement by Sam Sotha, CMAA, to a Landmine Monitor panel on mine action, Landmine Monitor Global Research Meeting, Phnom Penh, 3 April 2006; CMAA, “Draft Strategy on Area Reduction,” Phnom Penh, 26 April 2006.
[40] Deputy Prime Minister Sok An, Third Conference on Mine Action Achievements, Phnom Penh, 24 May 2006.
[41] Telephone interview with Steve Munroe, UNDP, Phnom Penh, 19 July 2007.
[42] Dave McCracken, “National Explosive Remnants of War Study, Cambodia,” (draft), NPA/CMAA, Phnom Penh, March 2006, p. 77.
[43] Interview with Sam Sotha, CMAA, Phnom Penh, 15 June 2007.
[44] Email from Steve Munroe, UNDP, 20 July 2007.

យកចិត្តទុកដាក់នៅពេលដែលមានសម្ពាធចេះតែកើនឡើងអំពីបញ្ហាដីធ្លី និងកង្វល់អំពីការចាប់យកដីនៅក្នុងតំបន់ដែលបានបោសសំអាតមីនរួច។ ដីភាគច្រើនត្រូវបានបោសសំអាតសំរាប់ការធ្វើកសិកម្មនិងការតាំងទីលំនៅជាថ្មី (៣០ភាគរយសំរាប់កសិកម្ម និង ១៤.៧ ភាគរយសំរាប់ការតាំងទីលំនៅជាថ្មី ក្នុងឆ្នាំ២០០៥)។ ប៉ុន្តែ អត្ថបទស្រាវជ្រាវមួយធ្វើឡើងដោយអង្គការ Austcare បានអោយដឹងថា នីតិវិធីការងាររបស់កងឯកភាពធ្វើផែនការកំចាត់មីនក្នុងការជ្រើសរើសផ្ទៃដីសំរាប់បោសសំអាតមីន និងសំរាប់បែងចែកដីមិនបានឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌរបស់ច្បាប់ភូមិបាលឆ្នាំ ២០០១ របស់ប្រទេសកម្ពុជា និងរកឃើញថាឯកសារដែលចេញទៅអោយអ្នកទទួលផលមិនមានទំរង់ដូចៗគ្នា និងមិនផ្តល់បណ្ណ័ចុះបញ្ជីត្រឹមត្រូវតាមច្បាប់ឡើយ។ អត្ថបទនោះបានជំរុញអោយអាជ្ញាធរមីនកម្ពុជាបន្តការធ្វើអោយស៊ីសង្វាក់គ្នានូវច្បាប់ពាក់ព័ន្ធទាំងឡាយ និងបានអំពាវនាវអោយមានគំរោងសាកល្បងមួយដើម្បីបង្កើតឯកសារដែលអាចធ្វើអោយការកាន់កាប់ដីដែលបានបោសសំអាតមីន និងបានបែងចែករួច ឬដែលគេគ្រោងនឹងធ្វើការដោះមីន មានលក្ខណៈត្រឹមត្រូវតាមច្បាប់[45]។

*ការវាយតំលៃការបោសសំអាតមីន*

ការរួមចំណែកនៃការបោសសំអាតមីន (រួមមានការបោសសំអាតមីន ការអប់រំអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងការជំរុញការអនុវត្តច្បាប់) និងកត្តានានាពាក់ព័ន្ធនឹងបរិស្ថាន រដូវ និងសេដ្ឋកិច្ច ចំពោះការថយចុះយ៉ាងគំហុកនូវគ្រោះថ្នាក់ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះត្រូវបានគេធ្វើការវាយតំលៃនៅក្នុងឆ្នាំ២០០៦។ ក្នុងការសិក្សានោះដោយផ្អែកលើបទសម្ភាសន៍ចំនួន៩០០ ដែលបានធ្វើក្នុងខេត្តចំនួន ៧ ក្នុងចន្លោះ ខែ តុលា និងខែធ្នូ ឆ្នាំ ២០០៦ អ្នកផ្តល់ព័ត៌មានក្នុងបទសម្ភាសន៍នោះបានកត់សំគាល់ការបោសសំអាតមីន និង EOD ថាជាមូលហេតុចំបងនៃការធ្លាក់ចុះនៃឧប្បត្តិហេតុ និងបន្ទាប់ពីមានការអប់រំអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន។ ការសិក្សានោះ បានកត់សំគាល់ថាការបោសសំអាតមីនត្រូវបានគេកំណត់គោលដៅបានកាន់តែប្រសើរឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដោយផ្តោតទៅលើអាទិភាពតាមតំបន់និងផ្ទៃដីដែលមានគ្រាប់មីនច្រើន ហើយការអប់រំអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីនតែឯង "ប្រហែលជាមិនអាចចាត់ទុកជាមូលហេតុនៃការធ្លាក់ចុះយ៉ាងខ្លាំងនោះបានទេ"។ ភាពក្រីក្រគឺជាកត្តាចំបងដែលជំរុញអោយប្រជាជនប្រឈម នឹងគ្រោះថ្នាក់ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ។ ចម្លើយរបស់អ្នកចូលរួមសម្ភាសន៍ និង ទិន្នន័យឧប្បត្តិហេតុបានអោយដឹងថា ការកាត់បន្ថយគ្រោះថ្នាក់ក៏ពាក់ព័ន្ធនឹងភាពប្រសើរឡើងនៃការប្រមូលផលនិងជីវភាពប្រជាពលរដ្ឋផងដែរ។ ការយកចិត្តទុកដាក់កាន់តែខ្ពស់របស់នគរបាលចំពោះបញ្ហាការជួញដូរគ្រឿងផ្ទុះខុសច្បាប់ដូចជាអេតចាយក៏អាចជាកត្តាមួយដែរ[46]។

[45] Austcare, "AIMAD Land Titling Pilot Project," Phnom Penh, February 2007.
[46] Ruth Bottomley, "A Study on the Dramatic Decrease of Mine/UXO Casualties in 2006 in Cambodia," February 2007. Organizations involved

## ការដោះមីន

ការដោះមីនតាមរយៈជំនួយមនុស្សធម៌ត្រូវបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលចំនួន ៣ គឺ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា អង្គការ HALO និង អង្គការ MAG ។ នៅក្នុងឆ្នាំ ២០០៧ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជាក៏បានចាប់ផ្តើមដោះមីន ក្នុងនាមក្រុមហ៊ុនជីករ៉ែអូស្ត្រាលី "BHP Billiton" ដែលកំពុងរុករករ៉ែបុកស៊ីតនៅក្នុងខេត្តមណ្ឌលគីរីប៉ែកឥសានប្រទេសកម្ពុជា ។ កងវិស្វកម្មនៃកងយោធពលខេមរៈភូមិន្ទធ្វើការដោះមីនជាចំបងសំរាប់គាំទ្រសកម្មភាពអាទិភាពរបស់រដ្ឋាភិបាល ដែលរាប់បញ្ចូលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ កងនេះក៏ទទួលយកកិច្ចសន្យាពាណិជ្ជកម្មសំរាប់ការអភិវឌ្ឍផ្លូវថ្នល់ដែល ឧបត្ថម្ភដោយធនាគារអភិវឌ្ឍអាស៊ី ។ វិស្វករនៃកងយោធពលខេមរៈភូមិន្ទក៏បានធ្វើប្រតិបត្តិការដោះមីនអោយសហប្រជាជាតិក្នុងប្រទេសស៊ូដង់ផងដែរ [47] ។

### *ការកំណត់អត្តសញ្ញាណ ការដាក់ផ្លាកសញ្ញា និងការធ្វើរបងព័ទ្ធផ្ទៃដីដែលមានមីន*

ប្រទេសកម្ពុជាមានទិន្នន័យដែលទទួលបានពីការធ្វើការស្ទាបស្ទង់ជាផ្នែកៗរបស់" LISនិងការស្ទាបស្ទង់បច្ចេកទេសដ៏ទូលំទូលាយមួយ " ដែលធ្វើឡើងដោយអង្គការដោះមីននៅក្នុងរយៈពេល ១៥ឆ្នាំ កន្លងទៅ[48] ។ ឧបករណ៍សំរាប់ធ្វើផែនការជាមូលដ្ឋានដែលប្រើប្រាស់ដោយ MAPU នៅតែជា "LIS "បើទោះជាការស្ទាបស្ទង់បែបនោះទទួលការរិះគន់ពីអង្គការដោះមីន ដោយសារតែបានបញ្ចូលដីដែលបានបោសសំអាតមីនរួចហើយ តែមិនបានបញ្ចូលផ្ទៃដីមួយចំនួនដែលមានគ្រាប់មីន [49] ។ ជាងនេះទៅទៀត វាមិនបានចែកអោយដាច់នូវកំរិតដែលមានគ្រាប់មីន " [50] ។

អនុលោមទៅតាមយុទ្ធសាស្ត្រកាត់បន្ថយផ្ទៃដីរបស់អាជ្ញាធរមីនកម្ពុជា អង្គការ HALO បានដាក់ពង្រាយក្រុមស្រាវជ្រាវនៅក្នុងឆ្នាំ ២០០៦ ដើម្បីប៉ាន់ស្មានបរិមាណផ្ទៃដីដែលបានបញ្ជាក់ថាជាដីសង្ស័យថាមានគ្រាប់មីនដោយ LIS ប៉ុន្តែត្រូវបានប្រជាជនចូលកាន់កាប់ឡើងវិញ ហើយគ្រោងនឹងបង្កើនចំនួនក្រុមដែលធ្វើកិច្ចការនេះដល់ទៅ៨ក្រុម នៅក្នុងឆ្នាំ២០០៧ [51] ។ អង្គការ MAG មាន៣ក្រុម សំរាប់ធ្វើផែនទីផ្ទៃដីដែលបានកាន់កាប់ឡើងវិញនៅក្នុងឆ្នាំ ២០០៦ ហើយគេរំពឹងថាចំនួនក្រុមនឹងឡើងដល់ ៦ក្រុមក្នុងឆ្នាំ ២០០៧[52] ។ ក្រុមស្ទាបស្ទង់បច្ចេកទេសចំនួន ២៣ របស់អង្គការ CMAC (ក្រុមដែលមានគ្នា៥ នាក់ៗ ចំនួន ១៩ និង ក្រុមដែលមានគ្នា១០ នាក់ៗ ចំនួន ៤) បានធ្វើការស្រាវជ្រាវលើផ្ទៃដី ចំនួន ២២០ គីឡូម៉ែត្រការេ ក្នុងឆ្នាំ ២០០៦ ហើយរំដោះផ្ទៃដីបានចំនួន ១៦៩.៥ គីឡូម៉ែត្រការេ ។ អង្គការ CMACបានដាក់

---

were Handicap International (HI), NPA, UNICEF and Cambodian Mine Victim Information Service (CMVIS).

47 "Cambodia to send new demining team to Sudan soon," *People's Daily Online*, 15 May 2007, http://english.people.com.cn, accessed 15 May 2007.

48 Dave McCracken, "National Explosive Remnants of War Response Study, Cambodia," (draft), NPA/CMAA, Phnom Penh, March 2006, p. 18.

49 CMAC found that more than 15 percent of land designated for clearance in the 2003 workplan was not included in the LIS.

50 HALO, "The need to document reclaimed land on the National Mine Area Database in Cambodia," Phnom Penh, 16 September 2005, p. 2.

51 Interview with Tim Porter, HALO, Siem Reap, 13 June 2007.

52 Interview with Nick Guest, Technical Operations Manager, MAG, Siem Reap, 13 June 2007.

ផ្លាកសញ្ញាលើបរិវេណដីដែលមានគ្រាប់មីន ឬដែលគេសង្ស័យថាមានគ្រាប់មីនចំនួន ២ គីឡូម៉ែត្រក្នុងឆ្នាំ ២០០៦[53] ។

*ការបោសសំអាតមីន/គ្រាប់ផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាម*

ការបោសសំអាតមីនដោយអង្គការមិនមែនរដ្ឋាភិបាលចំនួន៣ របស់ប្រទេសកម្ពុជា បន្តកើនឡើងក្នុងឆ្នាំ ២០០៦ បើទោះជាមានល្បឿនយឺតជាងកាលពីឆ្នាំ ២០០៥ក៏ដោយ ហើយការរំដោះផ្ទៃដីក៏បានកើនឡើងយ៉ាងខ្លាំង ដោយមានការជំរុញលើកទឹកចិត្តជាផ្លូវការ ។ អង្គការ CMAC, HALO និងអង្គការ MAG បានបោសសំអាតផ្ទៃដីចំនួន៣៥.៤ គីឡូម៉ែត្រ ការ កើនលើសឆ្នាំមុនចំនួន ១៥ ភាគរយ ប៉ុន្តែអង្គការទាំងនេះបានរំដោះផ្ទៃដីសរុបចំនួន ៣០៣គីឡូម៉ែត្រការ កើនលើសឆ្នាំ ២០០៥ ចំនួន ច្រើនជាង៣ ដង[54] ។ កងយោធពលខេមរភូមិន្ទបានអោយដឹងថា ខ្លួនបានដោះមីន៧០ ភាគរយច្រើនជាងឆ្នាំ ២០០៥ [55] ។

**ការដោះមីនក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៦**[56]

| អង្គភាពដោះមីន | ផ្ទៃដីដែលបានបោសសំអាតមីន (km$^2$) | APMs ដែលបានបំផ្លាញចោល | AVMs ដែលបានបំផ្លាញចោល | ផ្ទៃដីសមរភូមិដែល បានបោសសំអាត (km$^2$) | UXO ដែលបានបំផ្លាញចោល | AXO ដែលបានបំផ្លាញចោល | ផ្ទៃដីដែលបានកាត់បន្ថយឬលប់ចោល (km$^2$) |
|---|---|---|---|---|---|---|---|
| CMAC | 26.8 | 35,806 | 1,000 | N/A | 113,296 | N/A | 144 |
| HALO | 4.8 | 34,372 | 210 | N/A | 17,180 | N/A | 106 |
| MAG | 3.8 | 4,528 | 37 | N/A | 18,963 | N/A | 53 |
| NGO សរុប | 35.4 | 74,706 | 1,247 | | 149,439 | | 303 |
| RCAF | 16.5 | 1,528 | 139 | N/A | 9,870 | N/A | N/R |
| សរុប | 51.9 | 76,234 | 1,386 | | 159,309 | | 303 |

N/A = មិនអាចរកតួលេខបញ្ចូលបាន ; N/R = គ្មានរបាយការណ៍

អង្គការ CMAC ដែលជាអង្គភាពដោះមីនដ៏ធំជាងគេមានបុគ្គលិកជាង ២ ៣០០ នាក់ និងមានកងអនុសេនាតូចចំនួន ៤១ កង បានធ្វើការបោសសំអាតមីនកើនឡើងស្ទើតែពីរដងក្នុងឆ្នាំ ២០០៥ ហើយបានអោយដឹងថានៅក្នុងឆ្នាំ ២០០៦ ការបោសសំអាតមីនមានការកើនឡើងចំនួន ២១ ភាគរយទៀត។ ក្រុមស្ទាបស្ទង់បច្ចេកទេសរបស់អង្គការ CMAC ក៏បានធ្វើការបោសសំអាតកំណត់មួយក្នុងគោលបំណងកាត់បន្ថយគ្រោះថ្នាក់ ។ ដើម្បីសម្រេចបានភាពទន់ភ្លន់

[53] CMAC, “Annual Report 2006,” draft, Phnom Penh, undated but 2007, p. 4.
[54] CMAA, “Mine Action Achievements Report 2006 and Work Plan 2007,” Phnom Penh, March 2007, p. 29; see *Landmine Monitor Report 2006*, p. 254. HALO informed Landmine Monitor that it had area-reduced 160 square kilometers in 2006. Email from Tim Porter, HALO, 5 August 2007.
[55] RCAF operations are not subject to CMAA oversight, are not quality assured and its clearance data is unconfirmed.
[56] CMAA, “Mine Action Achievements Report 2006 and Work Plan 2007,” Phnom Penh, March 2007, p. 24.

បន្ថែមទៀត អង្គការCMACក៏បានផ្លាស់ប្តូរក្រុមកាត់បន្ថយគ្រោះថ្នាក់ និងក្រុមដាក់ផ្លាកសញ្ញាអោយធ្វើការបោសសំអាតចំការមីន និង គ្រោងផែនការបោសសំអាតគ្រាប់មិនទាន់ផ្ទុះ [57] ។ ដោយមានធនធានមេកានិកបន្ថែម អង្គការ CMAC ជឿជាក់ថាផលិតភាពប្រចាំឆ្នាំអាចត្រូវបានបង្កើនរវាងពី៣០ ទៅ៣៥ គីឡូម៉ែត្រការេក្នុងមួយឆ្នាំ១[58] ។ អង្គការ CMAC ក៏មានសមត្ថភាពប្រតិបត្តិការ EOD សំខាន់របស់ប្រទេសកម្ពុជាផងដែរ ដែលមានក្រុម EOD ចំនួន ២១ ក្រុម និងក្រុមចល័តចំនួន ៦ក្រុមកំពុងធ្វើការអប់រំផ្សព្វផ្សាយអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ និង គ្រោងផែនការបោសសំអាតគ្រាប់មិនទាន់ផ្ទុះ។ អង្គការ CMAC បានបើកការិយាល័យតំបន់ EOD មួយក្នុងខេត្តកំពង់ចាម ក្នុងដើមឆ្នាំ ២០០៦ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៅក្នុងខេត្តភាគខាងកើត[59] ។ នៅក្នុងឆ្នាំ ២០០៦ ក្រុមឆ្កែហិតគ្រឿងផ្ទុះចំនួនពីរក្រុមបានទទួលការបណ្តុះបណ្តាលនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ។ អង្គការ CMAC កំពុងពិចារណាការបណ្តុះ-បណ្តាល និងដាក់ពង្រាយក្រុមឆ្កែចំនួន ១០ ក្រុម[60] ។

អង្គការ HALO ដែលមានបុគ្គលិកអន្តរជាតិចំនួន ៤ នាក់ និងបុគ្គលិកជាតិចំនួន ១២០០ នាក់ បានដាក់ពង្រាយក្រុមបោសសំអាតមីនចំនួន ១០០ ក្រុម ដែលផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើខ្សែក្រវ៉ាត់គ្រាប់មីន" ក៥" តាមព្រំដែនកម្ពុជា-ថៃ និងទីតាំងការពារខ្លួនរបស់កងទ័ពវៀតណាម[61] ។ អង្គការ HALO បានអះអាងថា"ដង់ស៊ីតេគ្រាប់មីនដ៏ខ្ពស់ (ពី១០០០ ទៅ ៣០០០ គ្រាប់ក្នុងប្រវែង១គីឡូម៉ែត្រ) ហើយប្រវែងរបស់ " ក៥" (៧០០ គីឡូម៉ែត្រ) មានន័យថាចំណែកដី" ក៥" បន្ថែមទៀតទាមទារអោយមានការបោសសំអាតដើម្បីជួយអោយប្រទេសនេះសំរេចបាននូវស្ថានភាពគ្មានផលប៉ះពាល់ដោយសារគ្រាប់មីន "។ បើទោះជាអង្គការ HALOបានដោះមីនបានផ្ទៃដី ១៤ភាគរយតិចជាងឆ្នាំ ២០០៥ ក៏ដោយ ក៏ក្រុមរបស់អង្គការនេះបានដោះមីនប្រឆាំងមនុស្សបាន ៣៤៣៧២ គ្រាប់ គិតជាមធ្យមភាគគឺមានមីន ៧ ១៦០ គ្រាប់ក្នុង ១ គីឡូម៉ែត្រការេ ។ ក្រុមស្រាវជ្រាវរបស់អង្គការ HALOក៏បានកត់សំគាល់ផ្ទៃដីចំនួន ១៦០ គីឡូម៉ែត្រការេ ដែលពីមុនគេសង្ស័យថាមានគ្រាប់មីនថាជាដីដែលគេបានកាន់កាប់ឡើងវិញរួចហើយ [62] ។

អង្គការ MAG ដែលមានបុគ្គលិក ៤៥៦ នាក់ បានបង្កើនផលិតភាពរបស់ខ្លួនចំនួន ២១ ភាគរយក្នុងឆ្នាំ ២០០៦ ដោយធ្វើប្រតិបត្តិការរួមមួយជា "toolbox" ដែលមានក្រុមដោះមីនចំនួន ២៧ ក្រុម ក្រុមស្ទាបស្ទង់បច្ចេកទេសចំនួន ៥ ក្រុម និងក្រុមឆ្កែហិតមីនចំនួន ៣ ក្រុម ដែលបានមកពីការធ្វើកិច្ចសន្យាជាមួយអង្គការ CMAC និង ក្រុម EOD ចំនួន ៥ ក្រុម ។ អង្គការ MAGបានចាត់ទុកការកើនឡើងនៃការបោសសំអាតមីនដោយដៃថាបានមកពីការរួមចំណែកនៃការបន្ថែមប្រដាប់កាត់ព្រៃគម្លោតម៉ាក Tempest នៅក្នុងឆ្នាំ ២០០៦ ហើយរំពឹងថាផលិតភាពនឹងបន្តកើនឡើងនៅក្នុងឆ្នាំ ២០០៧។ អង្គការ MAG ក៏បានបណ្តុះបណ្តាលក្រុមដែលមានគ្នាពីរ១នាក់ចំនួន ៣ ក្រុម អោយចុះធ្វើការស្រាវជ្រាវដីដែលត្រូវបានគេកាន់កាប់ឡើងវិញ ហើយបានរំដោះផ្ទៃដីបាន ៥៣ គីឡូម៉ែត្រការេដែលសង្ស័យថាមានគ្រាប់មីននៅក្នុង

57 CMAC, "Annual Report," draft, Phnom Penh, undated but 2007, pp. 19-26.
58 Interview with Heng Rattana, Deputy Director General, CMAC, Phnom Penh, 15 June 2007.
59 CMAC, "Annual Report," draft, Phnom Penh, undated but 2007, pp. 1, 13, 34.
60 Interview with Heng Rattana, CMAC, 15 June 2007.
61 Interview with Tim Porter, HALO, Siem Reap, 13 June 2007.
62 HALO, "Mine clearance in Cambodia–2007," undated but 2007, p. 8.

LIS ក្នុងរយៈពេលតែ ៣ខែកន្លងទៅនៃឆ្នាំ ២០០៦ ប៉ុណ្ណោះ ។ អង្គការ MAG បានបញ្ឈប់ក្រុម EOD ចំនួន ៣ក្រុមក្នុងចំណោមក្រុម EOD ចំនួន ៧ បន្ទាប់ពីអ្នកផ្តល់ជំនួយឈប់ផ្តល់ការគាំទ្រ ប៉ុន្តែក្រោយមកបានអោយ ១ក្រុមចូលធ្វើប្រតិបត្តិការវិញ ។ ទោះបីជា បាត់បង់សមត្ថភាពក្រុម EOD ក្តី អង្គការ MAG បានបោសសំអាតគ្រាប់មិនទាន់ផ្ទុះកើនឡើងជិត ១០ ភាគរយ ក្នុងឆ្នាំ ២០០៦ [63] ។

ដោយយល់ឃើញថា ផលប្រយោជន៍នៃការបោសសំអាតមីនចំពោះសហគមន៍ត្រូវបានបង្កើនជាអតិបរមា នៅពេលដែលមានការគាំទ្រអោយមានការប្រើប្រាស់ដីដែលគេបានចូលកាន់កាប់ឡើងវិញ អង្គការ MAG បានធ្វើការជាដៃគូជាមួយទីភ្នាក់ងារអភិវឌ្ឍន៍នានា រួមមានអង្គការ Lutheran World Federation, អង្គការ World Vision, អង្គការ Church World Service និងអង្គការ CARE ។ វិធីសាស្ត្រធ្វើកិច្ចការបោសសំអាតមីនរួមគ្នានេះមានគោលបំណងធានាអោយមានការប្រើប្រាស់ដីដែលពាក់ព័ន្ធអោយបានទាំងស្រុង ក្រោយពីបានបោសសំអាតមីនរួច [64] ។

នៅក្នុង ៦ខែដើមឆ្នាំ ២០០៧ អង្គការដោះមីនក្រៅរដ្ឋាភិបាលបានបន្តបង្កើនល្បឿនការបោសសំអាតមីន ។ អង្គការ CMAC បានដោះមីនបាន ១៣,៣ គីឡូម៉ែត្រការេ អង្គការ HALOបាន ២,៣ គីឡូម៉ែត្រការេ និងអង្គការ MAGបាន២,៥គីឡូម៉ែត្រការេ ។ អង្គភាពប្រតិបត្តិការដោះមីនទាំង៣ បានកាត់បន្ថយផ្ទៃដីគ្រាប់មីនបាន២៦៨ គីឡូម៉ែត្រការេនៃផ្ទៃដីដែលពីមុនសង្ស័យថាមានគ្រាប់មីនដែលដីទាំងនោះភាគច្រើនត្រូវបានគេចូលកាន់កាប់ឡើងវិញរួចហើយ[65] ។ កិច្ចប្រឹងប្រែងបោសសំអាតមីនរបស់អង្គការ CMAC ត្រូវបានរំខាននៅក្នុងខែឆ្នាំ ២០០៧ដោយសារឧបត្តិហេតុមួយដែលបានសំលាប់អ្នកដោះមីននៃកងអនុសេនាតូចដោះមីនតាមមូលដ្ឋានអស់ចំនួន ៧ នាក់ ។ របាយការណ៍ឧបត្តិហេតុរបស់អង្គការ CMACបានសន្និដ្ឋានថា ឧប្បត្តិហេតុនោះបណ្តាលមកពីមីនប្រឆាំងយានយន្តចំនួន ៩ ឬ ១០គ្រាប់ផ្ទុះឡើងរួមគ្នា ហើយមិនមែនបណ្តាលមកពីការធ្វើខុសពីនីតិវិធីប្រតិបត្តិការអចិន្ត្រៃយ៍(SOPs) ឡើយ ប៉ុន្តែបានបង្ហាញអោយឃើញនូវចំណុចខ្សោយនៃការដឹកនាំនៃមេបញ្ជាការនៃកងអនុសេនាតូចនោះ[66] ។ សេចក្តីព្រាងរបាយការណ៍ឧប្បត្តិហេតុ របស់ក្រុមស៊ើបអង្កេតនៃអាជ្ញាធរមីនកម្ពុជាបានអោយដឹងថា គេមិនអាចធ្វើការសន្និដ្ឋានអោយបានជាក់លាក់បានទេ ដោយសារតែអង្គការ CMAC ហាមឃាត់មិនអោយចូលទៅជិតកន្លែងកើតហេតុ និងសាក្សីបន្ទាប់ពីពេលកើតហេតុភ្លាមៗ ។ ការនេះបានធ្វើអោយមានមន្ទិលពិតម្លាភាពនៃចំលើយរបស់អង្គការ CMAC ។ សេចក្តីព្រាងនោះបានកត់សម្គាល់ថាអ្នកដោះមីន ៥នាក់ក្នុងចំណោមអ្នកដោះមីនដែលបានស្លាប់ទាំងនោះមិនបានពាក់សម្ភារៈការពារខ្លួនឡើយ ចន្លោះសុវត្ថិភាពរវាងជួរដោះមីនមិនមានគម្លាតគ្រប់គ្រាន់ ហើយថានីតិវិធីប្រតិបត្តិការអចិន្ត្រៃយ៍មានភាពខុសៗគ្នារវាងកងអនុសេនាតូចដោះមីនរបស់ អង្គការ CMAC[67] ។

63 Email from Rupert Leighton, MAG, 9 August 2007.
64 Email from Rupert Leighton, MAG, 9 August 2007.
65 Emails from CMAC, 20 July 2007, HALO, 20 July 2007, MAG, 18 and 23 July 2007. CMAC reported area reducing 60.2 square kilometers, HALO 73.97 square kilometers and MAG 134.4 square kilometers.
66 CMAC, "Investigation Report on AT Mine Accident 19 January 2007," Phnom Penh, 22 February 2007.
67 CMAA, "Draft accident report," Phnom Penh, undated but 2007.

## សង្ខេបកិច្ចខិតខំប្រឹងប្រែងអនុវត្តក្នុងមាត្រាទី ៥នៃអនុសញ្ញាអូតាវ៉ា

អនុលោមតាមមាត្រាទី៥ នៃសន្ធិសញ្ញាប្រឆាំងគ្រាប់មីន ប្រទេសកម្ពុជាត្រូវបោសសំអាតមីនប្រឆាំងមនុស្សទាំងអស់ពីតំបន់ដែលមានគ្រាប់មីន ដែលស្ថិតក្នុងសមត្ថកិច្ច ឬការគ្រប់គ្រងរបស់ខ្លួន អោយបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនអោយយឺតជាងថ្ងៃទី ១ ខែមករា ឆ្នាំ ២០១០ ឡើយ ។ ប៉ុន្តែ ទស្សនវិស័យរយៈពេលមធ្យមរបស់ប្រទេសកម្ពុជា គឺត្រូវគេចអោយផុតពីផលប៉ះពាល់នៃគ្រាប់មីននៅឆ្នាំ ២០១២[68] ។ នៅក្នុងខែមេសា ឆ្នាំ ២០០៦ អគ្គលេខាធិការនៃអាជ្ញាធរមីនកម្ពុជាបានអះអាងជាសាធារណៈថាប្រទេសកម្ពុជានឹងមិនអាចសំរេចកិច្ចការទៅតាមកាលកំណត់បានឡើយហើយថា "គេត្រូវការការពន្យារពេល" ។ លោកបានមានប្រសាសន៍ថា រដ្ឋាភិបាលនឹងបញ្ជាក់ឱ្យបានច្បាស់ពីរយៈពេលដែលត្រូវពន្យារ បើសិនជាមានសំណូមពរ ហើយនឹងពន្យល់អោយបានពិស្តារពីមូលហេតុនៃការពន្យារពេលនោះ[69] ។

**ការដោះមីននៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០០២-២០០៦: ទិន្នន័យបោសសំអាតមីនរបស់អង្គការក្រៅរដ្ឋាភិបាល**

*( មានលទ្ធផលសរុបរបស់អង្គការក្រៅរដ្ឋាភិបាល និងកងយោធពលខេមរភូមិន្ទ)*

| ឆ្នាំ | ផ្ទៃដីដែលបានបោស សំអាតមីន ($km^2$) | ផ្ទៃដីដែលបានកាត់បន្ថយ ឬលប់ចោល ($km^2$) | ផ្ទៃដីសរុបដែលបានរំដោះ ($km^2$) |
|---|---|---|---|
| 2002 | 17.8 (34.9) | - | 17.8 (34.9) |
| 2003 | 17.3 (41.7) | - | 17.3 (41.7) |
| 2004 | 18.9 (32.0) | - | 18.9 (32) |
| 2005 | 30.8 (40.6) | 85.4 | 116.2 (126) |
| 2006 | 35.4 (51.9) | 303 | 338.4 (354.9) |
| សរុប | 120.2 (201.1) | 388.4 | 508.6 (589.5) |

ប្រទេសកម្ពុជាបានធ្វើអោយមានការរីកចំរើនយ៉ាងខ្លាំងក្នុងការបោសសំអាតមីន និងរំដោះផ្ទៃដីដែលមានមីន និង ដីដែលគេសង្ស័យថាមានគ្រាប់មីននៅក្នុងរយៈពេល ២ ឆ្នាំ កន្លងទៅនេះ ។ អង្គការក្រៅរដ្ឋាភិបាលនានាបានធ្វើឱ្យល្បឿននៃការដោះមីនរបស់ខ្លួនកើនឡើងទ្វេដង និងបានបោះជំហានដ៏សំខាន់មួយទៅរកការកំណត់ទំហំនៃបញ្ហាដែលនៅសេសសល់ឱ្យបានត្រឹមត្រូវដោយធ្វើការលប់ចោលឬកាត់បន្ថយផ្ទៃដីជាង៣៨៨ គីឡូម៉ែត្រការ៉េ ដែលសង្ស័យថាមានគ្រាប់មីនដោយ LIS ឆ្នាំ២០០២។ ការសិក្សាមួយដែលធ្វើឡើងដោយអង្គការ Norwegian People's Aid សំរាប់អង្គការ CMAC បានសង្កេតឃើញថា "ផ្ទៃដីនៅតាមព្រំដែនដែលមានគ្រាប់មីនច្រើនដែលនៅសេសសល់ អាចត្រូវបានគេកាត់បន្ថយក្នុងរយៈពេលរវាងពី ៥ទៅ១០ឆ្នាំ" ដោយកត់សម្គាល់ថា បើទោះជាការប៉ាន់ស្មាននេះអាចមានលក្ខណៈអភិរក្សបន្តិចក៏ដោយ [70] ។

[68] CMAA, "National Mine Action Strategy," Third Edition, Phnom Penh, March 2005, p. 7.
[69] Statement by Sam Sotha, CMAA, to Landmine Monitor panel on mine action, Phnom Penh, 3 April 2006.
[70] Dave McCracken, "National Explosive Remnants of War Study, Cambodia," (draft), NPA/CMAA, Phnom Penh, March 2006, pp. vii, 73.

## ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន

ប្រទេសកម្ពុជាមិនបានបញ្ចូលសកម្មភាពអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនទៅក្នុងទំរង់ទី១ នៃរបាយការណ៍មាត្រាទី ៧ ប្រចាំឆ្នាំ ២០០៦, ២០០៥ ឬ២០០៤ ឡើយ។ ទោះជាយ៉ាងណាការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនត្រូវមានក្នុងរបាយការណ៍ក្នុងមាត្រាទី ១៣ នៃពិធីសារវិសោធនកម្មទី ២ របស់អនុសញ្ញាស្តីពីគ្រឿងសព្វាវុធរបស់ប្រទេសកម្ពុជា សម្រាប់រយៈពេលពីថ្ងៃទី ១ កក្កដា ២០០៥ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៦។[៧១]

នៅឆ្នាំ២០០៦ ក្រសួងអប់រំយុវជននិងកីឡា មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា កាកបាទក្រហម កម្ពុជាអង្គការ HALO Trust ក្រុមប្រឹក្សាយោបល់ស្តីពីគ្រាប់មីន (MAG) និងអង្គការទស្សនៈពិភពលោកបន្តផ្តល់ នូវការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីន។ ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយគ្រាប់មីននៅកម្ពុជា (CMVIS) អង្គការ Spirit of Soccer ដែលមានទីតាំងនៅប្រទេសអង់គ្លេសបានចាប់ផ្តើមផ្តល់ការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីននៅឆ្នាំ ២០០៦។ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ( UNICEF )បន្តការឧបត្ថម្ភផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីនភាគច្រើនត្រូវបានធ្វើឡើងនៅខេត្តប៉ែកពាយព្យនៃប្រទេស ដែលមានចំនួនជនរងគ្រោះបន្តកើតមានបើទោះជានៅក្នុងកំរិតទាបជាងមុនក៏ដោយ។[៧២]

សមត្ថភាពលើការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីនដ៏ទូលំទូលាយ ដែលមានស្រាប់របស់កម្ពុជាបានកើនឡើងនៅឆ្នាំ ២០០៦។ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាមានបុគ្គលិក៦២រូប រួមជាមួយអ្នកស្ម័គ្រចិត្តដែលធ្វើការនៅតាមបណ្តាញអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីនដែលតាំងនៅតាមសហគមន៍ចំនួន ៤៣៤ បណ្តាញ និងបណ្តាញកាត់បន្ថយគ្រោះថ្នាក់ដោយគ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ចំនួន១៦៩បណ្តាញ។[៧៣] កាកបាទក្រហមកម្ពុជាមានបុគ្គលិកស្ម័គ្រចិត្តចំនួន ៥០០នាក់ និងយុវជនស្ម័គ្រចិត្តចំនួន១០៥០នាក់។[៧៤] ប្រព័ន្ធពតិមានជនរងគ្រោះដោយគ្រាប់មីននៅកម្ពុជា (CMVIS) មានបុគ្គលិក១៥ រូបដែលធ្វើការបណ្តុះបណ្តាលពីការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីន។[៧៥] នៅតាមសាលារៀនមានគ្រូបង្រៀនចំនួន៦០០០រូប ដែលអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីនដល់ សិស្ស ១៩០៤១នាក់ ក្នុងនាមជា"គ្រូបង្គោល" សំរាប់សិស្សដែលបោះបង់ចោលការសិក្សា និងឪពុកម្តាយរបស់គេ។[៧៦] ក្នុងឆ្នាំ ២០០៦ គ្រូបង្រៀនបឋមសិក្សាចំនួន ៣៨ ៨៤១នាក់បានទទួលការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រសំរាប់កុមារលើការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីន។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់អ្នកឯកទេសផ្នែកអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីន ២៥ រូបផ្សេងទៀតៈអង្គការ MAG (១៨ នាក់) អង្គការទស្សនៈ ពិភពលោក (World Vision)

---

[៧១] CCW Amended Protocol II Article 13 Report, Form A, March 2007.

[៧២] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 32.

[៧៣] CMAC, "Annual Report: January-December 2006," Phnom Penh, 2007, pp. 8-12.

[៧៤] CRC, "Community Based Landmine/UXO risk Education program, Annual Report 2006," March 2007, p. 14.

[៧៥] Email from Dos Sovathana, MRE Project Manager, CMVIS, 19 July 2007.

[៧៦] CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 1.

(៤ នាក់) និងអង្គការ HALO (៣នាក់ ) ។[៧៧]

ទោះបីជាសមត្ថភាពកើនឡើងក៏ដោយក៏ចំនួន ៦៤៩,៦៧៩ នាក់ ដែលទទួលការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅឆ្នាំ ២០០៦ មានចំនួនតិចជាងឆ្នាំ ២០០៥ (៧៨១,៨៨៩ ) ។ យ៉ាងណាក៏ចំនួននេះ ក៏ជាចំនួនច្រើន។[៧៨] ការធ្លាក់ចុះនៃចំនួននេះ បណ្តាលមកពីការដែលអ្នកផ្តល់ការបណ្តុះបណ្តាលនោះមានទិសដៅចំពោះក្រុមដែលរងគ្រោះច្រើនជាងតាមរយៈការបញ្ជ្រាបការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីន ចូលទៅក្នុងសកម្មភាពបណ្តុះបណ្តាលនៅតាមសហគមន៍និងការរកប្រាក់ចំនូលខ្នាតតូច។ បែបនេះធ្វើអោយមានការយកចិត្តទុកដាក់តិចជាងមុនទៅលើក្រុមជនទូទៅ។[៧៩] វិធីសាស្រ្តដែលប្រើរួមមានការបង្ហាញនៅតាមភូមិដែលរងគ្រោះដោយសារគ្រាប់មីនការដែលអ្នកស្ម័គ្រចិត្តចែកចាយពតិមាន ស្តីពីការអប់រំពីការគ្រោះថ្នាក់ដោយគ្រាប់មីនដល់មិត្តភ័ក្តិរបស់គេ តាមរយៈការតាំងលើផ្ទាំងប្រកាសការផ្សព្វផ្សាយតាមទូរទស្សន៍ ការបង្រៀនមេរៀននៅបឋមសិក្សា និងការចុះជួបផ្ទាល់ជាមួយកុមារដែលបោះបង់ចោលការសិក្សា។ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) ក៏បានរាយការណ៍អំពីការ ប្រឹក្សាយោបល់ដល់ក្រុមអ្នកប្រឈមនឹងគ្រោះថ្នាក់បំផុតក្នុងគោលបំណងធ្វើអោយពួកគេផ្លាស់ប្តូរអាកប្បកិរិយា ដែលគ្រោះថ្នាក់។[៨០]

នៅខែតុលាឆ្នាំ២០០៦ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជាបានបង្កើតគំរោងថ្មីមួយឈ្មោះថា **កាត់បន្ថយគ្រោះថ្នាក់ដោយគ្រាប់មិនទាន់ផ្ទុះតាមរយៈអ្នកទិញអេតចាយ** (URSMD) ដែលត្រូវដាក់សាកល្បងក្នុងរយៈពេល៦ខែ នៅក្នុងស្រុករងគ្រោះចំនួន២ និងត្រូវធ្វើការវាយតំលៃនៅខែកក្កដាឆ្នាំ២០០៧ ក្រោមការគាំទ្រពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) ។[៨១]

តាំងពីខែធ្នូឆ្នាំ២០០៣ អាជ្ញាធរសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះដោយសារមីនកម្ពុជា ទទួលខុសត្រូវក្នុងការសម្របសម្រួលសកម្មភាពការអប់រំ ពីការគ្រោះថ្នាក់ដោយគ្រាប់មីនដោយទទួលការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ។ អាជ្ញាធរសកម្មភាពកំចាត់មីននិងសង្គ្រោះជនរងគ្រោះកម្ពុជាបានពង្រឹងតួនាទីសម្របសម្រួលរបស់ខ្លួននៅឆ្នាំ ២០០៦ តាមរយៈការជួបប្រជុំជាទៀងទាត់ជាមួយស្ថាប័នរដ្ឋាភិបាលអ្នកដោះមីននិងដៃគូអភិវឌ្ឍន៍។ ការប្រជុំផ្តោតលើការលើកកំពស់ការធ្វើ ផែនការកំចាត់មីននៅតាមខេត្ត។[៨២]

ផែនការយុទ្ធសាស្រ្តអប់រំពីគ្រោះថ្នាក់គ្រាប់មីននៅកម្ពុជា ត្រូវបានកែសម្រួលនៅត្រីមាសទីមួយនៃឆ្នាំ២០០៦។ យុទ្ធសាស្រ្តអប់រំពីគ្រោះថ្នាក់គ្រាប់មីនថ្មីពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០១២ មានគោលបំណងកាត់បន្ថយចំនួនអ្នករងគ្រោះដោយការផ្តល់អំណាចដល់សហគមន៍ដែលរងគ្រោះ ដើម្បីធ្វើការកំនត់បង្ហាញនៅគោលវិធីអប់រំ/កាត់បន្ថយគ្រោះថ្នាក់ដែលសមស្រប និង មានប្រសិទ្ធភាព និងដោយការបញ្ជ្រាបការប្រឹងប្រែងទាំងនេះទៅក្នុងសកម្មភាពមនុស្សធម៌ និង

[77] Mine Action Support Group (MASG), "Newsletter-First Quarter of 2006," Washington, DC, 1 May 2006, p. 22.
[78] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 34.
[79] Emails from Plong Chhaya, Assistant Project Officer, Accidents, Injuries and Disabilities, UNICEF, 16 July 2007; email from Chan Monty, Project Manager, World Vision Cambodia, 17 July 2007.
[80] CMAC, "Annual Report: January-December 2006," Phnom Penh, 2007, p. 12; CMAC, "Integrated Work Plan 2007," Phnom Penh, p. 42-43.
[81] CMAC, "Annual Report: January-December 2006," Phnom Penh, 2007, p. 12; CMAC, "Integrated Work Plan 2007," Phnom Penh, p. 42-43; email from Plong Chhaya, UNICEF, 7 August 2007.
[82] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, pp. 1, 32-34; email from Plong Chhaya, UNICEF, 16 July 2007; see *Landmine Monitor Report 2006,* p. 259.

អភិវឌ្ឍន៍ដែលទូលំទូលាយជាងមុន។ ក្រុមការងារបច្ចេកទេសសំរាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន (MRE) បានជួបគ្នា២ដងនៅឆ្នាំ២០០៦ និងកែសម្រួលឯកសារអោយស្របតាមពេលវេលា ជាពិសេសកម្មវិធី សិក្សាធិការ។[៨៣]

នៅឆ្នាំ២០០៦ ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយគ្រាប់មីននៅកម្ពុជា បានផ្តោតការយកចិត្តទុកដាក់នៅតាមសហគមន៍ដែលមានឧប្បត្តិហេតុថ្មីៗកើតឡើង និងផ្តោតការយកចិត្តទុកដាក់ដោយការអនុវត្តន៍ជាមួយអ្នកដោះមីន ដែលបានស្នើរអោយមានការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅតាមតំបន់ដែលមានគ្រោះថ្នាក់ខ្លាំង។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ស៊ីម៉ាក់ បានបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យចំនួន១៥នាក់ អ្នកស្ម័គ្រចិត្ត៩នាក់ និងបុគ្គលិកគ្រប់គ្រងទិន្នន័យ៤នាក់។ CMVIS បានចាប់ផ្តើមធ្វើសកម្មភាព សំរាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅខែ មករា ឆ្នាំ ២០០៦។ ទន្ទឹមនឹងការផ្តល់នូវការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដល់មនុស្សចំនួន ៩៧១៩ នាក់ អ្នកប្រមូលទិន្នន័យ CMVIS និងអ្នកស្ម័គ្រចិត្ត បានបង្កើតក្រុមមិត្តអប់រំមិត្ត។[៨៤]

នៅខែ មិថុនា ឆ្នាំ២០០៦ អង្គការ Spirit of Soccer បានចាប់ផ្តើមធ្វើការអប់រំពី គ្រោះថ្នាក់ដោយគ្រាប់មីននៅខេត្ត បាត់ដំបងដល់សិស្ស ១៤,៥០៨ នាក់ (សិស្សប្រុស ៨២២៩ នាក់ និងសិស្សស្រី ៦,២៧៩ នាក់) ដែលមកពីសាលាបឋមសិក្សា ចំនួន ៥៣ សាលា និងមធ្យមសិក្សា ១៧ សាលា តាមរយៈសកម្មភាព កីឡា។[៨៥]

គម្រោងអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅតាមសហគមន៍របស់កាកបាទក្រហមកម្ពុជា ដែលបានបង្កើតឡើងនៅឆ្នាំ ២០០០ បានផ្តល់នូវការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដល់សិស្សចំនួន ៥,១៩៦ នាក់ (១៦,៤០៨ នាក់នៅឆ្នាំ ២០០៥) និង ៦ ៧៨២ នាក់ (២,៦៦៨ នាក់ ក្នុងឆ្នាំ ២០០៥ ) ក្នុងបណ្តាឃុំចំនួន ៣៨ (១៨៣ នៅឆ្នាំ២០០៥) នៅក្នុងខេត្តចំនួន៦នៅឆ្នាំ ២០០៦។[៨៦] អង្គការ MAG បានធ្វើការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់ មីនដល់អ្នកភូមិ ២៩,១៣៦ នាក់ ដែលតិចជាងឆ្នាំ ២០០៥ ប្រមាណ ៥០ ភាគរយ ដែលមានចំនួន ៦៣, ១៨៦ នាក់។ អង្គការទស្សនៈពិភពលោក បានផ្តល់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន ជាផ្នែកមួយសំខាន់នៃសកម្មភាពហេដ្ឋារចនាសម្ព័ន្ធនិងកសិកម្ម របស់ខ្លួននៅតាមស្រុកគោលដៅចំនួន ២ ដែលមាន ១ ក្រុមៗនៅតាមស្រុកនិមួយៗ។ នៅឆ្នាំ ២០០៦ ក្រុមផ្តល់នូវការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដល់អ្នកភូមិចំនួន ៧,៥៣២ នាក់ ដែលនៅតែតិចជាងឆ្នាំ ២០០៥ ចំនួន ៥០ ភាគរយ ដែលមាន ១៤,៤៩២ នាក់។[៨៧] ក្រុមអ្នកអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនរបស់អង្គការ HALO ដែលមានភារកិច្ចធ្វើការ អប់រំពីគ្រោះថ្នាក់ដោយ គ្រាប់មីនក្នុងពេលធ្វើការដោះគ្រាប់មីន បានធ្វើការអប់រំដល់ប្រជាពលរដ្ឋចំនួន ៣៦,២៥១ នាក់នៅក្នុងសហគមន៍ ដែលរងគ្រោះដោយគ្រាប់មីន។ នេះជាចំនួនច្រើនសំបើមជាងកាលពីឆ្នាំ ២០០៥

[៨៣] Ibid, pp. 32-33; Ibid.

[៨៤] Ibid; Ibid, pp. 261-262.

[៨៥] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 36; see also, www.spiritofsoccer.net, accessed 22 July 2007.

[៨៦] CRC, "Community Based Landmine/UXO Risk Education Program Annual Report 2006," March 2007, p. 4.

[៨៧] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 35; emails from Chan Monty, World Vision Cambodia, 17 and 20 July 2007.

ដែលមានចំនួន ២៦ ៧១៥ នាក់ ។[៨៨]

ក្រុមអ្នកធ្វើការ៦ក្រុមមកពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាបានមកដល់ភូមិ ២ឬ៣ ធ្វើការបង្រៀនពីគ្រោះថ្នាក់ដោយគ្រាប់មីនមួយចំនួនតូច និងដល់មនុស្សតិចតួចនៅឆ្នាំ ២០០៦ ប៉ុន្តែមានកំណើនលើរបាយការណ៍ពីចំនួនគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមដែលត្រូវបំផ្លាញ។ ជាសរុបមានការបង្ហាញពីការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនចំនួន ៥២០នាក់ (៨៥៥ នាក់ នៅឆ្នាំ ២០០៥) បានធ្វើការនៅបណ្តាភូមិចំនួន ៥០៧។ ក្រុមនេះបានចុះទៅដល់ ១៣,៣៩៨គ្រួសារ និងបោសសំអាតគ្រាប់មីន ១,៦៥៣គ្រាប់ និង គ្រាប់មិនទាន់ផ្ទុះ ៦,១៥៩គ្រាប់។ ក្រុមអ្នកធ្វើការមកពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាបាន ធ្វើការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដល់អ្នកចូលរួម ចំនួន១៧២,៦២៥ នាក់ នៅឆ្នាំ ២០០៦។[៨៩]

ក្នុងគំរោងកាត់បន្ថយពីគ្រោះថ្នាក់ដោយគ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ក្នុងខេត្ត៤ ដែលប្រឈមមុខខ្លាំងនឹងគ្រាប់មិនទាន់ផ្ទុះ (ខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែងនិងស្វាយរៀង) មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាបង្កើនសកម្មភាពគ្របដណ្តប់ និងផលិតផលនៃកិច្ចសហប្រតិបត្តិការយ៉ាងច្រើនដល់ទៅស្ទើរពីរដងនៃទំហំនៅឆ្នាំ២០០៥។ ជនបង្គោលនៅតាមស្រុកចំនួន ១៦ (១៣ នៅឆ្នាំ ២០០៥) ត្រូវបានពង្រាយនៅឆ្នាំ ២០០៦ ដល់ភូមិគោលដៅចំនួន ២,១៥៤។ ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មិនទាន់ផ្ទុះត្រូវបានផ្តល់ដល់អ្នកភូមិចំនួន១០២,៤៩៣ តាមរយៈការបង្រៀនចំនួន ៣,០៧៨ វគ្គ និងមានចុះទៅជួបគ្រួសារចំនួន២០,៤៥០។ មាន "សកម្មភាព" ២,៣៤០ (១,១៥៦ នៅឆ្នាំ២០០៥) លើការដោះគ្រាប់មីនចំនួន ៩៤២ និងគ្រាប់មិនទាន់ផ្ទុះ ២០,៩៣០ គ្រាប់ដល់ភ្នាក់ងារដោះគ្រាប់មីន។[៩០] នៅឆ្នាំ ២០០៦ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាបានបង្កើនយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់ខ្លួន។[៩១] កាកបាទក្រហមកម្ពុជាបានបង្កើតនិងចែកចាយផ្ទាំងផ្សព្វផ្សាយចំនួន១២។[៩២] មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារបានជួយបង្កើតឯកសារសម្រាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនចំនួន ១៥០,០០០។[៩៣]

ការសិក្សាអំពី "ការធ្លាក់ចុះចំនួនអ្នករងគ្រោះ" យ៉ាងខ្លាំងនៅឆ្នាំ ២០០៦ បានបង្ហាញថា ៤០ភាគរយនៃអ្នកឆ្លើយបានបញ្ជាក់ថា ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនជាកត្តាសំខាន់ទីពីរក្នុងការកាត់បន្ថយចំនួនគ្រោះថ្នាក់ បន្ទាប់ពីការបោសសំអាតគ្រាប់មីន។ គួរអោយកត់សំគាល់នោះគឺស្ថានភាពកាន់តែប្រសើរឡើងក្នុងការកំនត់គោលដៅច្រើនជាងមុនចំពោះអ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងសកម្មភាពដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្លាំង (ជាពិសេសអ្នកទិញអេតចាយ) និងការអោយមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗដូចជានគរបាលជាដើម។ ការសិក្សាបានកត់សំគាល់ថា

---

[៨៨] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 35.

[៨៩] Ibid, p. 34; CMAC, "Annual Report: January-December 2006," Phnom Penh, 2007, pp. 13-14; email from Heng Ratana, CMAC, 19 July 2007.

[៩០] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 34; CMAC, "Annual Report: January-December 2006," Phnom Penh, 2007, pp. 14-16; email from Heng Ratana, CMAC, 19 July 2007.

[៩១] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, p. 34.

[៩២] CRC, "Community Based Landmine/UXO Risk Education program Annual Report 2006," March 2007, p. 5.

[៩៣] Email from Plong Chhaya, UNICEF, 16 July 2007.

មនុស្សមានទំនោរផ្តល់នូវ "ចំលើយដល់អ្នកខាងក្រៅចំពោះសំណួរដែលគេគិតថា" ត្រឹមត្រូវ '..." និងបានបន្ថែមថា កត្តាផ្សេងៗរួមទាំងស្ថានភាពប្រសើរឡើងនៃជីវភាពរស់នៅ និងការទទួលបានដីធ្លីដែលមានជីជាតិ ព្រមទាំងគ្រប់គ្រងអាជីវកម្មទិញដូរអេតចាយជាកត្តាចំបងធ្វើអោយមានការធ្លាក់ចុះអត្រាគ្រោះថ្នាក់។ ការសិក្សាបានផ្តល់នូវអនុសាសន៍អោយមានការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដល់កន្លែងទិញដូរអេតចាយ និងក្រុមប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ និងក្រុមទទួលបានប្រយោជន៍តិចតួចផ្សេងៗទៀត។[៥៤]

ទោះជាយ៉ាងណា ប្រព័ន្ធពតិមានជនរងគ្រោះដោយគ្រាប់មីននៅកម្ពុជា បានបញ្ជាក់ថានៅឆ្នាំ ២០០៦ ចំនួនអ្នកគ្រោះថ្នាក់ដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះជាង៨៧ភាគរយ បានទទួលការអប់រំដោយគ្រាប់មីន មុនពេលជួបឧប្បត្តិហេតុ។ ទោះជាមានតែ១៥ភាគរយ នៃគ្រោះថ្នាក់កើតឡើងនៅតំបន់ដែលសញ្ញាគ្រោះថ្នាក់ ក៏ដោយប្រការសំខាន់នោះគឺត្រូវកត់សំគាល់ថាមានតែតំបន់មានគ្រាប់មីនដែលដាក់សញ្ញាសំគាល់ និងស្ទើរតែ៣៥ភាគរយ នៃគ្រោះថ្នាក់ដោយគ្រាប់មីនកើតឡើងនៅតំបន់ទាំងនេះ។ បុគ្គលភេទប្រុសជាពិសេសបុរសជាអ្នកដែលរងគ្រោះបំផុតក្នុងឧប្បត្តិហេតុទាំងដោយគ្រាប់មីន និង សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម និងជាអ្នកដែលទំនងក្លាយជាអ្នករងគ្រោះយ៉ាងខ្លាំងដោយការប៉ះពាល់គ្រាប់មីន ឬ សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម។[៥៥]

នៅថ្ងៃទី ១៩ ខែធ្នូឆ្នាំ២០០៦ អាជ្ញាធរមីនកម្ពុជាបានរៀបចំសិក្ខាសាលាទូទាំងប្រទេសមួយស្តីពីការកាត់បន្ថយអត្រាគ្រោះថ្នាក់។ អនុសាសន៍រួមមានការហាមឃាត់ពីអជ្ញាធរមូលដ្ឋានមិនឱ្យរុករានដីមុនពេលការបោសសំអាតគ្រាប់មីន ការផ្តោតគោលដៅទៅលើក្រុមអ្នកប្រឈមមុខនឹងគ្រោះថ្នាក់ ការបន្តបណ្តុះបណ្តាលពហុជំនាញដល់ក្រុមអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនដើម្បីធ្វើការដោះមីនភ្លាមៗការបង្កើតបន្ថែមទៀតលើបណ្តាញនៅតាមសហគមន៍ ដើម្បីធ្វើអោយមានការរាយការណ៍ និងការដោះគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមយ៉ាងលឿន ដោយអ្នកដោះមីន និងការបញ្ជ្រាបការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនទៅក្នុងគំរោងអភិវឌ្ឍន៍។[៥៦]

## ចំនួនអ្នករងគ្រោះដោយគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម (ERW)[៥៧]

នៅឆ្នាំ ២០០៦ មានអ្នករងគ្រោះដោយគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ៤៥០នាក់ ថ្មីទៀតនៅប្រទេសកម្ពុជា (ស្លាប់ ៦១ នាក់ និង របួស ៣៨៩ នាក់) ក្នុងឧប្បត្តិហេតុ ២៧២ ករណី។[៥៨]

ការធ្លាក់ចុះបរិមាណស្ទើរ ៥០ ភាគរយបែបនេះចាប់ពីឆ្នាំ ២០០៥ (អ្នករងគ្រោះមាន ៨៧៥ នាក់) បានជំរុញអោយមានការអង្កេតមួយដើម្បីរកមូលហេតុ ដោយហេតុថាអត្រារងគ្រោះចាប់តាំងពីឆ្នាំ ២០០០ មក មានកំរិតថេរ

---

[៥៤] Ruth Bottomley, "A Study on the Dramatic Decrease of Mine/UXO Casualties in 2006 in Cambodia," Phnom Penh, February 2007, pp. 5, 12.

[៥៥] Landmine Monitor analysis of data provided by Cheng Lo, Data Management Officer, CMVIS, Phnom Penh, 4 and 6 July 2007; email from Bruno Leclercq, Director of Programs, HI Belgium, Phnom Penh, 7 August 2007. In 2006, 390 of 450 people had received MRE prior to the incident and 66 casualties (all caused by mines) occurred in marked areas.

[៥៦] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, pp. 32-34.

[៥៧] Unless noted otherwise, information in this section was provided in emails from Cheng Lo, CMVIS, Phnom Penh, 4, 6, 23 and 24 July 2007 (hereinafter CMVIS data).

[៥៨] CMVIS, "Annual Report 2006," Phnom Penh, July 2007, p. 7; see *Landmine Monitor Report 2006*, p. 264.

(ដែលជាមធ្យមមាន ៨៤៦ នាក់ ក្នុងមួយឆ្នាំ) ។ ការអង្កេតដែលធ្វើពីខែ តុលា ដល់ ខែ ធ្នូ ឆ្នាំ ២០០៦ បានរកឃើញថា ការធ្លាក់ចុះនេះជាចំបងបណ្តាលមកពីស្ថានភាពអំណោយផលនៃរដូវកាល ដែលធ្វើអោយការផលិតផ្នែកកសិកម្មមានភាពប្រសើរឡើង និងជាទូទៅបានមកពីឱកាសសំរាប់សកម្មភាពសេដ្ឋកិច្ចមានទូលាយជាងមុនតាមរយៈការធ្វើការងារកសិកម្មនិងសំណង់។ ដោយបែបនេះហើយទើបមានការធ្លាក់ចុះនៃការយកហេតុផលសេដ្ឋកិច្ច សំរាប់សកម្មភាពដែលប្រថុយនឹងគ្រោះថ្នាក់។ ការអង្កេតបានកត់សំគាល់ថាភាពក្រីក្រជា "កត្តាមូលដ្ឋាននាំឱ្យមាន ការកើនឡើងភាពងាយរងគ្រោះដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ"។ ក៏មានការកត់សំគាល់ផងដែរថា កំណើននៃការចូលរួមរបស់សហគមន៍ក្នុងការធ្វើផែនការ និងការដាក់អាទិភាពសកម្មភាពកំចាត់មីន បានឆ្លើយតបទៅនឹងផលប៉ះពាល់លើសេដ្ឋកិច្ចសង្គម ដែលបណ្តាលមកពីការមានបង្កប់គ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ បានប្រកបដោយប្រសិទ្ធភាពជាងមុន។ ជិត៩០ភាគរយ នៃអ្នកឆ្លើយសំណួរក្នុងការអង្កេតបាននិយាយថា អាជីវកម្មអេតចាយលើសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមក្នុងភូមិរបស់គេបានធ្លាក់ចុះ។[៩៩] ទោះជាយ៉ាងណាសមាមាត្រនៃអ្នករងគ្រោះដោយសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមនៅថេរក្នុងចន្លោះឆ្នាំ ២០០១ និង២០០៦ ។[១០០]

សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមជាអ្នកបង្ក ៦០ភាគរយនៃចំនួនរងគ្រោះសរុប ( អ្នករងគ្រោះមាន ២៥៩ នាក់ រួមទាំងគ្រោះថ្នាក់ដោយគ្រាប់រំសេវបុមប៊ីតូចៗចំនួន ២០ នាក់ )នៅឆ្នាំ ២០០៦ ។ ចំណែកឯគ្រាប់មីនបង្កឱ្យមានអ្នករងរបួស១៩១នាក់ (ដោយគ្រាប់មីនប្រឆាំងមនុស្ស: ១១៦ នាក់, ដោយគ្រាប់មីនប្រឆាំងយានយន្ត:៧២ នាក់ និងដោយរំសេវផ្ទុះ fuzes: ៣ នាក់) ។ មនុស្សប្រុសមានចំនួនប្រមាណ ៨៧ ភាគរយ(៣៩៣ នាក់ )នៃអ្នករងគ្រោះ (បុរស: ៦៣ ភាគរយ ឬ ២៨៤ នាក់, កុមារា : ២៤ ភាគរយ ឬ ១០៩ នាក់)។ ការប៉ះពាល់ផ្ទាល់ជាបុព្វហេតុចំបងនៃគ្រោះថ្នាក់ក្នុងចំនោមអ្នករងគ្រោះភេទប្រុស (១១៤ ) - បន្ទាប់មកគឺ "ការមិនធ្វើអ្វីសោះ" ឬ ដោយការឈរនៅក្បែរ (៦៨ ) និងការកាប់/រកអុស (៣៩)។ ស្ត្រីមាន ចំនួន ១៣ ភាគរយ(៥៧នាក់)នៃអ្នករងគ្រោះ។ ចំនួនអ្នករងគ្រោះជាស្ត្រីដែលកើតឡើងពីការប៉ះពាល់ដោយចេតនាជាមួយគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមបានធ្លាក់ចុះជាសន្ទឹមៗពី ៣០ភាគរយ នៅឆ្នាំ២០០១ មកត្រឹម ៥ ភាគរយ (៣ នាក់ )នៅឆ្នាំ ២០០៦។ ប៉ុន្តែអត្រាអ្នករងគ្រោះដែលកើតឡើងដោយការ "មិនធ្វើអ្វីទាល់តែសោះ" ឬ ដោយការឈរនៅក្បែរ បានកើនឡើងយ៉ាងខ្លាំងពី ២០ភាគរយ នៅឆ្នាំ ២០០១ មកត្រឹម ៥១ភាគរយ (២៩នាក់) នៅឆ្នាំ២០០៦។ កុមារមានចំនួន ៣១ភាគរយ (១៤០នាក់)នៃអ្នករងគ្រោះទាំងអស់ហើយគ្រោះថ្នាក់កុមារភាគច្រើនបណ្តាលមកពីសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម (៨៣ភាគរយឬ១១៦នាក់)។ នៅឆ្នាំ ២០០៤ និង ២០០៥ ៨៧ភាគរយ នៃករណីកុមាររងគ្រោះបណ្តាលមកពីសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម។[១០១] នៅឆ្នាំ ២០០៦ ក្នុងចំណោមអ្នករងគ្រោះដោយ គ្រាប់រំសេវកំរងតូចៗ មានកុមារចំនួន ៨៥ ភាគរយ (១៧ ក្នុងចំនោម

---

[៩៩] Ruth Bottomley, "A Study on the Dramatic Decrease of Mine/UXO Casualties in 2006 in Cambodia," February 2007, pp. 5, 12.

[១០០] CMVIS data.

[១០១] See *Landmine Monitor Report 2006,* p. 264.

២០នាក់) ។ អត្រារងគ្រោះដែលជាអ្នកដោះមីនមានចំនួនស្មើរអត្រាក្នុងឆ្នាំ ២០០៥ ដែលមាន២២នាក់ ។ ក្នុងនោះរួមមាន ១៦ នាក់ជាប្រជាជនស៊ីវិល និង ៦ នាក់ជាកងកំលាំងប្រដាប់អាវុធ ។ ទាំងអស់សុទ្ធជាបុរស ។ បន្ថែមលើសនេះទៅទៀត "អ្នកដោះមីនក្រៅក្របខណ្ឌ" ១៣នាក់រងរបួសក្នុងពេលប្រតិបត្តិការដោះមីនបណ្តោះអាសន្ននៅតាមភូមិ ។ អ្នករងគ្រោះទាំងអស់ជាបុរស ។ អត្រាធ្លាក់ចុះនៃអ្នករងគ្រោះ នៅបន្តដល់ឆ្នាំ ២០០៧ ដែលគិតមកត្រឹមខែមិថុនាមានអ្នករងគ្រោះ ២០៨នាក់ (៣៨នាក់ស្លាប់ និង ១៧០នាក់របួស) ។ ក្នុងពេលដដែលនៅឆ្នាំ២០០៦ ចំនួនអ្នករងគ្រោះដែលបានកត់ត្រាទុកមាន ២៤០ នាក់ ។[១០២]

*ការប្រមូលទិន្នន័យ*

ប្រព័ន្ធព័តិមានជនរងគ្រោះដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះកម្ពុជា បានរក្សាទិន្នន័យអ្នករងគ្រោះតាំងពីឆ្នាំ ១៩៩៤ ។ ចំនួនអ្នករងគ្រោះត្រូវបានគេរាយការណ៍តាមរយៈបណ្តាញរបស់បុគ្គលិកនៅតាមមូលដ្ឋានរបស់កាកបាទក្រហមកម្ពុជា រួចត្រូវគេបញ្ចូលទៅក្នុងទិន្នន័យ CMVIS និងវិភាគដោយការឧបត្ថម្ភពីអង្គការជនពិការអន្តរជាតិ ប៊ែលហ្ស៊ិក (HI-B) ។ ទិន្នន័យ CMVIS ត្រូវបានប្រើប្រាស់សំរាប់ការធ្វើផែនការ និងការកំនត់អាទិភាពលើជំនួយដល់អ្នកនៅរស់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន ការងារដោះមីននិងកិច្ចការគ្រាប់មិនទាន់ផ្ទុះ ។ ព័តិមាននេះត្រូវបានគេចែកចាយយ៉ាងទូលំទូលាយជារបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ។[១០៣]

ការប្រមូលទិន្នន័យអ្នករងគ្រោះថ្នាក់មីនថ្នាក់ជាតិនៅប្រទេសកម្ពុជា ត្រូវបានគេចាត់ទុកថាមានភាពលំអិត ទោះបីជាវា "អាចថាមិនគ្រប់ព័តិមានពីអ្នករងគ្រោះទាំងអស់ត្រូវបានរាយការណ៍ដោយកង្វះខាតបរិក្ខាពេទ្យ ភូមិដ្ឋានខ្លះនៅដាច់ឆ្ងាយនិងការរំលោភក្នុងបញ្ហាផ្លូវច្បាប់ ។"[១០៤] ទិន្នន័យអ្នករងគ្រោះថ្នាក់មីន ទើបចាប់ផ្តើមធ្វើការបែងចែកនូវប្រភេទផ្សេងៗនៃអ្នករងគ្រោះពីរប្រភេទផ្សេងៗរបស់សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមនៅខែកញ្ញាឆ្នាំ២០០៦ ។ ជាលទ្ធផលករណីអ្នករងគ្រោះដោយគ្រាប់រំសេវបុមប៊ីតូចៗមិនត្រូវបានកត់ត្រាទុកជាប្រភេទនេះឡើយ ។[១០៥] នៅខែមិនាឆ្នាំ ២០០៦ ការវាយតំលៃពីខាងក្រៅបានកត់សំគាល់ឃើញថាក្នុងពេលដែលទិន្នន័យប្រមូលដោយទិន្នន័យអ្នករងគ្រោះមីនមាន "ភាពត្រឹមត្រូវច្រើននោះ....ទំនុកចិត្ត និងភាពស៊ីគ្នាទៅលើការកំនត់ទីតាំងឧប្បត្តិហេតុកើតឡើង ជាចំនុចដែលត្រូវធ្វើការកែតំរូវច្រើន ។"[១០៦]

គោលបំណងចម្បងនៃការវាយតំលៃ គឺដើម្បីធ្វើការវិភាគទៅលើសមត្ថភាពរបស់ប្រព័ន្ធព័តិមានជនរងគ្រោះថ្នាក់មីនកម្ពុជា ក្នុងការធ្វើប្រតិបត្តិការ ដោយប្រើប្រាស់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការជនពិការអន្តរជាតិដែលមានកំរិត ឬដោយមិនមានការគាំទ្រនេះ ។ មានអនុសាសន៍អោយអង្គការជនពិការអន្តរជាតិអនុវត្ត

[១០២] CMVIS, "Monthly Report: June 2007," Phnom Penh, July 2007, p. 2.

[១០៣] CMVIS, "Annual Report 2006," Phnom Penh, July 2007, p. 6.

[១០៤] Sheree Bailey, "Landmine Victim Assistance in Integrated Mine Action in Cambodia–Final Report," December 2005, p. 6.

[១០៥] HI, "Circle of Impact: The Fatal Footprint of Cluster Munitions on People and Communities," Brussels, May 2007, p. 24.

[១០៦] Elke Hottentot, "CMVIS External Evaluation Report," Phnom Penh, March 2006, p. 1, www.redcross.org.kh, accessed 23 July 2007.

យុទ្ធសាស្ត្រចាកចេញ (Exit Srategy) ដោយធ្វើកំនត់យ៉ាងលំអិតនូវជំហានសំរាប់ការប្រគល់ និងសូចនាករដំណើរការវិវឌ្ឍន៏លើសមត្ថភាពរបស់ទិន្នន័យអ្នករងគ្រោះមីនក្នុងការគ្រប់គ្រងគំរោង និងគួរតែផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព។ អនុសាសន៏សំខាន់មួយទៀតនោះគឺលើកកំពស់កិច្ចសហប្រតិបត្តិការណ៏ និងការសំរបសំរួលជាមួយអ្នកពាក់ពន្ធ័ ដែលផ្តល់ជំនួយដល់អ្នកដែលមានជីវិតរស់។[107] ជាការឆ្លើយតបទិន្នន័យអ្នករងគ្រោះមីន បានធ្វើការពិនិត្យកែប្រែទិសដៅរបស់ខ្លួននៅខែសីហាឆ្នាំ២០០៦។ យុទ្ធសាស្ត្រឆ្នាំ ២០០៧-២០០៩ មានទិសដៅពង្រីកការជួយសង្គ្រោះដល់ជនរងគ្រោះធ្វើការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន និងធានានិរន្តភាព។[១០៨]

មក ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៦ ទិន្នន័យអ្នករងគ្រោះថ្នាក់មីន មានផ្ទុកកំនត់ត្រាអ្នករងគ្រោះដោយសារគ្រាប់មីន/ សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ចំនួន ៦២,៦៩៣ នៅក្នុងប្រទេសកម្ពុជា (ស្លាប់ ១៩,៣៣៧ របួស ៤៣,៣១៦ ដាច់ដៃដាច់ជើង ៨,៩៨៩ ជនស៊ីវិល ៣៦,៩៣៧)។[១០៩]

នៅខែមេសា ឆ្នាំ ២០០៧ ប្រព័ន្ធព័ត៌មានជនរងគ្រោះថ្នាក់មីន បានចាប់ផ្តើមធ្វើការអង្កេតទៅលើអ្នករស់ប្រមាណ ៤,០០០ នាក់ក្នុងរយៈពេលពីឆ្នាំ២០០១-២០០៥ក្នុង១៧ខេត្តក្រុងដើម្បីប្រមូលទិន្នន័យពីជំនួយ ដែលអ្នករស់រានទទួលបាន និងសូចនាករសង្គមសេដ្ឋកិច្ច។[១១០] ទិន្នន័យការអង្កេតនឹងត្រូវយកមកប្រើសំរាប់ការសិក្សាពីជំនួយដល់ជនរងគ្រោះនៅកម្ពុជា និងសំរាប់ការធ្វើផែនការ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យដំបូងដែលទទួលបាន នឹងដំណើរការដោយប្រព័ន្ធព័ត៌មានជនរងគ្រោះថ្នាក់មីន ចង្អុលបង្ហាញថាការបណ្តុះបណ្តាលបន្ថែមគឺចាំបាច់សំរាប់អ្នកប្រមូលទិន្នន័យនិងបែបបទសំរាប់ការអង្កេតត្រូវធ្វើការកែប្រែ។ តាមទិន្នន័យអ្នករងគ្រោះថ្នាក់មីនបានប៉ាន់ប្រមាណពីការចាប់ផ្តើមធ្វើការអង្កេតឡើងវិញ នៅខែ កញ្ញា/តុលា ឆ្នាំ ២០០៦។[១១១]

ពតិមានពីការជួយសង្គ្រោះដែលជនរងគ្រោះដោយគ្រាប់មីន/កាកសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម គឺប្រើដើម្បីចែកចាយជាប្រចាំទៅអោយអ្នកពាក់ពន្ធ័ដោយអាជ្ញាធរមីនកម្ពុជា។ ប៉ុន្តែមានសេចក្តីរាយការណ៏មួយថាលក្ខណៈបែបនេះមិនបានកើតឡើងឡើយ។[១១២]

មានកង្វះខាតព័ត៌មានដែលត្រឹមត្រូវអំពីចំនួនជនពិការនៅកម្ពុជានិងស្ថានភាពរស់នៅរបស់គេ។ ប្រព័ន្ធប្រមូលទិន្នន័យដែលប្រើក្នុងវិស័យស្តារនីតិសម្បទារូបវ័ន្តត្រូវបានគេចាត់ទុកថាមានមិនគ្រប់គ្រាន់។[១១៣] មានសេចក្តីរាយការណ៏ថា

---

[១០៧] Ibid, pp. 1, 28, 37.

[១០៨] CMVIS, "Annual Report 2006," Phnom Penh, July 2007, pp. 3, 5-7.

[១០៩] CMVIS data.

[១១០] Email from Bruno Leclercq, HI Belgium, 16 July 2007; "ERW Survivor Assistance Information Form," Chhiv Lim, CMVIS, 22 March 2007.

[១១១] Email from Bruno Leclercq, HI Belgium, 16 July 2007.

[១១២] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, Annex C, pp. 5-6; see also *Landmine Monitor Report 2006,* pp. 267-268. The annual victim assistance reports, previously compiled by CMAA, were assigned to Disability Action Council without funding support.

[១១៣] Kendra J. Gregson, *et al.*, "Evaluation of the Physical Rehabilitation Sector in Cambodia," Phnom Penh, 27 October 2006, p. i.

ព័ត៌មានអំពីពិការភាពនឹងមិនត្រូវបានបញ្ចូលនៅក្នុងជំរឿន ឆ្នាំ ២០០៨ ក្នុងប្រទេសកម្ពុជាឡើយ ។[១១៤]

## **ការផ្តល់ជំនួយដល់អ្នកដែលមានជីវិតរស់ពីគ្រាប់មីន**

សេវាកម្មផ្តល់ជំនួយដល់អ្នកដែលមានជីវិតរស់ជាច្រើនរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា គឺតាំងនៅតំបន់ទីក្រុង និងមិនបានដល់ជនពិការនៅតំបន់ជនបទអោយបានពេញលេញឡើយ ។ ដោយសមត្ថភាពរបស់រដ្ឋាភិបាលមានកំរិតអង្គការមិនមែនរដ្ឋាភិបាលជាអ្នកផ្តល់ជំនួយភាគច្រើនបំផុតដល់អ្នកមានជីវិតរស់ដោយសហការជាមួយអជ្ញាធរពាក់ព័ន្ធ ។ យោងទៅតាមរបាយការណ៍របស់អាជ្ញាធរមីនកម្ពុជា មានអង្គការ ៤៣ ធ្វើការក្នុងជំនួយដល់អ្នកមានជីវិតរស់ដោយគ្រាប់មីន និងជនពិការដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។[១១៥]

ប្រព័ន្ធគាំពារសុខភាពនៅកម្ពុជាត្រូវបានរៀបចំនៅក្នុងមជ្ឈមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកនិងមន្ទីរពេទ្យនៅថ្នាក់ជាតិ ។ ការថែរក្សាសុខភាពនៅមន្ទីរពេទ្យសាធារណៈជាធម្មតាមិនមែនមិនយកប្រាក់នោះទេ និងតំលៃក្នុងការថែរក្សាសុខភាពបន្តត្រូវបានហាមឃាត់ ។[១១៦] ជំនួយសង្គ្រោះបន្ទាន់មាននៅមជ្ឈមណ្ឌលសុខភាពរដ្ឋ ប៉ុន្តែជនរងរបួសដោយសារគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមជាច្រើន ទាមទារអោយមានការព្យាបាលប្រកបដោយឯកទេសដែលមិនមាននៅតាមមូលដ្ឋាន ។ នៅឆ្នាំ២០០៦ប្រហែលជា ៦០ភាគរយ នៃអ្នករងគ្រោះថ្មីៗទទួលបានការថែរក្សាសុខភាពក្នុងរយៈពេល៣០នាទីក្រោយពេលឧប្បត្តិហេតុកើតឡើង ហើយអត្រាមរណៈបានធ្លាក់ចុះពី១៩ភាគរយ នៅឆ្នាំ ២០០៥ មកប្រហែល១៤ ភាគរយនៅឆ្នាំ ២០០៦ ។[១១៧]

សេវាកម្មស្តារនីតិសម្បទារូបវន្តជាទូទៅត្រូវបានរៀបចំ និងមានគុណភាពល្អ ជាពិសេសសំរាប់ជនពិការដៃជើង ។ ទោះបីជាមានការប៉ាន់ប្រមាណថាមនុស្សពី ៧០,០០០ នាក់ទៅ១៥៣,០០០ នាក់ត្រូវការឧបករណ៍ជំនួយ ហើយពួកគេស្ទើរគ្រប់គ្នា (៨៩ភាគរយ)រស់នៅក្នុងតំបន់ជនបទក៏ដោយ ក៏គេគិតថាភាគច្រើនទទួលបានសេវាកម្មរួចហើយ ។[១១៨] ពុំមានរបាយការណ៍ពីការវិវឌ្ឍន៍លើកញ្ចប់សកម្មភាពបំពេញបន្ថែមសំរាប់សេវាកម្មមន្ទីរពេទ្យ ឆ្នាំ ២០០៥ (២០០៥ Complementary Package of Activities for Hospital Services)ហើយវិស័យស្តារនីតិសម្បទាបន្តពឹងផ្អែកទៅលើជំនួយយ៉ាងច្រើនពីអង្គការអន្តរជាតិ ។[១១៩]

ជំនួយផ្នែកចិត្តសាស្ត្រសង្គមនៅមានកំរិត ។ សេវាកម្មខ្លះត្រូវបានផ្តល់តាមរយៈផ្នែកសុខភាពផ្លូវចិត្តរបស់មន្ទីរពេទ្យបង្អែក ឬ បញ្ជ្រាបទៅក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍ ។ មានកម្មវិធីជាតិសំរាប់សុខភាពផ្លូវចិត្ត តែវាមិនមានដំណើរការល្អដោយកំហិតផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស ។ មានពេទ្យចិត្តសាស្ត្រដែលទទួលការបណ្តុះបណ្តាលតិចតួច

[១១៤] Email from Plong Chhaya, UNICEF, 16 July 2007.

[១១៥] CMAA, “Mine Action Achievements Report 2006,” Phnom Penh, 6 March 2007, p.16.

[១១៦] “Final Report of the Sixth Meeting of States Parties/ Zagreb Progress Report,” Part II, Annex V, Zagreb, 28 November-2 December 2005, pp. 123-124.

[១១៧] CMVIS, “Annual Report 2006,” Phnom Penh, July 2007, p. 17.

[១១៨] Kendra J. Gregson, *et al.*, “Evaluation of the Physical Rehabilitation Sector in Cambodia,” Phnom Penh, 27 October 2006, p. i; email from Denise Coghlan and Nhar Ny, Landmine Monitor researchers, Phnom Penh, 8 August 2007.

[១១៩] Presentation by Long Sothy, Executive Director, Disability Action Council (DAC), Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007; see *Landmine Monitor Report 2006,* p. 268.

និងមាន "តម្រូវការធំធេងអោយ មានមន្ត្រីសង្គមកិច្ចជួយផ្តល់ជំនួយ" ដល់អ្នកដែលរងគ្រោះពីរបួសផ្លូវចិត្ត។[១២០] ទោះជាយ៉ាងណា ចំនួនក្រុមជួយខ្លួនឯងបានកើនឡើង និងជាទូទៅរួមមានអ្នកមានជីវិតរស់។ ក្រុមជួយខ្លួនឯងខ្លះអនុវត្តនៅរាល់គំនិតផ្តួចផ្តើមសំរាប់ជំនួយសេដ្ឋកិច្ច។ ប៉ុន្តែសេវាកម្មសមាហរណកម្មសេដ្ឋកិច្ចនៅតែមានក៏រិតសំរាប់អ្នកមានជីវិតរស់ហើយសេវាកម្មនេះផ្តល់ជាច្រើនដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងជាតិ។[១២១]

ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ទទួលខុសត្រូវលើបញ្ហាពិការភាព និងប្រតិបត្តិការគម្រោងប្រាក់សោធននិវត្តន៍ដល់អតីតមន្ត្រីរាជការ និងទាហានពិការ។ ទោះជាយ៉ាងណា ទឹកប្រាក់មានតិចតួច បើកមិនទៀងទាត់ និង មានការសូកប៉ាន់។[១២២]

ប្រទេសកម្ពុជាមិនមានច្បាប់ការពារសិទ្ធិជនពិការ។ រដ្ឋាភិបាលបន្ទរាំងមិនអោយមនុស្សដែលមានពិការភាព មិនអោយធ្វើគ្រូបង្រៀននៅតាមសាលាសាធារណ ទោះបីជាមានអ្នកខ្លះធ្វើការជាគ្រូបង្រៀនក៏ដោយ។[១២៣] ពង្រាងច្បាប់ការពារ និងលើកកំពស់សិទ្ធិជនពិការត្រូវបានបញ្ជូនទៅកាន់រដ្ឋាភិបាលនៅខែ ធ្នូ ឆ្នាំ២០០៦។[១២៤] ទោះបីជាប្រទេសកម្ពុជាប្រកាសនៅខែមិនាឆ្នាំ២០០៧ ថា នឹងចុះហត្ថលេខាលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការនៅខែមិនា ឆ្នាំ ២០០៧ នេះក៏ដោយក៏មកដល់ខែ មិថុនា ឆ្នាំ ២០០៧ ច្បាប់នេះនៅមិនទាន់បានចុះហត្ថលេខានៅឡើយទេ។[១២៥]

***<u>ការរីកចំរើនក្នុងការបំពេញតាមទិសដៅផ្តល់ជំនួយដល់អ្នកនៅមានជីវិតក្នុងប្រទេសទាំង24</u>***

ប្រទេសកម្ពុជាជារដ្ឋសមាជិកមួយក្នុងចំនោម ២៤ប្រទេស ដែលត្រូវបានសន្និសិទពិនិត្យឡើងវិញលើកទីមួយនៅណៃរ៉ូប៊ី (Nairobi) ក្នុងខែ វិច្ឆិកា-ធ្នូ ឆ្នាំ២០០៤ ចង្អុលបង្ហាញថាជាប្រទេសដែលមានអ្នកមានជីវិតរស់ក្នុងគ្រោះថ្នាក់ដោយគ្រាប់មីនច្រើនជាងគេ និង "មានការទទួលខុសត្រូវធំបំផុតក្នុងការធ្វើសកម្មភាពកំចាត់មីន ប៉ុន្តែក៏ជាប្រទេសដែលមានតំរូវការនិងការរំពឹងរកជំនួយច្រើនបំផុតផងដែរ" ដើម្បីផ្តល់សេវារកម្មគ្រប់គ្រាន់សំរាប់ការ គាំពារស្តារនីតិសម្បទា និងសមាហរណកម្មអ្នកមានជីវិតរស់។[១២៦]

ជាផ្នែកនៃការប្តេជ្ញាចិត្តអនុវត្តតាមផែនការសកម្មភាពក្រុងណៃរ៉ូប៊ី ( the Nairobi Action Plan) ប្រទេសកម្ពុជាបានរៀបចំទិសដៅឆ្នាំ ២០០៥-២០០៩ សំរាប់ការកិច្ចប្រជុំលើកទី៦របស់រដ្ឋសមាជិកនៅឆ្នាំ២០០៥ (the Nairobi Action Plan)។[១២៧] នៅខែ មេសា ឆ្នាំ ២០០៧ កិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍របស់កម្ពុជា បានបង្ហាញសេចក្តី

---

[១២០] NGO Forum on Cambodia, "NGO Position Papers on Cambodia's Development in 2006…," Phnom Penh, June 2007, p. 89.

[១២១] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, pp.16-17.

[១២២] See *Landmine Monitor Report 2006*, p. 272.

[១២៣] US Department of State, "Country Reports on Human Rights Practices-2006: Cambodia," Washington, DC, 6 March 2007; email from Denise Coghlan and Nhar Ny, Landmine Monitor researchers, Phnom Penh, 8 August 2007.

[១២៤] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, p.18; Presentation by Long Sothy, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007.

[១២៥] Deputy Prime Minister Sok An, public address, Phnom Penh, 14 March 2007.

[១២៦] UN, "Final Report, First Review Conference," Nairobi, 29 November-3 December 2004, APLC/CONF/2004/5, 9 February 2005, p. 99.

[១២៧] "Final Report of the Sixth Meeting of States Parties/ Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 122-128.

លំអិតអំពីដំណើរការខ្លះ ដែលបានធ្វើឡើងដើម្បីសំរេចបានតាមទិសដៅ ។[១២៨] ទោះជាយ៉ាងណា ទិសដៅជាច្រើនមិនមានក្របខណ្ឌពេលវេលាច្បាស់លាស់ ទោះបីជាការវាយតំលៃបានលើកឡើងនូវអនុសាសន៍សំរាប់ការលើកកំពស់ការងារក៏ដោយ ។ ប្រទេសកម្ពុជាពុំតាមដានសកម្មភាពជួយសង្គ្រោះដល់អ្នកមានជីវិតរស់របស់ខ្លួនឡើយ ហើយពុំមានសូចនាករសំរាប់ការតាមដានណាត្រូវបានគេបង្កើតឡើងឡើយ ។[១២៩]

ប្រទេសកម្ពុជាបានទទួលស្គាល់ថាខ្លួនមិនបានធ្វើការគ្រប់គ្រាន់ដើម្បីជួយដល់អ្នកដែលមានជីវិតរស់ឡើយ ។[១៣០] ផែនការការងារឆ្នាំ ២០០៧ របស់អាជ្ញាធរមីនកម្ពុជា មានបញ្ញត្តិតិចតួចដែលសំដៅជាពិសេសសំរាប់ការជួយសង្គ្រោះដល់អ្នកដែលមានជីវិតរស់ ។[១៣១]

ប្រទេសកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍ពីការជួយសង្គ្រោះជនរងគ្រោះនៅក្នុងកិច្ចប្រជុំទី៧របស់រដ្ឋសមាជិកនៅខែកញ្ញា ឆ្នាំ ២០០៦ និងនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍នៅខែមេសា ឆ្នាំ ២០០៧។ អ្នកឯកទេសផ្នែកជួយសង្គ្រោះដល់ជនរងគ្រោះត្រូវបានគេបញ្ចូលទៅក្នុងគណប្រតិភូទាំងពីរ ។[១៣២] ប្រទេសកម្ពុជាបានទទួលការជួយជ្រុំជ្រែងពីអ្នកឯកទេសជួយសង្គ្រោះជនរងគ្រោះនៃក្រុមគាំទ្រការអនុវត្តន៍សន្ធិសញ្ញាលុបបំបាត់គ្រាប់មីន (ISU)) នៅឆ្នាំ ២០០៦ និង ២០០៧ និងបានស្នើរសុំឱ្យមានការគាំទ្របន្ថែមទៀត ។[១៣៣]

### ការវិវឌ្ឍក្នុងការអនុវត្តទិសដៅជួយសង្គ្រោះជនរងគ្រោះថ្នាក់មីនក្នុងផែនការសកម្មភាពណៃរ៉ូប៊ីរបស់កម្ពុជា[១៣៤]

| សេវាកម្ម | ទិសដៅ | ក្របខណ្ឌពេលវេលា | ការងារប្រគល់អោយធ្វើ | ផែនការដើម្បីសំរេចទិសដៅ | សកម្មភាពនៅឆ្នាំ ២០០៦-២០០៧ |
|---|---|---|---|---|---|
| ការប្រមូលទិន្នន័យ | រក្សាការអង្កេតលើជនរងគ្រោះ និងបណ្តាញបញ្ជូនបន្ត | មិនមាន | ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ (CMVIS) | មិនមាន | បន្តការអង្កេត-ការវាយតំលៃពីខាងក្រៅ |

[១២៨] Presentation by Long Sothy, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007.

[១២៩] NGO Forum on Cambodia, "NGO Position Papers on Cambodia's Development in 2006…," Phnom Penh, June 2007, p. 58.

[១៣០] Statement by Cambodia, Seventh Meeting of States Parties, Geneva, 19 September 2006.

[១៣១] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, Annex D.

[១៣២] Statement by Cambodia, Seventh Meeting of States Parties, Geneva, 19 September 2006; Presentation by Long Sothy, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007.

[១៣៣] Email from Sheree Bailey, Victim Assistance Specialist, ISU, GICHD, 12 June 2006.

[១៣៤] "Final Report of the Sixth Meeting of States Parties/ Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 122-128; statement by Cambodia, Seventh Meeting of States Parties, Geneva, 19 September 2006; presentation by Long Sothy, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007; co-chairs of the Standing Committee on Victim Assistance and Socio-Economic Reintegration, "Status of the development of *SMART* victim assistance objectives and national plans," Geneva, 23 April 2007, pp. 20-21.

| សេវាកម្ម | ទិសដៅ | ក្របខណ្ឌពេលវេលា | ការងារប្រគល់អោយធ្វើ | ផែនការដើម្បីសំរេចទិសដៅ | សកម្មភាពនៅឆ្នាំ ២០០៦-២០០៧ |
|---|---|---|---|---|---|
| | វិភាគ/ចែកចាយទិន្នន័យជនរងគ្រោះ | មិនមាន | ប្រព័ន្ធពត៌មានជនរងគ្រោះដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ (CMVIS) | មិនមាន | បន្តការវិភាគ និងការផ្សព្វផ្សាយ |
| | ការអភិវឌ្ឍសមត្ថភាពកាកបាទក្រហមកម្ពុជា | មិនមាន | បព័ន្ធពត៌មានជនរងគ្រោះដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះកម្ពុជា (CMVIS) អង្គការ ជនពិការអន្តរជាតិប៊ែលហ្សិក | មិនមាន | ការវាយតំលៃត្រូវបានធ្វើនៅឆ្នាំ ២០០៧ យុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០០៩ ត្រូវបានបង្កើតឡើង |
| | តាមដានការជួយសង្គ្រោះអ្នកមានជីវិតរស់នៅក្នុងខេត្តរងគ្រោះដោយគ្រាប់មីន | ចុងឆ្នាំ ២០០៦ | អង្គការ JS, ប្រព័ន្ធពត៌មានជនរងគ្រោះដោយគ្រាប់មីន/ គ្រាប់មិនទាន់ផ្ទុះ (CMVIS) | មិនមាន | ការអង្កេតរបស់អង្គការ JS នៅខេត្តពីរ នៅឆ្នាំ ២០០៦ការអង្កេតរបស់ប្រព័ន្ធពត៌មានជនរងគ្រោះដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះបានចាប់ផ្តើមនៅ ខែមេសា ២០០៧ |
| ការថែទាំសុខភាពបន្ទាន់ និងបន្តរ | បង្កើតគោលការណ៍ណែនាំ និងយុទ្ធសាស្ត្រ | មិនមាន | មិនមាន | មិនមាន | ការវាយតំលៃ និងអនុសាសន៍ត្រូវបានបញ្ចប់ |
| | គោលនយោបាយ និងផែនការយុវនិតិសម្បទាសុខភាព | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ពីការវិវឌ្ឍន៍ |
| | ចែករំលែកព័ត៌មាន | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ពីការវិវឌ្ឍន៍ |
| | បង្កើតផែនការសំរាប់ ការព្យាបាលនៅមន្ទីរ ពេទ្យដោយមិនគិតថ្លៃ សំរាប់ជនរងគ្រោះដោយគ្រាប់មីន និងតាមដានការអនុវត្ត | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ពីការវិវឌ្ឍន៍ |

| សេវាកម្ម | ទិសដៅ | ក្របខណ្ឌពេលវេលា | ការងារប្រគល់អោយធ្វើ | ផែនការដើម្បីសំរេចទិសដៅ | សកម្មភាពនៅឆ្នាំ ២០០៦-២០០៧ |
|---|---|---|---|---|---|
| ស្ដានីតិសម្បទារូបវ័ន្ត | លើកកំពស់បទដ្ឋាន និងគុណភាពសេវាកម្មមជ្ឈមណ្ឌលស្តារនីតិសម្បទារូបវ័ន្ត (PRC) | មិនមាន | មិនមាន | មិនមាន | ការវាយតំលៃ និងអនុសាសន៍ត្រូវបានបញ្ចប់ |
| | ការបែងចែកមានសកម្មភាពជាអតិប្បរមាទៅលើសេវាកម្មស្តានីតិសម្បទារូបវ័ន្ត | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍន៍ |
| ការគាំទ្រផ្នែកចិត្តសាស្ត្រ និងសមាហរណកម្មសង្គម | ផែនការ និងគោលការណ៍ណែនាំសំរាប់ការអនុវត្តល្អប្រពៃ | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍន៍ |
| សមាហរណកម្មសេដ្ឋកិច្ច | ការកសាងសមត្ថភាពសំរាប់ជនពិការ និងគ្រួសាររបស់គេ, ការចូលរួមពេញលេញរបស់ជនពិការនៅក្នុង ការអភិវឌ្ឍ | មិនមាន | មិនមាន | មិនមាន | ក្រុមជួយខ្លួនឯងមាន ៤៣៥ ក្រុមត្រូវបានបង្កើតឡើងដោយមានអ្នកនៅមានជីវិតរស់ ចំនួន ៣៣៣៥ នាក់ ចូលរួម |
| | ឱកាសរកប្រាក់ចំនូលសំរាប់ជនពិការ | មិនមាន | មិនមាន | មិនមាន | របាយការណ៍ពីការវិវឌ្ឍន៍មានកំរិត |
| | កំនត់បង្ហាញជំនាញ/សេវាកម្មសំរាប់ជនពិការ | មិនមាន | មិនមាន | មិនមាន | របាយការណ៍ពីការវិវឌ្ឍន៍មានកំរិត |
| | ជួយកូនជនពិការអោយទទួលបានសមធម៌ ប្រកបដោយសក្តានុពលពេញលេញ-សមធម៌ក្នុងសង្គម | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍ |
| | គំរោងសហគមន៍ពេញលេញ-ការថែទាំពិសេសសំរាប់កុមារដែលពិការធ្ងន់ធ្ងរ | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍន៍ |

| សេវាកម្ម | ទិសដៅ | ក្របខណ្ឌពេលវេលា | ការងារប្រគល់អោយធ្វើ | ផែនការដើម្បីសំរេចទិសដៅ | សកម្មភាពនៅឆ្នាំ ២០០៦-២០០៧ |
|---|---|---|---|---|---|
| ច្បាប់ និងគោលនយោបាយសាធារណៈ | ពង្រាងច្បាប់ការពារសិទ្ធិជនពិការ | មិនមាន | មិនមាន | មិនមាន | ពង្រាងច្បាប់ត្រូវបានបញ្ជូនសុំការអនុម័ត |
| | ពិនិត្យឡើងវិញ លើច្បាប់ដែលមាន ដើម្បីកំនត់ពីការរើសអើងលើជនពិការ | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍន៍ |
| | លើកកំពស់ការយល់ដឹងសិទ្ធ និងតំរូវការរបស់ជនពិការ | មិនមាន | មិនមាន | មិនមាន | ពុំមានរបាយការណ៍ ពីការវិវឌ្ឍន៍ |
| | រៀបចំវេទិកាស្តីពីជំនួយដល់ជនរងគ្រោះជាមួយអ្នកមានជីវិតរស់ក្នុងគ្រោះថ្នាក់គ្រាប់មីន។ ក្រសួង អង្គការមិនមែនរដ្ឋាភិបាលក្រុមប្រឹក្សាសកម្មភាពជនពិការ ធ្វើផែនការបំពេញតាមទិសដៅផែនការសកម្មភាពក្រុងណៃរូប៊ី។ | ២០០៦ | អាជ្ញាធរសកម្មភាពកំចាត់មីននិងសង្គ្រោះជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (ស.អ.យ) | មិនមាន | វេទិកាស្តីពីជំនួយដល់ជនរងគ្រោះត្រូវបានធ្វើឡើង និងផែនការសកម្មភាពត្រូវបានពង្រាង |

PWD = ជនពិការ; ស.អ.យ= ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា; DAC = ក្រុមប្រឹក្សាសកម្មភាពជនពិការ
CMVIS = ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះកម្ពុជា ;
CMAA = អាជ្ញាធរសកម្មភាពកំចាត់មីន និងសង្គ្រោះជនរងគ្រោះកម្ពុជា; CRC = កាកបាទក្រហមកម្ពុជា ;
HI-B = អង្គការជនពិការអន្តរជាតិ បែលហ្ស៊ិក; JS= អង្គការយេស៊ូតបំរើនៅកម្ពុជា; NAP = ផែនការសកម្ម ភាពណៃរូប៊ី; VA =ជំនួយដល់ជនរងគ្រោះ; PRC =មជ្ឈមណ្ឌលស្តានីតិសម្បទារូបវន្តថ្នាក់ខេត្ត

## *ក្របខណ្ឌយុទ្ធសាស្ត្រសំរាប់ជួយដល់ជនរងគ្រោះ*

អាជ្ញាធរមីន និងសង្គ្រោះជនរងគ្រោះដោយសារមីន ទទួលខុសត្រូវក្នុងការសម្របសម្រួល និងតាមដានការផ្តល់ជំនួយដល់ជនរងគ្រោះ និង បានបង្កើតផែនការយុទ្ធសាស្ត្រសំរាប់ឆ្នាំ ២០០៤-២០០៩។ ទោះជាយ៉ាងណាពុំមានថវិកាសំរាប់ការអនុវត្តយុទ្ធសាស្ត្រឡើយ។ អាជ្ញាធរមីននិងសង្គ្រោះជនរងគ្រោះដោយសារមីនបានផ្ទេរការងារសម្របសម្រួលលើការផ្តល់ជំនួយដល់ជនរងគ្រោះ និងសេវាកម្មបំរើជនពិការ ដែលផ្តល់ដោយអង្គការ ៤៣

នៅក្នុងប្រទេសទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រុមប្រឹក្សាសកម្មភាពសំរាប់ជនពិការ (DAC)។ នាយកដ្ឋានផ្តល់ជំនួយដល់អ្នកមានជីវិតរស់របស់អាជ្ញាធរមីននិងសង្គ្រោះជនរងគ្រោះដោយសារមីនត្រូវបានគេរាយការណ៍ថា "បានធ្វើការយ៉ាងជិតស្និទជាមួយក្រសួង និង ក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីប្រមូលព័ត៌មានលើសេវាកម្មដែលផ្តល់ដល់ជនរងគ្រោះដោយសារគ្រាប់មីន"។ នៅខែធ្នូ២០០៦ អាជ្ញាធរមីននិងសង្គ្រោះជនរងគ្រោះដោយសារមីន និងក្រសួងនេះ បានបង្កើតគណៈកម្មការអចិន្ត្រៃយ៍ដើម្បីបង្កើត តាមដាន និង វាយតំលៃផែនការយុទ្ធសាស្រ្តថ្មីសំរាប់ជំនួយដល់ជនរងគ្រោះក្នុងរយៈពេលជាង២ឆ្នាំ។ ក្នុងដំណើរការរៀបចំបង្កើតគណៈកម្មការអចិន្ត្រៃយ៍នេះ អាជ្ញាធរមីន និងសង្គ្រោះជនរងគ្រោះកម្ពុជាបានផ្តួចផ្តើមការប្រជុំជាមួយអ្នកពាក់ព័ន្ធ។[១៣៥] ក្រសួងបានប្រគល់ការទទួលខុសត្រូវក្នុងកិច្ចប្រជុំរបស់គណៈកម្មការអចិន្ត្រៃយ៍ទៅអោយអាជ្ញាធរមីនកម្ពុជា។[១៣៦] ទោះជាយ៉ាងណា មានសេចក្តីរាយការណ៍ថាមានការជំទាស់កាន់តែខ្លាំងឡើងចំពោះវិធានការ ដែលប្រើជាពិសេសសំរាប់អ្នកដែលមានជីវិតរស់ក្រោយគ្រោះថ្នាក់មីន និងទន្ទឹមនឹងនេះដែរអ្នកផ្តល់សេវាកម្មសំរាប់ជនពិការចង់បានវិធីសាស្រ្តមេជាង។[១៣៧] អ្នកប្រឹក្សាយោបល់រយៈពេលខ្លីត្រូវបានគេជួលអោយបង្កើតផែនការយុទ្ធសាស្រ្តនៅខែ មិថុនា ឆ្នាំ២០០៧។ ស្ថានប័នអនុវត្តគាំទ្រអនុសញ្ញាលុបបំបាត់មីនក្រុងហ្សឺណែវហៅថា(ISU)ក៏បានផ្តល់ការគាំទ្រផងដែរ។[១៣៨]

ផែនទីផ្លូវការងារ (Road Map) ឆ្នាំ ២០០៧ ដែលជាផែនការការងាររបស់អាជ្ញាធរមីន និងសង្គ្រោះជនពិការកម្ពុជាសំរាប់ឆ្នាំនោះ មានទិសដៅតែ ២ ប៉ុណ្ណោះសំរាប់ការជួយសង្គ្រោះដល់ជនរងគ្រោះ: បង្កើតក្រុមការងារបច្ចេកទេស និងជួយក្នុងការអនុវត្តន៍យន្តការសម្របសម្រួលការផ្តល់ជំនួយដល់ជនរងគ្រោះ។ ទោះបីជានាយកដ្ឋានផ្តល់ជំនួយដល់ជនរងគ្រោះទទួលខុសត្រូវក្នុងការ "ចងក្រងរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាសនិងប្រចាំឆ្នាំដែលទទួលបានពីអង្គការជាតិនិងអន្តរជាតិ ដែលផ្តល់ជំនួយសង្គ្រោះដល់ជនរងគ្រោះដោយគ្រាប់មីន" ក៏ដោយក៏របាយការណ៍ ទាំងនេះមិនមានសំរាប់ឆ្នាំ២០០៥ឬ២០០៦ឡើយ។ ផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន មិនមានបង្ហាញពីគោលដៅដែលជាក់លាក់ឡើយ។[១៣៩] អាជ្ញាធរមីននិងសង្គ្រោះជនរងគ្រោះដោយសារមីនកម្ពុជាមិនបានបង្កើតបទដ្ឋានសំរាប់ផែនការសកម្មភាពកំចាត់មីនសំរាប់ការជួយដល់ជនរងគ្រោះឡើយ។ ផ្នែកមួយរបស់អាជ្ញាធរមីននិងសង្គ្រោះជនរងគ្រោះ ដែលធ្វើការផ្នែករៀបចំផែនការនិងគ្រប់គ្រងទិន្នន័យពុំមានសកម្មភាព ឬ សុចនាករជាក់លាក់សំរាប់ការជួយសង្គ្រោះដល់អ្នកមានជីវិតរស់ឡើយ។ ជាគោលការណ៍ទោះបីជាក្រុមប្រឹក្សាសកម្មភាពជនពិការជាស្ថាប័ននាំមុខគេសំរាប់ការជួយសង្គ្រោះអ្នកមានជីវិតរស់នៅកម្ពុជាក៏ដោយ ក៏ក្រុមការងារ និង គណៈកម្មការមួយចំនួនមិនដំណើរការឡើយ បើគិតមកត្រឹម

---

[១៣៥] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, Annex C, pp. 5-6, presentation by Long Sothy, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 24 April 2007.

[១៣៦] Email from Bruno Leclercq, HI Belgium, 7 August 2007.

[១៣៧] Email from Denise Coghlan and Nhar Ny, Landmine Monitor researchers, 8 August 2007.

[១៣៨] Email from Sheree Bailey, ISU, 12 June 2006.

[១៣៩] CMAA, "Mine Action Achievements Report 2006," 6 March 2007, Phnom Penh, Annex C, Annex D.

ពាក់កណ្តាលឆ្នាំ២០០៧។ ក្នុងនោះរួមមានក្រុមការងារលើកកម្ពស់ការយល់ដឹងពីពិការភាព និងស្តារនីតិសម្បទាសុខភាព និងគណៈកម្មការនិរន្តភាព សហគមន៍ជនពិការ និង ស្ត្រីពិការ ។[១៤០]

យោងទៅតាមអាជ្ញាធរមីន និងសង្គ្រោះជនរងគ្រោះដោយសារមីនកម្ពុជា អ្នកមានជីវិតរស់ក្នុងគ្រោះថ្នាក់គ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ចំនួន ១៩,៣៦៧នាក់ ទទួលបានសេវាកម្មនៅឆ្នាំ២០០៦។ ក្នុងចំណោមចំនួនសរុបនេះ អ្នកនៅមានជីវិតរស់ចំនួន ២,៨៤២ នាក់ទទួលបានសេវាកម្មស្តារនីតិសម្បទារូបវ័ន្ត, ៤៩២នាក់ទទួលបានរទេះពិការ ២,១៩៧នាក់ ទទួលបានការជួសជុលលើឧបករណ៍សិប្បនិម្មិត ឧបករណ៍ចល័ត, ១០,០៧៤ នាក់ទទួលបានការថែរក្សាសុខភាពបន្ត, ១១៧ នាក់ ទទួលបានការដឹកជញ្ជូនទៅព្យាបាល, ២២១នាក់ ទទួលបានជំនួយសេដ្ឋកិច្ចដោយផ្ទាល់, ៣,៣៣៥ នាក់មាននៅក្នុង ក្រុមជួយខ្លួនឯងចំនួន ៤២៥ ក្រុម, ៨៩ នាក់ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងចំណោមអ្នកទាំងនេះមាន ៣៤ នាក់ទទួលបានសេវាកម្មអភិវឌ្ឍន៍មុខរបរ។[១៤១]



ទោះជាយ៉ាងណាយោងទៅតាមព័ត៌មានដែលផ្តល់ដោយអ្នកអនុវត្តន៍និងប្រភពផ្សេងៗទៅអោយក្រុមរបាយការណ៍ **អ្នកត្រួតពិនិត្យមីន** យ៉ាងហោចណាស់ក៏មានជនពិការចំនួន៣៤,១៦៥នាក់ នៅកម្ពុជាទទួលបានសេវាកម្មនៅ កំឡុងឆ្នាំ ២០០៦។ ក្នុងចំនោមអ្នកទាំងនេះមាន ១០,៦៤១ នាក់ជាអ្នកដែលមានជីវិតរស់ក្នុងគ្រោះថ្នាក់គ្រាប់មីន/ សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ដែលរួមទាំង ១៧៤នាក់ ទទួលបានការថែរក្សាសុខភាពបន្ទាន់ ឬបន្ត, ៥,៥០៧នាក់ ទទួលបានការស្តារនីតិសម្បទារូបវ័ន្ត, ៣,៨៩៤ នាក់ទទួលបានការឧបត្ថម្ភផ្នែកចិត្តសាស្ត្រសង្គម, ៨៨០នាក់ ទទួលបានសេវាកម្មសមាហរណកម្មសង្គមសេដ្ឋកិច្ច, ៦៨នាក់ទទួលបានទម្រង់ផ្សេងទៀតនៃជំនួយដោយផ្ទាល់ និង ១១៨នាក់ ត្រូវបានបញ្ជូនអោយទទួលសេវាកម្មផ្សេងទៀត។ ក្នុងចំណោមចំនួនទាំងអស់នេះមន្ទីរពេទ្យ **សង្គ្រោះបន្ទាន់** បានជួយដល់ជនរងគ្រោះដោយគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ១០១នាក់ ថ្មីទៀត ដែលទទួលបានការថែទាំសុខភាពបន្ទាន់ និង៧៣នាក់ ទទួលបានការថែទាំសុខភាពបន្ត។[១៤២] អង្គការ Cambodia Trust បានជួយដល់មនុស្ស ៤,៥៩៦ នាក់អោយទទួលបានសេវាកម្មស្តារនីតិសម្បទា រូបវ័ន្ត

[១៤០] DAC, “Current Activities,” www.dac.org.kh, updated 2 July 2007.

[១៤១] CMAA, “Mine Action Achievements Report 2006,” Phnom Penh, 6 March 2007, p. 17.

[១៤២] Email from Paolo Busoni, Statistician, Emergency, Battambang, 13 July 2007.

(អ្នកមានជីវិតរស់ ១,៤៤៨ នាក់) បានបង្កើតក្រុមជួយខ្លួនឯងថ្មីទៀតចំនួន ៣៩ ក្រុម (អ្នកមានជីវិតរស់មាន ៧៩ នាក់) និងបណ្តុះបណ្តាលដល់អ្នកបច្ចេកទេសធ្វើអវយវៈសិប្បនិម្មិត/គ្រឿងរណប១០នាក់រហូតទទួលបានសញ្ញាប័ត្រ។[១៤៣] អង្គការកាកបាទក្រហមអន្តរជាតិបានជួយដល់មនុស្សចំនួន ៣,៣២៥នាក់ អោយទទួលបានសេវាកម្មស្តារនីតិសម្បទារូបវ័ន្ត (អ្នកមានជីវិតរស់មាន ១,៦៨០ នាក់ ) ក្រុមចុះភូមិបានចុះជួប និង ជួយដល់មនុស្ស ចំនួន៦៤,០០០នាក់និងបានផ្តល់ជំនួយផ្នែកធ្វើចលនានិងការបញ្ជូនបន្តទៅបណ្តុះបណ្តាលដល់អ្នកបច្ចេកទេស៥នាក់។[១៤៤] អង្គការជនពិការអន្តរជាតិប៊ែលហ្សិកបានជួយដល់មនុស្ស៥,២៨៤នាក់ អោយទទួលបានសេវាកម្មស្តារនីតិសម្បទារូបវ័ន្ត (អ្នកមានជីវិតរស់ ២,០៩៦នាក់) និង១២៩នាក់ ទទួលបានសេវាកម្មផ្នែកសេដ្ឋកិច្ច (អ្នកមាន ជីវិតរស់មាន ៣៩នាក់ )។ សេវាកម្មបង្គោលត្រូវបានផ្តល់ដល់មនុស្ស ៣៣៥ នាក់ (មិនមានចំនួនអ្នកនៅមានជីវិតរស់) និងមានការបណ្តុះបណ្តាលដល់អ្នកឯកទេសរោគសរីរសាស្ត្រនិងអ្នកបច្ចេកទេសធ្វើអវយវៈសិប្បនិម្មិត២នាក់។[១៤៥] អង្គការជនពិការអន្តរជាតិបារាំងបានជួយដល់មនុស្ស៨៦០នាក់ ឱ្យទទួលបានសេវាកម្មស្តារនីតិសម្បទារូបវ័ន្ត (អ្នកមានជីវិតរស់ មាន ២២៥នាក់ ) បានផ្តល់ជំនួយដល់អ្នកមានជីវិតរស់ចំនួន ២២១នាក់ ផ្នែកសេដ្ឋកិច្ចបានបង្កើតក្រុមជួយខ្លួនឯង ១ក្រុម (អ្នកមានជីវិតរស់ចំនួន១០នាក់) និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកបច្ចេកទេស ៧នាក់ និងអ្នកឯកទេសរោគសរីរសាស្ត្រ ៤នាក់។[១៤៦] អង្គការអតីតយុទ្ធជនកម្ពុជា (VI) បានជួយដល់មនុស្ស ៤,៩០០ នាក់ ផ្នែកស្តារនីតិសម្បទា, ១៣៣នាក់ ទទួលបានជំនួយសង្គ្រោះផ្នែកសេដ្ឋកិច្ច ឬ ការបណ្តុះបណ្តាលជំនាញ និង បង្កើតក្រុមជួយខ្លួនឯង ៣ ក្រុមថ្មី (អ្នកមាន ជីវិតរស់ចំនួន ២៤ នាក់)។ បន្ថែមលើសនេះទៅទៀតមនុស្ស ១៥២០ នាក់ ត្រូវបានបញ្ជូនទៅទទួលសេវាកម្មដទៃ និងមន្ត្រីផ្នែកស្តានីតិសម្បទា, ៣៤ នាក់ ត្រូវបានបណ្តុះបណ្តាល។[១៤៧]

អង្គការ JS បានផ្តល់ការងារដល់អ្នកនៅមានជីវិតរស់ចំនួន ៥៨ នាក់ ជួយដល់អ្នកមានជីវិតរស់ ១២០នាក់ និងផ្តល់នូវការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមរួមជាមួយការជួយផ្នែកសេដ្ឋកិច្ចដល់អ្នកមានជីវិតរស់ចំនួន៥៥៩នាក់។[១៤៨] អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការខេត្តពោធិសាត់ (DDSP) បានជួយដល់អ្នកមានជីវិតរស់ ៥៨នាក់អោយទទួលបានសេវាកម្មសេវាកម្មស្តារនីតិសម្បទារូបវ័ន្ត និង ១៧០នាក់ អោយទទួល សេវាកម្មសមាហរណកម្មសេដ្ឋកិច្ច។[១៤៩] អង្គការស្តារនីតិសម្បទាសង្គមជនពិការអវយវៈដោយសង្គ្រាមនៅកម្ពុជា (CWARS) បានជួយដល់អ្នកមានជីវិតរស់ចំនួន ១១៨ នាក់ ដោយបានបញ្ជូនទៅអោយទទួលសេវាកម្មស្តារនីតិសម្បទាឬសុខភាព។[១៥០] អង្គការទស្សនៈពិភពលោកកម្ពុជាបានផ្តល់

[១៤៣] Email from Mary Scott, Country Manager, Cambodia Trust, Phnom Penh, 25 May 2007.

[១៤៤] ICRC, “Annual Report 2006,” Geneva, May 2007, p. 209.

[១៤៥] CMAA, “Mine Action Achievements Report 2006,” Phnom Penh, 6 March 2007, p.17; email from Bruno Leclercq, HI-Belgium, 7 August 2007.

[១៤៦] Email from Lucile Papon, Program Director, HI France, Phnom Penh, 19 July 2007.

[១៤៧] Email from Josefina McAndrew, Interim Country Representative, Veterans International Cambodia, Phnom Penh, 6 July 2007.

[១៤៨] Emails from Nhar Ny, Jesuit Service Cambodia, 7 June, 6 and 12 July 2007.

[១៤៩] Email from Pheng Samang, Director, Disability Development Services Pursat, Pursat, 13 July 2007.

[១៥០] Email from Tuoch Narin, Deputy Managing Director, Cambodian War Amputees Rehabilitation Society, Siem Reap, 13 July 2007.

ជំនួយផ្ដែលសេដ្ឋកិច្ចឬការបណ្ដុះបណ្ដាលជំនាញដល់មនុស្សចំនួន ២,៣២១នាក់ (អ្នកមានជីវិតរស់ចំនួន១៥៤នាក់)។[១៥១] អង្គការមូលនិធិស្ដារនីតិសម្បទាពិភពលោក (WRF) បានផ្ដល់ការងារជាលក្ខណៈធ្វើការងាររបស់ខ្លួនឬហាត់ការងារដល់មនុស្សចំនួន ៥៣៧ នាក់ (អ្នកមានជីវិតរស់ចំនួន ៧២ នាក់) និងមនុស្ស ៣៩៥ នាក់ ទទួលការបណ្ដុះបណ្ដាលពេលកំពុងធ្វើការឬការបណ្ដុះបណ្ដាលសំរាប់ការងារដទៃៗ (អ្នកមានជីវិតរស់ចំនួន៤០នាក់)។[១៥២] គំរោងបណ្ដុះបណ្ដាលវិជ្ជាជីវៈសំរាប់ជនពិការរបស់សមាគមន៍ផ្ដល់ជំនួយនិងការសង្គ្រោះ (AAR-VTD) បានផ្ដល់ការ បណ្ដុះបណ្ដាលជំនាញដល់មនុស្ស ៣៧នាក់ (អ្នកមានជីវិតរស់ចំនួន៦នាក់) និង គំរោងរទេះរុញសំរាប់ការអភិវឌ្ឍន៍ របស់សមាគមន៍ផ្ដល់ជំនួយនិងការសង្គ្រោះ (AAR- Wheel Chair for Development Project) បានចែកចាយរទេះរុញចំនួន ២៧២គ្រឿង។[១៥៣] សមាគមន៍ជនពិការភ្នែកកម្ពុជា (The Association of the Blind ) បានជួយដល់មនុស្ស ៧២នាក់តាមរយៈ សកម្មភាពរកប្រាក់ចំណូលនិងបញ្ជូនមនុស្ស១៦៧២នាក់ អោយទទួលសេវាកម្មផ្សេង។[១៥៤] ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយគ្រាប់មីន/ គ្រាប់មិនទាន់ផ្ទុះកម្ពុជាបានផ្ដល់ជំនួយសង្គ្រោះបន្ទាន់និងជំនួយជាគ្រួសារដល់អ្នកមានជីវិតរស់ចំនួន៦៨នាក់។[១៥៥] អង្គការដ៏ទៃទៀតដែលបង្កើតក្រុមជួយខ្លួនឯងសំរាប់ជនពិការមាន អង្គការសកម្មភាពស្ដីពីជនពិការ និងការ អភិវឌ្ឍន៍ (ADD) (២៧៨ ក្រុម —អ្នកមានជីវិតមាន ២,១៣៧នាក់ ) គាំទ្រជនពិការដោយគ្រាប់មីន (Landmine Disability Support) (៨៩ក្រុម —អ្នកមានជីវិតមាន១,០៣៦នាក់ )និង មជ្ឈមណ្ឌលជាតិដើម្បីជនពិការ(១៥ក្រុម-អ្នកមានជីវិតមាន៤៩នាក់)។[១៥៦]



មូលនិធិជួយសង្គ្រោះជនរងគ្រោះដោយគ្រាប់មីន ( Landmine Victim Assistance Fund ) ដែលបានបង្កើតឡើងនៅឆ្នាំ២០០៤ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់អ្នកមានជីវិតរស់ក្នុងគ្រោះថ្នាក់គ្រាប់មីននៅកម្ពុជាសំរាប់ការធ្វើសមាហរណកម្មរូបវ័ន្តសង្គមសេដ្ឋកិច្ចបានទទួលប្រាក់ចំនួន៦៥០,០០០ ដុល្លាអូស្ត្រាលី (៤៨៩,៧៧៥ ដុល្លាអាមេរិក) នៅឆ្នាំ២០០៦ពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី(AusAID)។ មូលនិធិនេះផ្ដល់ការគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន១០ដើម្បីជួយដល់អ្នកមានជីវិតរស់ និងជនពិការ នៅក្នុងសហគមន៍ដែលរងគ្រោះដោយសារគ្រាប់មីន តាមរយៈសេវាកម្មជាច្រើន។[១៥៧]

---

[១៥១] Emails from Chan Monty, World Vision Cambodia, 17 and 20 July 2007.

[១៥២] World Rehabilitation Fund, “Accomplishments for 2006,” 2007, pp. 1-2, www.worldrehabfund.org, accessed 14 July 2007.

[១៥៣] Email from Houy Socheat, Project Director, AAR-VTD, Phnom Penh, 12 July 2007.

[១៥៤] Association of the Blind in Cambodia, *Newsletter*, www.cambodiablindassociation.org, accessed 6 March 2007.

[១៥៥] CMVIS, “Annual Report 2006,” Phnom Penh, July 2007, pp. 7-8.

[១៥៦] CMAA, “Mine Action Achievements Report 2006,” Phnom Penh, 6 March 2007, p.17.

[១៥៧] Statement by Australia, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 27 April 2007. See later for exchange rate.

មកត្រឹមឆ្នាំ២០០៥ មានមជ្ឈមណ្ឌលស្តារនីតិសម្បទារូបវ័ន្ត និង រោងជាងសំរាប់ធ្វើអវយវៈសិប្បនិម្មិតចំនួន ១១ កន្លែងនៅឆ្នាំ ២០០៦ គ្របដណ្តប់គ្រប់ ២៤ ខេត្តក្រុងនៅកម្ពុជា (ការធ្លាក់ចុះពី ១៤ មជ្ឈមណ្ឌលនៅដើមឆ្នាំ ២០០៣ ដែលបណ្តាលជាចំបងមកពីកង្វះខាតថវិកា) ។ ការវាយតំលៃពីនិរន្តភាពរយៈពេលវែងរបស់សេវាកម្មអវយវៈសិប្បនិម្មិត /គ្រឿងរណប ដែលមានធ្វើផែនការសំរាប់ឆ្នាំ ២០០៥ បានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ ២០០៦ និងត្រូវបញ្ចប់នៅខែតុលា ឆ្នាំ២០០៦។ តំរូវការជាបន្តបន្ទាប់របស់អតិថិជន តួនាទីបច្ចុប្បន្ន និងអនាគតរបស់រដ្ឋាភិបាលនិងការធ្លាក់ចុះការគាំទ្ររបស់ម្ចាស់ជំនួយជាបញ្ហាចំបង។ អង្គការអន្តរជាតិចំនួន ៥ : អង្គការកាកបាទក្រហមអន្តរជាតិ (ICRC) អង្គការ កម្ពុជាត្រាស់ (CT) អង្គការជនពិការអន្តរជាតិ (HI-B និង HI-F) និងអង្គការអតីតយុទ្ធជនអន្តរជាតិកម្ពុជា (VI) បានគាំទ្រដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាទាំង ១១ នៅឆ្នាំ២០០៦ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ។ តំលៃក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលគឺអស់ប្រមាណ ៤,៦ លានដុល្លា ក្នុងមួយឆ្នាំ និង កំរិតនៃការផ្តល់មូលនិធិជំនួយបច្ចុប្បន្ន "ចាំបាច់ត្រូវបានប្រសិនបើអោយកំរិតនៃការផ្តល់សេវាកម្មបច្ចុប្បន្នស្ថិតនៅ"។ ទោះជាយ៉ាងណា ការវាយតំលៃមានជំនឿថាការផ្តល់មូលនិធិពីម្ចាស់ជំនួយទំនងជាធ្លាក់ចុះ។[១៥៨] ក្នុងឆ្នាំ២០០៦ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តល់វិភាគទានចំនួន ១០០,០០០ដុល្លា សំរាប់ដំណើរការបន្តរបស់មជ្ឈមណ្ឌលទាំងនេះ។[១៥៩] ការវាយតំលៃបានកត់សម្គាល់ឃើញថា "វិស័យស្តារនីតិសម្បទាមិនមែនជាអាទិភាព(របស់រដ្ឋាភិបាល) នោះទេនិងមូលនិធិរបស់វានឹងមានបន្តពឹងផ្អែកទៅលើជំនួយពីខាងក្រៅក្នុងរយៈពេលមួយយ៉ាងវែង។"[១៦០]

សមាគមន៏ជំនួយសង្គ្រោះជប៉ុន បានធ្វើការគ្រប់គ្រងសេវាកម្មផលិតរទេះរុញសំរាប់ជនពិការ និងគ្រប់គ្រងដំណើរការរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ កៀនឃ្លាំង នៅទីក្រុងភ្នំពេញ ក្នុងរវាងឆ្នាំ ១៩៩៣ ដល់ ២០០៦។ គំរោងនេះត្រូវបានដាក់នៅក្រោមការគ្រប់គ្រងថ្នាក់ជាតិនៅខែតុលា ឆ្នាំ២០០៦ និងត្រូវបានបែងចែកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីរ។ សមាគមន៏ជំនួយសង្គ្រោះជប៉ុន (AAR-Japan) នឹងបញ្ចប់ការគាំទ្រផ្នែកហិរញ្ញវត្ថុទៅអោយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់សមាគមន៏ជំនួយសង្គ្រោះជប៉ុន(AAR-VTD) នៅឆ្នាំសារពើពន្ធ២០០៨។[១៦១]

នៅខែមិថុនា ឆ្នាំ ២០០៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទានិងក្រុមប្រឹក្សាសកម្មភាពជនពិការ បានទទួលការគាំទ្រពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ សំរាប់គំរោងស្តារនីតិសម្បទានៅតាមសហគមន៏ទូទាំងប្រទេស ដើម្បីបំពេញនូវកង្វះខាតក្នុងការផ្តល់សេវាកម្មសំរាប់ជនពិការ ដោយសហការជាមួយអង្គការជនពិការកម្ពុជា (CDPO)។[១៦២] នៅខែមិថុនាឆ្នាំ ២០០៦ គំរោងសាកល្បងមួយបានចាប់ផ្តើមនៅក្នុងខេត្តចំនួន ៨ និងមានផែនការ នឹង

---

[១៥៨] Kendra J. Gregson, *et al.*, "Evaluation of the Physical Rehabilitation Sector in Cambodia," Phnom Penh, 27 October 2006, pp. 16, 76.

[១៥៩] Statement by Cambodia, Seventh Meeting of States Parties, Geneva, 19 September 2006.

[១៦០] Kendra J. Gregson, *et al.*, "Evaluation of the Physical Rehabilitation Sector in Cambodia," Phnom Penh, 27 October 2006, p. 106.

[១៦១] Email from Houy Socheat, AAR-VTD, 12 July 2007.

[១៦២] Email from Plong Chhaya, UNICEF, 5 July 2007; CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, p.17.

បញ្ចប់នៅថ្ងៃទី៣១ខែកក្កដាឆ្នាំ២០០៧។[១៦៣] មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារមានផែនការគាំទ្រដល់ការពង្រីកទូទាំងប្រទេសដែលចាប់ផ្តើមពីខែសីហាឆ្នាំ២០០៧ និងផ្តល់ទីប្រឹក្សាមួយដល់ក្រសួង។ ការបណ្តុះបណ្តាលរបស់រដ្ឋាភិបាល និងភាគីដៃគូអង្គការមិនមែនរដ្ឋាភិបាលត្រូវបានធ្វើឡើង ដោយមានសកម្មភាពលើកកំពស់ការយល់ដឹង។ របាយការណ៍ថ្នាក់ជាតិស្តីពីការជួយសង្គ្រោះជនរងគ្រោះ (កាលពីមុនចងក្រងដោយអាជ្ញាធរមីនកម្ពុជា) បានរៀបចំចប់សព្វគ្រប់។ មកត្រឹមខែកក្កដា ឆ្នាំ២០០៧ របាយការណ៍មិនទាន់បានធ្វើការ អនុម័ត និងបកប្រែជាផ្លូវការនៅឡើយទេ។[១៦៤]

មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារបន្តគាំទ្រ, អង្គការ VI, អង្គការ Opération Enfants du Cambodge, មជ្ឈមណ្ឌលជាតិនៃជនពិការ (NCDP) និង អង្គការកសាងសមត្ថភាពសំរាប់ជនពិការនៅសហគមន៍ (the Capacity Building of People with Disability in Community Organization)។[១៦៥]

កម្មវិធីស្តារនីតិសម្បទានៅតាមសហគមន៍របស់អង្គការជនពិការអន្តរជាតិប៊ែលហ្ស៊ិក (HI Belgium) ត្រូវដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយឈ្មោះCABDICO នៅខែមករា ឆ្នាំ ២០០៦។ កម្មវិធីសំរាប់កុមារនេះផ្តល់នូវការគាំពារសំរាប់ការតាមដានផ្នែកសុខភាព ចិត្តសាស្ត្រសង្គម ការកាត់ បន្ថយភាពក្រីក្រ និងសមាហរណកម្មសង្គមសេដ្ឋកិច្ចសំរាប់ជនពិការតាមរយៈក្រុមជួយខ្លួនឯង និងកម្មវិធីគ្រប់គ្រង ជំនួញខ្នាតតូច។[១៦៦] អង្គការបេសកកម្មដើម្បីការអភិវឌ្ឍន៍ជនពិការនៅកម្ពុជា (CDMD) ដែលជាអង្គការមិនមែនរដ្ឋាភិបាលជាតិមួយទើបបង្កើតថ្មីនៅខែ មករា ឆ្នាំ ២០០៧ បានផ្តល់ការស្តារនីតិសម្បទានៅភ្នំពេញ និងស្រុកចំនួន ៦ នៅខេត្តកណ្តាល តាកែវ កំពត និង កំពង់ស្ពឺ។[១៦៧] អង្គការសុខភាពផ្លូវចិត្ត (TPO) បានធ្វើការផ្តោតទៅលើមនុស្ស ដែលបាក់ស្មារតីដោយសារសង្គ្រាម រួមទាំងអ្នកមានជីវិតរស់នៅក្នុងគ្រោះថ្នាក់ដោយសារគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាមផងដែរ តាមរយៈការបណ្តុះបណ្តាលសុខភាពផ្លូវចិត្តនៅសហគមន៍ការរកប្រាក់ចំនួលនិងសុខភាពផ្លូវចិត្ត។[១៦៨] គំរោងកាត់បន្ថយភាពក្រីក្រតាមរយៈកម្មវិធីមិត្តបណ្តុះបណ្តាលមិត្ត (APPT) ជាគំរោងកាត់បន្ថយភាពក្រីក្រដែលចំណាយអស់ថវិកាតិច និងធ្វើការនៅថ្នាក់មូលដ្ឋានសំរាប់ជនពិការនៅតំបន់ជនបទដោយប្រើប្រាស់វិធីសាស្ត្រមិត្តបណ្តុះបណ្តាលមិត្ត និងការអភិវឌ្ឍន៍ជំនួញខ្នាតតូច។ ស្ថានទូតហ្វាំងឡង់បានពង្រីក ការផ្តល់មូលនិធិ ដល់ គំរោង APPT រហូតដល់ខែមិថុនា ឆ្នាំ ២០០៧ ហើយគំរោងនេះបានទទួលមូលនិធិឧបត្ថម្ភថ្មីពីរដ្ឋនៅឈូងសមុទ្រអារ៉ាប់ (AG Fund) និងអង្គការពលកម្មអន្តរជាតិ។ គំរោងបច្ចុប្បន្នធ្វើការយកចិត្តទុកដាក់ទៅលើស្ត្រីពិការ។[១៦៩]

---

[១៦៣] DAC, "Community Based Rehabilitation Committee," www.dac.org.kh, accessed 12 July 2007.

[១៦៤] Email from Plong Chhaya, UNICEF, 5 July 2007.

[១៦៥] Ibid.

[១៦៦] Telephone interview with Bruno Leclercq, HI, Phnom Penh, 17 July, and email, 7 August 2007.

[១៦៧] Email from San Sothorn, Administration/Finance Coordinator, CDMD, Phnom Penh, 4 May 2007.

[១៦៨] TPO, "Welcome to TPO Cambodia, Company Profile," www.tpocambodia.org, accessed 19 July 2007.

[១៦៩] International Labour Organization, "Overview and Background Paper of APPT in Cambodia," Phnom Penh, April 2007; ILO, "Cambodia: Alleviating Poverty through Peer Training (APPT) Women and Disability," www.ilo.org, accessed 12 July 2007.

មជ្ឈមណ្ឌលជាតិនៃជនពិការ អង្គការ ADD, អង្គការ CT, អង្គការ HI France និងអង្គការគាំទ្រពិការភាពដោយសារគ្រាប់មីនសុទ្ធតែបានបង្កើតក្រុមជួយខ្លួនឯង ដែលមានបញ្ចូលអ្នកមានជីវិតរស់ក្នុងគ្រោះថ្នាក់ដោយសារគ្រាប់មីន/សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម ។[១៧០]

សំរាប់ព័ត៌មានបន្ថែមស្ដីពីអ្នកផ្ដល់ជំនួយសង្គ្រោះដល់អ្នកមានជីវិតរស់នៅកម្ពុជា សូមអានរបាយការណ៍ត្រួតពិនិត្យមីននៅក្នុងការចេញផ្សាយក្នុងឆ្នាំមុន ។[១៧១]

## **ការផ្ដល់មូលនិធិ និងជំនួយសង្គ្រោះ**

ក្នុងឆ្នាំ២០០៦ ជំនួយអន្តរជាតិដែលមានសរុប ២៩,៥៨៣,០៣២ ដុល្លា (`២៣,៥លាន) សំរាប់សកម្មភាពកំចាត់មីននៅកម្ពុជាត្រូវបានគេរាយការណ៍ថាបានមកពីប្រទេសចំនួន ១៣ និង គណៈកម្មការអឺរ៉ុប (EC) ។ ចំនួននេះកើនឡើង២៤% ពីឆ្នាំ២០០៥ (២៣,៩លានដុល្លា ដែលទទួលបានពី១៤ប្រទេស) ។[172] ប្រទេសម្ចាស់ជំនួយដែលផ្ដល់មូលនិធិនៅឆ្នាំ ២០០៦មាន :

ប្រទេសអូស្ត្រាលី:A$៧,៤៣៩,០០០ ($៥,៦០៥,២៨៧) ដែលមាន A$៩៥៥,៧៦៣ ទៅអោយ AUSTCARE សំរាប់សកម្មភាពកំចាត់មីនរួមមួយនៅខេត្តបន្ទាយមានជ័យ, A$៦៣,៤១៥ ទៅកាកបាទក្រហមអូស្ត្រាលីសំរាប់ការជួយសង្គ្រោះដល់ជនរងគ្រោះ, A$៦៩០,៣២២ ទៅអោយអង្គការស្ម័គ្រចិត្តអន្តរជាតិអូស្ត្រាលី (AVI) ទៅសំរាប់ផែនការសកម្មភាពកំចាត់មីន, A$១,៣២៦,៦៦៩ ទៅអង្គការ CARE Australia សំរាប់ សកម្មភាពកំចាត់មីនរួម A$១០០,០០០ ទៅក្រុមប្រឹក្សាយោបល់ស្ដីពីគ្រាប់មីន (MAG) សំរាប់ការអង្កេត A$ ៣ លាន ទៅអង្គការ UNDP សំរាប់គម្រោងបោសំអាតមីនដើម្បីលទ្ធផល A$ ៥៨២,៥៨៨ សំរាប់មូលនិធិជំនួយ ដល់ជនរងគ្រោះដោយគ្រាប់មីន និង A$៧២០,២៤៣ ទៅអង្គការទស្សនះពិភពលោកនិង ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រី អន្តរជាតិសំរាប់សកម្មភាពកំចាត់មីនរួម ។[១៧៣]

ប្រទេសបែលហ្សិក: € ២០០,០០០ ($ ២៥១,២៦០) សំរាប់ជំនួយដល់ជនរងគ្រោះ[១៧៤]

ប្រទេសកាណាដា: C$៣,០៣១,០៤៨ ($ ២,៦៧២,៧៧៨) ដែលរួមមាន C$៣៦,០០០ ទៅអង្គការ UNDP សំរាប់ការបោសសំអាតមីន - C$ ៣៧,៧៤៤ ទៅអោយអង្គការដោះមីនMAG សំរាប់ EOD-C$ ៥០,០០០ សំរាប់សិក្ខាសាលាអាស៊ីអាគ្នេយ៍ C$ ៦១,៤៦១ ទៅអង្គការ Geospatial International (GI) សំរាប់ការបោសសំអាតមីន-C$១,១៣០,៤៤០ ទៅអង្គការ Geospatial International (GI) សំរាប់ការអភិវឌ្ឍន៍កសិកម្មនៅក្នុងតំបន់ដែលរងគ្រោះដោយគ្រាប់មីន - C$ ២០០,៥០៣ ទៅអង្គការ Oxfam សំរាប់ការជួយសង្គ្រោះជនរងគ្រោះ —និង

---

[១៧០] CMAA, "Mine Action Achievements Report 2006," Phnom Penh, 6 March 2007, p.17.

[១៧១] See *Landmine Monitor Report 2006*, pp. 268-272.

[១៧២] Ibid, p. 262. Average exchange rate for 2006: `1 = US$1.2563, used throughout this report. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2007.

[១៧៣] Email from Catherine Gill, Mine Action Coordinator, AUSAID, 10 July 2007. Average exchange rate for 2006: A$1 = US$0.7535. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2007.

[១៧៤] Belgium Article 7 Report, Form J, 30 April 2007.

C$ ១,៥១៤,៩០០ ទៅអង្គការ UNDP សំរាប់ការបោសសំអាតមីន ។[១៧៥]

គណៈកម្មាធិការអឺរ៉ុប : €១ លាន ($១,២៥៦,៣០០) សំរាប់ការបោសសំអាតមីន ។[១៧៦]

ប្រទេសហ្វាំងឡង់:€១,០២០,០០០ ($១,២៨១,៤២៦) ដែលរួមមាន €១០០,០០០ ទៅអង្គកាជនពិការអន្តរជាតិសំរាប់ការបោសសំអាតមីន — €២៥០,០០០ ទៅអង្គការ FinnChurchAid សំរាប់ការបោសសំអាតមីននៅខេត្តបាត់ដំបងនិងសំរាប់ការបោសសំអាតមីន-និង€៦៧០,០០០ទៅអង្គការ HALO សំរាប់ការបោសសំអាតមីន ។[១៧៧]

ប្រទេសបារាំង: €៣៩,៨៨៦ ($៥០,០៥៩) ដែលរួមមាន €២,១៨៦ សំរាប់ការបណ្តុះបណ្តាល និង €៣៧,៧០០ សំរាប់ការជួយសង្គ្រោះ ។[១៧៨]

ប្រទេសអាល្លឺម៉ង់ : €៨៤៦,៨៤៤ ($១,០៦៣,៨៩០) ទៅអាជ្ញាធរមីន/ស៊ីម៉ាក់ សំរាប់ការបោសសំអាតមីននៅខេត្តសៀមរាប និង ឧត្តរមានជ័យ ។[១៧៩]

ប្រទេសអៀរឡង់: €៥០០០០០ ($៦២៨១៥០)ទៅអង្គការ HALO សំរាប់ការបោសសំអាតមីន ។[១៨០]

ប្រទេសជប៉ុន:¥៨៦៣,៨៥៨,៦៦០($៧,៤២៩,១៨៤) ដែលមាន ¥៧,២៨៣,៧០៩ ទៅសេវាកម្មសកម្មភាពកំចាត់មីនរបស់អង្គការសហប្រជាជាតិ (UNMAS )សំរាប់ការបោសសំអាតមីន ¥២០,៤៦២,១៩៩ ទៅអង្គការស៊ីម៉ាក់សំរាប់ការគ្រប់គ្រងសកម្មភាពកំចាត់មីន- ¥៤១,៨៣៧,០០០ ទៅអង្គការស៊ីម៉ាក់សំរាប់ការបោសសំអាត សំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម- ¥ ៥៨,៦៩០,៩១៧ ទៅសេវាកម្មសកម្មភាពកំចាត់មីនជប៉ុន (JMAS) សំរាប់ការបោសសំអាតមីននៅប៉ែកបស្ចឹមប្រទេសកម្ពុជា- ¥៦២,៧៤០,៤១៩ ទៅ JMAS សំរាប់ក្រុមកំទេចគ្រឿងផ្ទុះ (EOD) នៅប៉ែកអាគ្នេយ៍ប្រទេសកម្ពុជា- ¥៦៦,៣៣២,៨៣១ ទៅអង្គការក្រុមប្រឹក្សាយោបល់ស្តីពីគ្រាប់មីន (MAG) សំរាប់សកម្មភាពកំចាត់មីន- ¥៩២,៣២៩,១៣៤ ទៅអង្គការ HALO សំរាប់សកម្មភាពកំចាត់មីននៅប៉ែកពាយ័ព្យប្រទេសកម្ពុជា -¥៩៨,១៨២,៤៥១ ទៅអង្គការស៊ីម៉ាក់ សំរាប់ការបោសសំអាតមីននៅខេត្តបាត់ដំបង និង ¥៤១៦,០០០,០០០ ទៅរដ្ឋាភិបាលកម្ពុជាសំរាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ។[១៨១]

ប្រទេសលុចហ្សែមបួរ: €២៥,១១១ ($៣១,៥៤៧) ផ្តល់ទៅអង្គការជនពិការអន្តរជាតិ (HI) សំរាប់ការកម្មវិធីជួយសង្គ្រោះដល់ជនរស់រានជីវិតពីគ្រោះថ្នាក់មីន ។[១៨២]

---

[១៧៥] Email from Carly Volkes, Program Officer, Foreign Affairs and International Trade Canada, 5 June 2007. Average exchange rate for 2006: C$1 = US$0.8818. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2007.

[១៧៦] "EC Budget line 19 02 04, Community participation to actions relating to antipersonnel mines, Annual Work Plan 2006," Version 15/13/2006; additional data provided by Antoine Gouzée de Harven, EuropeAid Co-operation Office, EC, 23 July 2007.

[១៧៧] Email from Sirpa Loikkanen, Secretary, Ministry of Foreign Affairs, 23 February 2007.

[១៧៨] Email from Anne Villeneuve, Advocacy Officer, HI, Lyon, 12 July 2007.

[១៧៩] Germany Article 7 Report, Form J, 30 April 2007.

[១៨០] Email from Michael Keaveney, Disarmament and Non-Proliferation, Department of Foreign Affairs, 20 July 2007.

[១៨១] Email from Conventional Arms Division, Ministry of Foreign Affairs, 6 June 2007. Average exchange rate for 2006: ¥1 = US$0.0086. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2007.

[១៨២] Email from Michel Leesch, Secrétaire de Légation, Ministry of Foreign Affairs, 24 July 2007.

ប្រទេសហូឡង់: €១,៣៨០,៩១៣ ($១,៧៣៤,៨៤១) ដែលមាន €៧៥០,៩១៣ ទៅអង្គការ HALO សំរាប់កម្មវិធីបោសសំអាតមីននិង ៦៣០,០០០ទៅអង្គការជំនួយរបស់ប្រជាជនន័រវេវ NPA សំរាប់កម្មវិធីការកសាងសមត្ថភាព។[១៨៣]

ប្រទេសអេស្បាញ: €៥៥៧,៣៥៨ ($៧០០,២០៩)ដែលមាន ២៥៧,៣៥៨ សំរាប់កម្មវិធីជួយសង្គ្រោះដល់ជនរងគ្រោះ និង €៣០០,០០០ ទៅអង្គការ UNDP សំរាប់កម្មវិធីការបោសសំអាតមីន។[១៨៤]

ចក្រភពអង់គ្លេស: £៥០៦,៧២៧ ($៩៣៤,១០១)ដែលមាន £ ២៣,៧៧៤ ទៅកម្មវិធីប្រមូលព័ត៌មានជនរងគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះ/UNDP សំរាប់កម្មវិធីជួយសង្គ្រោះដល់ជនរងគ្រោះ, £៩៩,៨៦២ និង £២៦៦,២២០ ទៅអង្គការ MAG សំរាប់កម្មវិធីបោសសំអាតមីន និង £១១៦,៨៧១ ទៅអង្គការ HALO សំរាប់កម្មវិធីបោសសំអាតមីន។[១៨៥]

សហរដ្ឋអាមេរិក: $៥,៩៨៤,០០០ ដែលមាន $៤,៩០០,០០០ ពីក្រសួងការបរទេស, $៩៨,០០០ ពីក្រសួងការពារជាតិនិង $៩៥០,០០០ពីUSAID/មូលនិធិ Leahy សំរាប់កម្មវិធីជនរងគ្រោះដោយសារសង្គ្រាម(USAID/ Leahy War Victims Fund)។[១៨៦]

នៅខែតុលាឆ្នាំ២០០៦ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាបានរាយការណ៍ពីការធ្លាក់ចុះ១/៥ នៃមូលនិធិបើប្រៀបធៀបទៅនឹងឆ្នាំ២០០៥។ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បានរាយការណ៍ថា ថវិកាប្រចាំឆ្នាំមាន ១០ លានដុល្លា ដែលក្នុងនោះ មាន ៩៥% ជាមូលនិធិផ្តល់ដោយអន្តរជាតិ។[១៨៧]

ការពិនិត្យឡើងវិញនៅចុងឆ្នាំ២០០៦ លើផលបត្រ័គំរោងសកម្មភាពកំចាត់មីនកម្ពុជាបានរាយការណ៍ថា ប្រទេសកម្ពុជាបានទទួលប្រាក់ ៤២ភាគរយ ($៩,០៨៧,៧៣៣) នៃមូលនិធិដែលបានស្នើរសុំតាម រយៈដំណើរការអំពាវនាវនៅឆ្នាំ២០០៦។[១៨៨] ផលបត្រ័របស់គំរោងផែនការសកម្មភាពកំចាត់មីននៅឆ្នាំ២០០៧ រួមមានគំរោងចំនួន១៣សំរាប់កម្ពុជាដែលមានសេចក្តីអំពាវនាវសុំថវិកាសំរាប់គំរោងសរុបដែលមានចំនួន $១០,៩៣៧,៦២២ ដែលមកដល់ខែ វិច្ឆិកា ឆ្នាំ ២០០៦ ប្រាក់ចំនួន $១,៧៨០,៣០០ ត្រូវបានផ្តល់ជូន។[១៨៩]

*<u>វិភាគទានជាតិរួមចំណែកសំរាប់សកម្មភាពកំចាត់មីន</u>*

មកដល់រយៈពេល២ឆ្នាំមុន កម្មវិធីសកម្មភាពកំចាត់មីននៅកម្ពុជាដែលមានរយៈពេល ១៥ឆ្នាំ ហើយនោះ

---

[១៨៣] Email from Vincent van Zeijst, Deputy Head, Ministry of Foreign Affairs, 11 July 2007.

[១៨៤] Spain Article 7 Report, Form J, 30 April 2007.

[១៨៥] Email from Andy Willson, Program Officer, Department for International Development, 23 February 2007. Average exchange rate for 2006: £1 = US$1.8434. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2007.

[១៨៦] USG Historical Chart containing data for FY 2006, by email from Angela L. Jeffries, Financial Management Specialist, US Department of State, 20 July 2007.

[១៨៧] "Demining in Cambodia at risk as funding dries up," *Taipei Times*, 15 October 2006, www.taipeitimes.com, accessed 12 June 2007.

[១៨៨] UN, "2006 Portfolio End-Year Review," New York, January 2007, p. 3.

[១៨៩] UN, "2007 Portfolio of Mine Action Projects," New York, List of Projects, pp. 406-423.

បានទទួលមូលនិធិឧបត្ថម្ភស្ទើរតែទាំងស្រុងដោយម្ចាស់ជំនួយបរទេស។ រដ្ឋាភិបាលផ្តល់ប្រាក់ខែដល់បុគ្គលិកបំរើការក្នុងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដែលជាផ្នែកមួយនៃការចូលរួមចំណែកប្រចាំឆ្នាំដល់ការដោះមីនដែលមានទឹកប្រាក់ចំនួន $១,២ លាន នៅឆ្នាំ២០០៦ និង រំពឹងថាកើនឡើងដល់ $១,៤ លានក្នុងឆ្នាំ២០០៧។[190] ទោះជាយ៉ាងណាការបើកប្រាក់របស់រដ្ឋាភិបាលមានភាពយឺតយ៉ាវ ៥ខែ ដែលធ្វើអោយបុគ្គលិកទទួលរងនូវសំពាធផ្នែកហិរញ្ញវត្ថុយ៉ាងច្រើន និងដែលធ្វើអោយមានការបារម្ភថាមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា នឹងមិនអាចរក្សាបុគ្គលិកដែលខ្លួនត្រូវការដើម្បីបំពេញទៅតាមអាណត្តិរបស់ខ្លួន។[១៩១] ប្រទេសកម្ពុជាបានធ្វើបានធ្វើសេចក្តីលំអិតពីវិភាគទានរបស់រដ្ឋាភិបាលក្នុងមាត្រទី៧ដែលមានចំនួនសរុប $១,១៥០,០០០ សំរាប់សកម្មភាពកំចាត់មីននៅឆ្នាំ២០០៦ ដែលរួមមាន "ការបែងចែកប្រាក់ជាប្រចាំ" ចំនួន $៣៥០,០០០ ទៅអោយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា។ រដ្ឋាភិបាលបានផ្តល់ប្រាក់ចំនួន $១៥០,០០០ជាមូលនិធិបន្ថែមទៅមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា, $២៥០,០០០ ទៅអោយអាជ្ញាធរមីនកម្ពុជា, $២៥០,០០០ ទៅកងយុទ្ធពលខេមរៈភូមិន្ទ, $១០០,០០០ ជាជំនួយសង្គ្រោះដល់ជនរងគ្រោះតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, $៣០,០០០ សំរាប់ឧបត្ថម្ភដល់កម្មវិធីគណៈកម្មការសកម្មភាពកំចាត់មីននៅតាមខេត្ត និង $២០,០០០ សំរាប់ឧបត្ថម្ភដល់កម្មវិធីអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន។[១៩២]



[១៩០] Interview with Sam Sotha, CMAA, Phnom Penh, 15 June 2007.

[១៩១] UNDP, "Clearing for Results, Annual Project Review Report," Phnom Penh, 15 March 2007. For details of UNDP contributions under this program, see earlier section *Strategic Mine Action Planning*.

[១៩២] CCW Amended Protocol II Article 13 Report, Annex 4, March 2007.